# ការវិភាគអំពី ភាពក្រីក្រ
# និង ការប្រើប្រាស់ធនធានវារីសត្វ
# ដោយផ្តោតទៅលើជីវភាពរស់នៅ
# របស់អ្នកក្រីក្រ

## សេចក្ដីសង្ខេប

របាយការណ៍នេះត្រូវបានរៀបរៀងឡើង ដោយផ្អែកលើពត៌មានដែលមានក្នុងឯកសារផ្សេងៗ និងពីការសំភាសន៍ជាមួយអ្នកផ្ដល់ពត៌មានសំខាន់ៗ ក្នុងគោលបំណងធ្វើការប៉ាន់ប្រមាណ និងវិភាគជាពិសេសអំពីស្ថានភាពជីវភាពក្រីក្ររបស់ប្រជាជនកម្ពុជា និងរបាយធនធានវារីជាតិ ។ របាយការណ៍នេះ រៀបរាប់ពិពណ៌នាអំពីស្ថានភាពក្រីក្ររបស់ប្រជាជនកម្ពុជា ដោយវិភាគតាមវិធីសាស្ត្រផ្សេងៗគ្នា និងចង្អុលបង្ហាញអំពីនានាភាពនៃធនធានវារីជាតិ និងរបាយប្រើប្រាស់ធនធានទាំងនេះ នៅតាមទីតាំងភូមិសាស្ត្រខុសៗគ្នា នៅក្នុងប្រទេសកម្ពុជា ។

ប្រទេសកម្ពុជាត្រូវបានចាត់បញ្ចូលក្នុងចំណោម ២០% នៃប្រទេសដែលមានការអភិវឌ្ឍន៍ធនធានមនុស្សក្នុងកំរិតទាបនៅឡើយ ។ កម្ពុជាក៏ស្ថិតក្នុងចំណោម ២០ ប្រទេសដែលក្រីក្របំផុតនៅក្នុងពិភពលោក ។ ប្រជាជនប្រមាណ ៩០% ដែលរស់នៅតាមជនបទ ភាគច្រើនជាអ្នកក្រីក្រ មានជីវភាពគ្រួសារជាសំខាន់អាស្រ័យលើការនេសាទ និងកសិកម្មដូចជា ការធ្វើដំណាំស្រូវទ្រង់ទ្រាយតូច កាប់ព្រៃ និងនេសាទជាដើម ។ វិស័យជលផលត្រូវបានគេទទួលស្គាល់ថាមានតួនាទីយ៉ាង សំខាន់ក្នុងការរក្សាសុវត្ថិភាពស្បៀងអាហារ រក្សានិរន្តរភាពនៃជីវភាពរស់នៅរបស់ប្រជាជន និងជាប្រភពផ្ដល់ប្រាក់ ចំណូលគ្រួសារផងដែរ ។

នេសាទទឹកសាបកម្ពុជា ជាប្រភពផ្ដល់ប្រូតេអ៊ីនត្រីដ៏ច្រើនជាងគេបំផុត ហើយដែលការគ្រប់គ្រងធនធានអោយមាននិរន្តរភាពនោះ មានសារៈសំខាន់ណាស់ក្នុងការរក្សាសុវត្ថិភាពស្បៀងអាហារ និងស្ថេរភាពនៃជីវភាពរស់នៅរបស់ប្រជាជនកម្ពុជានៅតាមជនបទ ។ អ្នកដែលប្រើប្រាស់ធនធានជលផលទ្រង់ទ្រាយតូច គឺមានអ្នកនេសាទជាលក្ខណៈគ្រួសារ និង អ្នកនេសាទនៅតាមតំបន់ឆ្ងាយពីដែននេសាទដែលធ្វើវារីវប្បកម្មទ្រង់ទ្រាយតូច ឬ ធ្វើនេសាទបន្តិចបន្តួចដែលជាចំណែកនៃជីវភាពរស់នៅ ។

គេពិនិត្យឃើញមានភាពខុសគ្នាយ៉ាងខ្លាំងអំពីស្ថានភាពសង្គម និងធនធានមនុស្សរវាងបណ្ដាខេត្តផ្សេងៗនៅកម្ពុជា។ ការសិក្សាស្រាវជ្រាវបានចង្អុលបង្ហាញថា ខេត្តកំពង់ស្ពឺ ជាខេត្តដែលពុំសូវមានប្រយោជន៍ ដោយឡែកខេត្តរតនគិរី មណ្ឌលគិរី កំពង់ចាម សៀមរាប និងព្រៃវែង មានការអភិវឌ្ឍន៍ធនធានមនុស្សក្នុងកំរិតទាបណាស់ ។ ប្រជាជនកម្ពុជាដែលក្រីក្របំផុតមាននៅពាសពេញផ្ទៃប្រទេស ថ្វីបើភាពក្រីក្រត្រូវបានកាត់បន្ថយប្រមាណ ៣ % ក្នុងរវាងឆ្នាំ ១៩៩៣ និង ១៩៩៧ ។ ប្រជាជនកម្ពុជាប្រហែល ៣៦ % មានជីវភាពរស់នៅក្រោមខ្សែបន្ទាត់នៃភាពក្រីក្រ គឺទាបជាង ១៤៥ ដុល្លា អាមេរិក ក្នុងម្នាក់ ក្នុងមួយឆ្នាំ ។

- ប្រជានេសាទជាលក្ខណៈគ្រួសារភាគច្រើននេសាទនៅតាមទន្លេតូចៗ បឹង ទំនាបព្រៃលិចទឹក និង បឹងទន្លេសាប ។ មានប្រជានេសាទជាលក្ខណៈគ្រួសារប្រមាណ ១៥ % នៅបណ្ដាខេត្តជុំវិញបឹងទន្លេសាប ( កំពង់ធំ សៀមរាប បន្ទាយមានជ័យ បាត់ដំបង ពោធិសាត់ កំពង់ឆ្នាំង និង ខេត្តកណ្ដាលភាគខាងជើងនៃក្រុងភ្នំពេញ) និង ប្រមាណ ៣៩% នៅតំបន់ទន្លេបាសាក់ និងទន្លេមេគង្គ (ខេត្តកណ្ដាលភាគខាងត្បូងក្រុងភ្នំពេញ កំពង់ចាម ស្វាយរៀង ព្រៃវែង និង ខេត្តតាកែវ) ។ តំបន់ភាគខាងលើនៃទន្លេមេគង្គកម្ពុជា ដែលមាន

ចំណោតទឹកធ្លាក់ (ខេត្ត ក្រចេះ និងស្ទឹងត្រែង) ត្រូវបានចាត់ទុកជាតំបន់ប្រព័ន្ធអេកូឡូស៊ីទីពា ដែលមាន នេសាទពុំសូវមានសារៈសំខាន់សេដ្ឋកិច្ច ប៉ុន្តែមានលក្ខណៈអេកូឡូស៊ី មានសារៈសំខាន់ចំពោះ ប្រភេទត្រីធ្វើចរាចរខ្លាំង ផ្សារភ្ជាប់ជាមួយបណ្តាតំបន់ ដីទៃទៀត និងមានសារៈសំខាន់ចំពោះនេសាទ ជាលក្ខណៈគ្រួសាររបស់ប្រជាជនរស់ នៅជិតខាង ។

- ការធ្វើវារីវប្បកម្មទ្រង់ទ្រាយតូច ឬ ការប្រមូលធនធានជលផល មានសារៈសំខាន់ណាស់នៅបណ្តាខេត្តនៅឆ្ងាយពីទន្លេបាសាក់ ទន្លេមេគង្គ និងបឹងទន្លេសាប ដូចជានៅខេត្តកំពង់ស្ពឺ រតនៈគីរី មណ្ឌលគីរី ព្រះវិហារ និង ឧត្តរមានជ័យ ដែលជាខេត្តខ្សត់ធនធានជលផល ។

បញ្ហាចំបងដែលប្រជានេសាទក្រីក្រកម្ពុជាជួបប្រទះ គឺជុំវិញបញ្ហាសិទ្ធិក្នុងការចូលនេសាទ និង ការទំនាក់ទំនងជាមួយបណ្តាភ្នាក់ងារដែលទទួលបន្ទុក ។ ការយល់ដឹងអំពីផ្នែកជំនាញបច្ចេកទេសរបស់មន្ត្រីជលផល និងបណ្តាភ្នាក់ងារដែល មានការងារទំនាក់ទំនងជាមួយកសិករក្រីក្រ អ្នកគ្មានកម្មសិទ្ធិដីធ្លី និងប្រជានេសាទទ្រង់ទ្រាយតូច នៅមានកំរិតនៅឡើយ ។ បញ្ហាទាំងនេះមានសារៈសំខាន់ណាស់ ព្រោះវាជះឥទ្ធិពលលើការផ្សព្វផ្សាយគោលនយោបាយ យុទ្ធសាស្ត្រ និងភាពសមស្របចំពោះប្រជានេសាទ។ លើសពីនេះវាក៏ជះឥទ្ធិពលលើសិទ្ធស្របច្បាប់របស់ប្រជានេសាទក្រីក្រ ក្នុងការរំដោះខ្លួនចេញផុត ពីភាពក្រីក្រតាមរយៈការបង្កើនទ្រង់ទ្រាយនៃការនេសាទ ។

<u>មានកម្មវត្ថុជាច្រើនក្នុងការកែប្រែស្ថានភាពបែបនេះ ក្នុងនោះរួមមាន :</u>

- <u>ជំរុញដំណើរការកសាងគោលនយោបាយចំពោះអ្នកក្រីក្រៈ</u> ណែនាំ និងកសាងសមត្ថភាពមន្ត្រីរាជការក្នុង និង ក្រៅរដ្ឋាភិបាល សំរបសំរួលរវាងស្ថាប័ននៅតាមមូលដ្ឋាន និងនៅទូទាំងប្រទេសដើម្បីចូលរួមចំណែក ទំនាក់ទំនង រវាងស្ថាប័ននានាក្នុងតំបន់ ដែលពាក់ព័ន្ធនឹងការគ្រប់គ្រងធនធានវារីជាតិ សំដៅកាត់បន្ថយភាព ក្រីក្រ និង អភិវឌ្ឍន៍ជនបទ ។ ជាពិសេសជំរុញការយល់ដឹងអំពីភាពក្រីក្រ ការប្រើប្រាស់ធនធានវារីជាតិ កសាងសមត្ថភាព អ្នកចូលរួមក្នុងដំណើរការវិភាគអំពីជីវភាពរស់នៅអោយមាននិរន្តរភាព ពិនិត្យរកចំនុចខ្លាំង និង គោលបំណងរបស់ ប្រជាជនក្រីក្រនៅតាមជនបទ ស្វែងយល់អំពីចំនុចខ្សោយ និងការជះឥទ្ធិពលពីគោលនយោបាយ និងស្ថាប័នលើ ប្រជាជនក្រីក្រ ។
- <u>បញ្ហាដែលពាក់ព័ន្ធនឹងការនេសាទៈ</u> ក្នុងនោះរួមមាន ការកំណត់ព្រំប្រទល់ដែននេសាទដែលចែងក្នុងច្បាប ជលផល ពិនិត្យព្រំប្រទល់ឡូត៍នេសាទឡើងវិញ ពិនិត្យនិយមន័យ និងកំណត់ដែន នេសាទសំរាប់ការនេសាទជា លក្ខណៈគ្រួសារ ឬ នេសាទទ្រង់ទ្រាយតូច បង្កើតឡើងវិញនូវច្បាប់នៃការនេសាទជាលក្ខណៈគ្រួសារ ដំណើរការដេញថ្លៃឡូត៍នេសាទ រយៈពេល/អាណត្តិនៃការធ្វើអាជីវកម្មនេសាទ បញ្ហានៃការស្រាវជ្រាវឡូត៍ នេសាទ ការគ្រប់គ្រងធនធានជលផល តាមរូបភាពសហគមនេសាទ ការផ្ទេរការទទួលខុសត្រូវ ក្នុងការចំណាយ ថវិកាជូនអាជ្ញាធរ ឬ ស្ថាប័ននៅតាមបណ្តាខេត្តក្រោមឱវាទនាយកដ្ឋាន និង ក្រសួង និង អនុវត្តយុទ្ធវិធី ចំណាយថវិកាអោយបានសមស្របនឹងធនធានមនុស្សក្នុងស្ថាប័នរបស់ខ្លួន ។

*************

# ការវិភាគភាពក្រីក្រ និងការប្រើប្រាស់ធនធានជលផល ជាពិសេសអំពីជីវភាពរស់នៅរបស់ ប្រជាជនក្រីក្រកម្ពុជា

## ១.សេចក្តីផ្តើម

បើប្រៀបធៀបនឹងបណ្តាប្រទេសជិតខាង (ថៃ ឡាវ និងវៀតណាម) កម្ពុជាជាប្រទេសដ៏តូចមួយ មានផ្ទៃដី ១៨១.០៣៥ គីឡូម៉ែត្រក្រឡា មាន ២៤ ខេត្ត ក្រុង និងឆ្នេរសមុទ្រមានប្រវែងខ្លី ។ ប្រព័ន្ធទន្លេមេគង្គ ទន្លេបាសាក់ និង បឹងទន្លេសាបបានបង្ហូរទឹកជន់នៃទំនាបល្បាប់លិចទឹកដ៏ធំ នៅភាគកណ្តាលនៃប្រទេសកម្ពុជា ដែលភាគច្រើននៃប្រជាជន ប្រមាណ ៨៦% មានជីវភាពរស់នៅអាស្រ័យនឹងទំនាបលិចទឹកនេះ (មីហ្សិង, ១៩៩៨)។ ការធ្វើជំរឿនប្រជាជននៅឆ្នាំ ១៩៩៨ បានរកឃើញថា ប្រទេសកម្ពុជាមានប្រជាជនចំនួន ១១.៤ លាននាក់ ហើយប្រជាជនប្រមាណ ៨២% រស់នៅ តាមជនបទ ។

របរកសិកម្មរបស់ប្រជាជនកម្ពុជានៅតាមជនបទ ជាកសិកម្មយថាផល ប្រាក់ចំណូលប្រែប្រួលខ្លាំង ជួបប្រទះ គ្រោះលំបាកជាច្រើន (ដូចជាមានជម្ងឺ និងគ្រោះថ្នាក់ជាដើម) និងផលស្តុកគ្មានស្ថេរភាព ដូចជា ការសន្សំប្រាក់ និងការស្តុក ស្បៀងអាហារជាដើម។ ធនធានសាធារណៈ ជាពិសេសធនធានវារីជាតិមានសារៈសំខាន់ណាស់ចំពោះប្រជារាស្ត្រក្រីក្រ នៅតាមជនបទក្នុងការរក្សាសុវត្ថិភាពស្បៀងអាហារ ។ ធនធានវារីជាតិកកើតឡើងក្នុងប្រព័ន្ធអេកូនៃ ទំនាបលិចទឹក ដោយរបបទឹកជំនន់ពីទន្លេមេគង្គជារៀងរាល់ឆ្នាំដែលទទួលរងឥទ្ធិពលពីរបបខ្យល់ពីទិសនិរតី (មិថុនា-តុលា) ហើយធ្វើ អោយទំនាបលិច ទឹកនោះមានទំហំ ១០.០០០-១៣.០០០ គ.ម$^2$ នៅរដូវវស្សាគ្របដណ្តប់តាមបណ្តាទន្លេ និងដៃរបស់វា បឹងទន្លេសាប និង ទន្លេបាសាក់ (និងមាន ទំហំ តែ ២.៦០០-៣.០០០ គ.ម$^2$ ប៉ុណ្ណោះនៅរដូវប្រាំង) ។ នៅ រដូវវស្សារបបទឹក ទន្លេមេគង្គបានហូរចូលទៅបឹងទន្លេសាប ផ្ទុយទៅវិញនៅរដូវប្រាំង ទឹកបឹងទន្លេសាបបានហូរ ចេញមក ទន្លេមេគង្គវិញ ។

ការនេសាទជារបរសំខាន់របស់ប្រជាជនក្រីក្រកម្ពុជារស់តាមជនបទ ។ ត្រី និងបណ្តាវារីសត្វ ដូចជា (ក្តាម កំពឹស ខ្យង កង្កែបជាដើម) និងរុក្ខជាតិទឹក (ដូចជា ព្រលិត ត្រកួន ជាដើម) ជាប្រភពផ្តល់ប្រូតេអ៊ីនរហូតដល់ ៧៥ % នៅ ក្នុងចំណីអាហារ ។ ការនេសាទ និងការប្រមូលធនធានវារីជាតិផ្សេងៗទៀត អាចប្តូរបានជាប្រាក់សំរាប់ទិញអង្ករពិសារ ។ ជារៀងរាល់ឆ្នាំប្រជាកសិករកម្ពុជាតែងតែយកស្រូវអង្ករទៅបឹងទន្លេសាប ប្តូរយកត្រីរៀល (*Henicorhynchus sp.*) និងប្រភេទត្រីតូចៗផ្សេងទៀតដើម្បី ធ្វើប្រហុក ដែលជាសមាភាពនៅក្នុងអាហារដ៏សំខាន់របស់ប្រជាកសិករក្រីក្រនៅតាម ជនបទ ។ ការនេសាទ និងការងារដែលមានទំនាក់ទំនងនឹងការនេសាទជារបរសំខាន់ទីមួយរបស់ប្រជាជនប្រមាណ ១០.៥% និង ៣៤.១% ជាអ្នកដែលមានរបរបន្ទាប់បន្សំ ពាក់ព័ន្ធនឹងការនេសាទនៅតាមភូមិនេសាទ (អាមេត, ១៩៩៨) និងប្រជាជនភាគច្រើន ដែលគ្មានកម្មសិទ្ធិដីធ្លី បានប្រកបការនេសាទ និងប្តូរត្រីយកស្រូវអង្ករ ។

នេសាទទឹកសាបកម្ពុជាបានចូលរួមចំណែកយ៉ាងសំខាន់ក្នុងសុវត្ថិភាពស្បៀងអាហារ និងសេដ្ឋកិច្ចរបស់ប្រជាជន ជាងការនេសាទដូចគ្នានេះ នៅបណ្តាប្រទេសផ្សេងៗទៀតនៅលើពិភពលោក ។ នេសាទទឹកសាបកម្ពុជា បានផ្តល់ទិន្នផល

ត្រីប្រចាំឆ្នាំជាមធ្យម ២៩០.០០០-៤៣០.០០០ តោន (ដៀប. ១៩៩៨ អាមេត. ១៩៩៨ ធូក.២០០០ ហៀនហ្សិន.២០០០) ដែលជាប់ចំណាត់ថ្នាក់លេខ ៤ ដោយសារសំបូរត្រីទឹកសាបច្រើនជាងគេបំផុតលើពិភពលោក ។ ទិន្នផលត្រីទាំងនេះគិតជាប្រាក់មានតំលៃ ១០០-២០០ លានដុល្លាអាមេរិក (តំលៃនៅទីកន្លែងនេសាទ) បើគិតជាតំលៃនៅតាមទីផ្សារ មានតំលៃជាទឹកប្រាក់ចំនួន ២៥០-៥០០ លានដុល្លាអាមេរិក ដែលចូលរួមវិភាគទានប្រមាណ ៩%-១៨% នៃ ២.៨០០ លានដុល្លាអាមេរិកនៃផលិតផលក្នុងស្រុក (GDP) (MEF. 1999)។ ប្រជាជនកម្ពុជាប្រមាណ ៤.៣ លាននាក់ មានជីវភាពរស់ដោយពឹងផ្អែកលើប្រាក់ចំណូលតិចជាង ១១៣ ដុល្លាអាមេរិកក្នុងមួយឆ្នាំ ។ ទិន្នផល ត្រីប្រចាំឆ្នាំដែលបានពីការនេសាទជាលក្ខណៈគ្រួសារ និង តាមវាលស្រែ មានប្រមាណ ១៦០.០០០-២៥០.០០០ តោន ។ ទោះបីច្រើនជាងទិន្នន័យនៅបណ្តាឆ្នាំមុនៗ ប៉ុន្តែប្រហែលជានៅចាំប្រមាណទាបនៅឡើយ។ រាល់កិច្ចខិតខំប្រឹងប្រែងទាំងឡាយក្នុងការអភិវឌ្ឍន៍ ប្រទេសកម្ពុជាគឺសំដៅជួយទំនុកបំរុង និង កាត់បន្ថយភាពក្រីក្ររបស់ប្រជាជន។ ការកាត់បន្ថយភាពក្រីក្រ គឺជាតំរូវការជាបន្ទាន់បំផុតនៅកម្ពុជា ជាមួយគ្នានោះការនេសាទមានសារៈសំខាន់ណាស់ចំពោះ ជីវភាពរស់នៅរបស់ប្រជាជន ជាពិសេសចំពោះប្រជារាស្ត្រក្រីក្រនៅតាមជនបទ ។

ថ្វីបើមានពត៌មានបន្តិចបន្តួចប៉ុណ្ណោះអំពីរបាយនៃភាពក្រីក្រ ប៉ុន្តែគេបានដឹងថា មានប្រជាជនកម្ពុជាប្រមាណ ៣៦% មានជីវភាពរស់នៅស្ថិតក្រោមខ្សែបន្ទាត់នៃភាពក្រីក្រ (MP / UNDP.1999)។ ការសិក្សាស្រាវជ្រាវអំពីសេដ្ឋកិច្ច សង្គម នៅឆ្នាំ ១៩៩៣-៩៤ និងនៅឆ្នាំ ១៩៩៧ បានបង្ហាញអោយដឹងថា នៅរាជធានីភ្នំពេញមានប្រជាជនក្រីក្រ ប្រមាណ ១១ % តំបន់ជាយក្រុង ៣០% និង នៅជនបទមានប្រមាណ ៤០% ។ ទោះជាយ៉ាងណាក្តី គេបានដឹងយ៉ាងច្បាស់ថា ប្រជាកសិករ នៅតាមជនបទដែលមានប្រភពប្រាក់ចំណូលជាចំបងពីកសិកម្មមាន ៩០% នៃប្រជាជនក្រីក្រកម្ពុជា ។

សេចក្តីរាយការណ៍នេះដែលផ្អែកលើឯកសារបច្ចុប្បន្ន និងពត៌មានដែលទទួលបានពីការសំភាសន៍ ជាមួយប្រភពផ្តល់ពត៌មានសំខាន់ៗ មានគោលបំណងសំខាន់ចាំប្រមាណអំពីស្ថានភាព និងរបាយនៃភាពក្រីក្រ និងការប្រើប្រាស់ធនធានជលផល ដែលជាពិសេសអំពីជីវភាពក្រីក្ររបស់ប្រជាជន ដែលមានដូចតទៅ :

- ពិនិត្យឡើងវិញនូវស្ថានភាពបច្ចុប្បន្ននៃជីវភាពរស់នៅរបស់ប្រជាជនក្រីក្រកម្ពុជា និង របាយនៅតាមទីតាំងភូមិសាស្ត្រ (នៅទូទាំងប្រទេស នៅតាមតំបន់ តាមតំបន់ទំនាបលិចទឹក បឹង ទន្លេសាប តំបន់ភ្នំ និងខ្ពង់រាបតាមតំបន់របៀងទន្លេមេគង្គ (Mekong Corridor) និងតាមបណ្តាខេត្ត ទូទាំងប្រទេស) រហូតដល់រដ្ឋបាលថ្នាក់ទាបបំផុតដូចជា ករិតនៃការអភិវឌ្ឍន៍ធនធានមនុស្ស នៅតាម បណ្តាខេត្តជាដើម ។
- ធនធានវារីជាតិ (ជាពិសេសធនធានជលផល និងវារីវប្បកម្ម) ការប្រើប្រាស់របស់វា និងសារៈសំខាន់ចំពោះសុវត្ថិភាពស្បៀងអាហាររបស់ប្រជាជននៅតាមជនបទ ការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ និងវិធីសាស្ត្រគ្រប់គ្រងជាគន្លឹះ និងបញ្ហាលំបាកដែលជួបប្រទះ និង
- លក្ខណៈសេដ្ឋកិច្ចសង្គមរបស់អ្នកប្រើប្រាស់ធនធានវារីជាតិ ។

## ២. សញ្ញាណបញ្ញាក់អំពីភាពក្រីក្រនៅកម្ពុជា:

ភាពក្រីក្រជាបញ្ហាបង្កផលវិបាកចំពោះការអភិវឌ្ឍន៍ធនធានមនុស្ស គឺវិតលទ្ធភាពជ្រើសរើសរបស់ប្រជាជន ធ្វើឱ្យបាត់បង់សេចក្ដីថ្លៃថ្នូរ និងគ្មានការគោរពចំពោះខ្លួនឯង ។ មានវិធីសាស្ត្រជាច្រើនក្នុងវាស់ភាពក្រីក្រ ដែលត្រូវបានប្រើប្រាស់នៅកម្ពុជា ដូចជាប្រាក់ចំណូលទាប ការប្រើប្រាស់/ចំណាយទាប ខ្វះខាតសំភារៈប្រើប្រាស់ ពុំមានកម្មសិទ្ធិដីធ្លី មានសុខភាពមិនល្អ និងបាត់បង់សមត្ថភាពពលកម្ម អត្រាមរណៈភាពខ្ពស់ មានកំរិតវប្បធម៌ទាប និង ខ្វះមធ្យោបាយទំនាក់ទំនង ។

### ២.១. ខ្សែបន្ទាត់នៃភាពក្រីក្រ

#### ២.១.១. ខ្សែបន្ទាត់នៃភាពក្រីក្រចំពោះចំណីអាហារ

ខ្សែបន្ទាត់នៃភាពក្រីក្រចំពោះចំណីអាហារ ដែលមនុស្សម្នាក់ៗ ត្រូវការជាអប្បរមាដើម្បីផ្លងផុតពីភាពក្រីក្រ ត្រូវបានអនុម័ត គឺ ២.១០០ កាឡូរីក្នុងមួយថ្ងៃ ។ ក្នុងការអនុវត្តជាក់ស្តែង តំរូវការថាមពលកាឡូរីរបស់មនុស្សម្នាក់ៗដែលទទួលបានពីចំណីអាហារប្រែប្រួលតាមអាយុ ទំងន់ និងការបញ្ចេញពលកម្ម ឧទាហរណ៍ កសិករ (២.៧៨០) បុរសដែលធ្វើការងារធ្ងន់ (៣.៤៩០) ស្ត្រីនៅតាមជនបទ (២.២៣៥) ក្មេងប្រុសអាយុ១០ឆ្នាំ (២.០៨០) ក្មេងស្រី (១.៩១៥) (WHO, 1985) ។

ខ្សែបន្ទាត់នៃភាពក្រីក្រចំពោះចំណីអាហារគិតជាប្រាក់រៀល នៅភ្នំពេញ ១.១៨៥ រៀល /ថ្ងៃ តំបន់ជាយក្រុង ៩៥៥ រៀល/ថ្ងៃ និងនៅជនបទ ៨៨១ រៀល/ថ្ងៃ ដើម្បីអាចទទួលបានថាមពលប្រចាំថ្ងៃពីចំណីអាហារ២.១០០កាឡូរី/ថ្ងៃ។ ខ្សែបន្ទាត់នៃភាពក្រីក្រ ចំពោះចំណីអាហារដែលត្រូវការជាអប្បរមាដែលបំបែកទៅតាមប្រភេទចំណីអាហារ មានបង្ហាញនៅក្នុងតារាង ២.១។ ថាមពលដែលទទួលបានពីគ្រាប់ធញ្ញជាតិ ជាពិសេសស្រូវមាន ២/៣ ឬ ៦៥ % នៃថាមពលសរុប ។ គេពិនិត្យឃើញថា មានការចំណាយប្រាក់ទៅលើសាច់ច្រើនជាងប្រភេទអាហារផ្សេងៗទាំងអស់ នៅគ្រប់តំបន់ទាំងអស់នៅកម្ពុជា ។

តារាង២.១. **សមាសភាពខ្សែបន្ទាត់នៃភាពក្រីក្រចំពោះចំណីអាហារតាមក្រុមប្រភេទអាហារ (គិតជា រៀល/ថ្ងៃ)**

| ក្រុមប្រភេទអាហារ | ១១៨៤.៩ | ៩៥៥.៣ | ៨៨១.៤ | ២.១០០ |
|---|---|---|---|---|
| ភេសជ្ជៈ | ៥១.៣ | ៣៧.១ | ៣១.២ | ១២២.៣ |
| គ្រាប់ធុញ្ញជាតិ | ២៨៩.០ | ២៤៧.៣ | ២៤៦.៨ | ១៤៤០.២ |
| ផលិតផលប្រចាំថ្ងៃ | ៧.៦ | ២.៧ | ៥.៧ | ១.៥ |
| ស៊ុត | ២០.៦ | ២០.៨ | ២០.៧ | ៧.៨ |
| ផ្លែឈើ | ១០៤.៥ | ៧៨.២ | ៦២.៥ | ៥៥.៦ |

| | | | | |
|---|---|---|---|---|
| សាច់ | ៤៣៣.៧ | ៣៦៨.៣ | ៣១១.៧ | ២០២.៨ |
| ប្រេង និងខ្លាញ់ | ១៣.១ | ១២.៨ | ១២.៥ | ៥០.៣ |
| ផលិតផលអាហារផ្សេងៗទៀត | ៥៤.៤ | ៣៥.៤ | ២៦.២ | ៥៥.៧ |
| បន្លែ | ១១៨.៣ | ១០៨.៥ | ៨៣.១ | ៤២.២ |
| ស្ករ អំបិល និងគ្រឿងទេស | ៩២.៣ | ៨៤.២ | ៨១.០ | ១២១.៥ |

(អាត្រាប្តូរប្រាក់: ១ដុល្លាអាមេរិក = ២.៥០០រៀល)

**ការចំណាយលើសំភារៈប្រើប្រាស់** (non-food allowance)

គេធ្វើការវិភាគស្ថិតិ (regression analysis) ដើម្បីកំណត់ការចំណាយលើការប្រើប្រាស់ ក្រៅពីស្បៀងអាហារក្នុងគ្រួសារក្នុងកំរិតដែលអាចឈានដល់ខ្សែបន្ទាត់នៃភាពក្រីក្រ។ តាមរយៈការវិភាគនេះ បានចង្អុលបង្ហាញថា: មានភាគនៃការចំណាយលើសំភារៈប្រើប្រាស់ក្នុងគ្រួសារខុសៗគ្នា រវាងតំបន់និមួយៗនៃប្រទេសកម្ពុជា។ នេះជាការពិតណាស់ សំភារៈមានតំលៃខុសគ្នាពីតំបន់មួយទៅតំបន់មួយ និង ខុសពីបណ្តាប្រទេសផ្សេងៗទៀត។ តាមការវិភាគនេះគេបានប៉ាន់ប្រមាណការចំណាយលើសំភារៈនៅទីក្រុងភ្នំពេញមាន ៣៩៣ រៀល/ថ្ងៃ នៅទីប្រជុំជននៅបណ្តា ស្រុក ឬខេត្ត ២៩៦ រៀល/ថ្ងៃ និងនៅតាមជនបទ ២៣៦ រៀល/ថ្ងៃ។

**ខ្សែបន្ទាត់នៃភាពក្រីក្រ**

ខ្សែបន្ទាត់នៃភាពក្រីក្រជាលទ្ធផលទទួលបានពីផលបូកនៃការចំណាយលើចំណីអាហារ និងការចំណាយក្រៅពីស្បៀងអាហារនៅក្នុងតំបន់និមួយៗ។ ជាលទ្ធផល ខ្សែបន្ទាត់នៃភាពក្រីក្រទូទៅនៅកម្ពុជាក្នុងឆ្នាំ ១៩៩៣-៩៤ នៅភ្នំពេញ ១.៥៧៨ រៀល/ថ្ងៃ (១ ដុល្លាអាមេរិក = ២៥០០ រៀល) នៅទីប្រជុំជន ១.២៦៤ រៀល/ថ្ងៃ និងនៅជនបទ ១.១១៧ រៀល/ថ្ងៃ ។

ភាពក្រីក្រដាច់ខាតមាននៅពាសពេញកម្ពុជា (UNDP, 1997, UNDP, 1998, MoP, 1998)(2) នៅឆ្នាំ ១៩៩៣-១៩៩៤ ប្រជាជនកម្ពុជាប្រមាណ ៣៩% មានជីវភាពរស់នៅទាបជាង ១៤៥ ដុល្លាអាមេរិក/ឆ្នាំ (តារាង២.១) ត្រូវបានកាត់បន្ថយមកត្រឹម៣៦.១% នៅឆ្នាំ ១៩៩៧ ភាគច្រើនមានប្រាក់ចំណូលស្ថិតនៅក្រោមខ្សែបន្ទាត់ក្រីក្របន្តិច ។ ស្ថានភាពជីវភាពក្រីក្ររបស់ប្រជាជន (incidence of poverty) មានទាបបំផុតនៅក្រុងភ្នំពេញ (១១.១%) បន្ទាប់មកនៅតាមទីប្រជុំជនក្រៅភ្នំពេញ (២៩.៩%) និងជនបទ (៤០.១%) (តារាង២.២) ។ លើសពីនេះ គំលាតនៃភាពក្រីក្រ (dept of poverty) ដែលជារង្វាស់រវាងការចំណាយរបស់គ្រួសារក្រីក្រ និងខ្សែបន្ទាត់ភាពក្រីក្រមានគំលាត ធៀបតូចនៅកម្ពុជា (៩.២% នៅឆ្នាំ ១៩៩៣ /៩៤ ថយមកត្រឹម ៨-៧% នៅឆ្នាំ ១៩៩៧) (តារាង ២-១ និង២-២) ។ កំរិតធ្ងន់ធ្ងរនៃភាពក្រីក្រ (Severity of poverty) មានប្រមាណ ៣.១% នៅឆ្នាំ ១៩៩៣/៩៤ និង ១៩៩៧ នៅទូទាំងប្រទេសកម្ពុជា ទោះបីជាមានភាពខុសគ្នាខ្លាំងរវាងតំបន់នានាក្តី ។ (ជាការពិតណាស់ បើយុទ្ធសាស្ត្រនៃការកាត់បន្ថយភាពក្រីក្រ ត្រូវបានអនុវត្តចំគោលដៅបានល្អនឹងធ្វើឱ្យមានកំណើនប្រាក់ចំណូល ១៨ ដុល្លាអាមេរិក/

នាក់/ខែ នោះ ឬត្រូវនឹង ១៩០ លាន ដុល្លាអាមេរិក នៅទូទាំងប្រទេស ក្នុងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន។ ចំនួននេះ មានប្រហែល ៤០% នៃជំនួយអន្តរជាតិសំរាប់ការអភិវឌ្ឍន៍ដែលទទួលបាននៅឆ្នាំ ១៩៩៥) ។

ដោយប្រជាជនក្រីក្រកម្ពុជាប្រមាណ ៩០% រស់នៅជនបទ ហើយកសិករមានភាពក្រីក្រខ្លាំងជាងគេបំផុត យុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ ត្រូវផ្តោតយកចិត្តទុកដាក់ចំពោះវិស័យកសិកម្ម ។

ភស្តុតាងនៃការស្រាវជ្រាវបានចង្អុលបង្ហាញឱ្យឃើញពី កំណើនឡើងនៃការប្រើប្រាស់មិនស្មើគ្នា នៅតំបន់ជនបទ ក្នុងរវាងឆ្នាំ ១៩៩៣/៩៤ និង១៩៩៦ ។ កំណើននៃការប្រើប្រាស់របស់អ្នកមានបំផុតចំនួន ២០% ក្នុងម្នាក់ ធ្វើឱ្យមានកំណើនភាគនៃការប្រើប្រាស់ទូទាំងប្រទេស ក្នុងខណៈនោះ ធ្វើឱ្យអ្នកក្របំផុតត្រូវបាត់បង់ការប្រើប្រាស់របស់ខ្លួនចំនួន ៨០%។ ស្ថានភាពនេះ គេពិនិត្យឃើញមានជាច្រើននៅក្នុងដំណាក់កាលនៃសេដ្ឋកិច្ច អន្តរកាល ដែលបណ្តាលមកពីទីផ្សារសេរីបានបង្កើតឡើងនូវឱកាសល្អសំរាប់អ្នកមានអាចរកប្រាក់ចំណូលបានប្រសើរឡើង។

គេពិនិត្យឃើញស្ថានភាពក្រីក្រមានភាពខុសគ្នាខ្លាំងពីតំបន់មួយទៅតំបន់មួយ។ នៅតំបន់ឆ្នេរ និងតំបន់ភ្នំមានស្ថានភាពក្រីក្រទាបជាងគេបំផុត (ប្រហែល២២%) តំបន់បឹងទន្លេសាបមានស្ថានភាពក្រីក្រខ្លាំងជាងគេបំផុត (៣៨%) (ក្រាហ្វិក ១ )។ នៅតំបន់វាលទំនាបប្រជាជនប្រមាណ ២៩% មានជីវភាពរស់នៅក្រោមខ្សែបន្ទាត់នៃភាពក្រីក្រ (UNDP 1999) ។

ក្រាហ្វិក ១: ស្ថានភាពក្រីក្រ (incidence of poverty) នៅតាមតំបន់នៃកម្ពុជា ១៩៩៧




ប្រភព: CSES (១៩៩៧) និង UNDP (១៩៩៩)

ទន្ទឹមនឹងប្រជាជនក្រីក្របំផុតប្រមាណ ២០% បន្ថយភាគនៃការប្រើប្រាស់ស្បៀងអាហារ ប្រជាជនក្រីក្រទាំងនេះក៏ប្រើប្រាស់សំភារៈដូចជា វិទ្យុ ទូរទស្សន៍ កង់ និងម៉ូតូ ក្នុងរយៈពេលវែងដែរ ។ ទោះបីមានការលូតលាស់សេដ្ឋកិច្ចយ៉ាងខ្លាំងក្នុងរយៈពេល ៣ ឆ្នាំ ក្តី ប៉ុន្តែអត្រានៃប្រជាជនក្រីក្រត្រូវបានកាត់បន្ថយបន្តិចបន្តួចប៉ុណ្ណោះ។ ភាគរយៈនៃ

ប្រជាជនក្រីក្រដែលមានជីវភាពរស់នៅក្រោមខ្សែបន្ទាត់នៃភាពក្រីក្រ នៅតំបន់ទីប្រជុំជនក្រៅក្រុងភ្នំពេញ បានថយចុះយ៉ាងច្រើន មានថយចុះបន្តិចបន្តួចនៅតំបន់ជនបទ និងពុំមានការថយចុះទេនៅទីក្រុងភ្នំពេញ ។

តារាង២.២ **សញ្ញាណនៃភាពក្រីក្រនៅតាមតំបន់ផ្សេងនៅកម្ពុជា ១៩៩៣.៩៤ (គិតជាភាគរយ%)**

| តំបន់ | ភាគរយប្រជាជន | សញ្ញាណគិតតាមចំនួនមនុស្ស | គំលាតភាពក្រីក្រ | ភាពធ្ងន់ធ្ងរនៃក្រីក្រ |
|---|---|---|---|---|
| ភ្នំពេញ | ១០.៧ | ១១.៤ | ៣.១ | ១.២ |
| ទីប្រជុំជន | ១១.០ | ៣៦.៦ | ៩.៦ | ៣.៦ |
| ជនបទ | ៧៨.២ | ៤៣.១ | ១០.០ | ៣.៣ |
| សរុប | ១០០ | ៣៩.០ | ៩.២ | ៣.១ |

ប្រភព: NIS ១៩៩៨ និង Prescott និង Prahan (១៩៩៧) * ចំនួនសរុបគិតទៅតាមតំបន់សិក្សាស្រាវជ្រាវតែប៉ុណ្ណោះ

តារាង ២.៣: **វិធ្វាស់នៃភាពក្រីក្រនៅតាមតំបន់នានានៅកម្ពុជា ១៩៩៧**

| | ចំនួនប្រជាជន | ភាគរយប្រជាជន | ភាគរយៈគិតតាមចំនួនមនុស្សយកគំរូ | គំលាតភាពក្រីក្រ | ភាពធ្ងន់ធ្ងរនៃភាពក្រីក្រ |
|---|---|---|---|---|---|
| ខ្សែបន្ទាត់ភាពក្រីក្រស្បៀងអាហារ | | | | | |
| ភ្នំពេញ | ០.៩ | ៨.៥ | ៣.៤ | ០.៥ | ០.១ |
| ទីប្រជុំជន | ១.១ | ១០.៥ | ១៥.៤ | ៣.៣ | ១.១ |
| ជនបទ | ១០.៤ | ៨១.០ | ២០.០ | ៣.៩ | ១.២ |
| សរុប | | ១០០ | ១៧.៩ | ៣.៥ | ១.១ |
| ខ្សែបន្ទាត់ភាពក្រីក្រ | | | | | |
| ភ្នំពេញ | ០.៩ | ៨.៥ | ១១.១ | ២.២ | ០.៦ |
| ទីប្រជុំជន | ១.១ | ១០.៥ | ២៩.៩ | ៧.៥ | ២.៧ |
| ជនបទ | ៨.៤ | ៨១.០ | ៤០.១ | ៩.៧ | ៣.៤ |
| សរុប | ១០.៤ | ១០០ | ៣៦.១ | ៨.៧ | ៣.១ |

ប្រភព: NIS ១៩៩៨ MoP/UNDP/SIDA/WORLD BANK ១៩៩៩

## ២.២ សញ្ញាណនៃភាពក្រីក្រតាមការងារធ្វើ និងជីវិតវប្បធម៌

នៅកម្ពុជាគេងាយនឹងឃើញភាពក្រីក្រ រាយទៅតាមក្រុមមនុស្សធ្វើការងារ និងជីវិតវប្បធម៌ ។ គេឃើញមានភាពក្រីក្រខ្ពស់បំផុតក្នុងចំណោមប្រជាជនដែលរស់នៅក្នុងគ្រួសារដែលមេគ្រួសារជាកសិករ និងអ្នកនេសាទ (៤០%) កម្មករសំណង់ និងអ្នកជីករ៉ែ (៣៧%) និងអ្នកដឹកជញ្ជូន (៣១%) (UNDP 1997) ។ ភាពក្រីក្រក្នុងចំណោមមន្ត្រីរាជការ មានប្រមាណ ២០% ។

ស្ទើរតែ ៧៥% នៃប្រជាជនក្រីក្រប្រកបរបរកសិកម្ម និង នេសាទ ។ លោក អាមេត (១៩៩៨) បានសង្កេតឃើញមាន ៧៧% នៃគ្រួសារដែលរស់នៅជុំវិញបឹងទន្លេសាប ខេត្តនៅតាមដងទន្លេមេគង្គ និងទន្លេបាសាក់ (ខេត្តកណ្តាល កំពង់ចាម កំពង់ឆ្នាំង សៀមរាប ពោធិសាត់ បាត់ដំបង និងកំពង់ធំ) មាន ៣៩% ប្រកបរបរកសិកម្ម និង នេសាទ ជាចំបង (តារាង ២.៣) ។ អត្រានៃប្រជាជនប្រកបរបរនេសាទខុសគ្នារវាងបណ្តាខេត្តនិមួយៗ ដូចជានៅខេត្តកំពង់ឆ្នាំងមានគ្រួសារធ្វើនេសាទចំនួន ៥៤% នៅខេត្តកំពង់ធំមានតែ ២១% (តារាង ២.៤) ។ ការសិក្សាស្រាវជ្រាវរបស់អង្គការ AIT-Aqua Outreach (១៩៩៨) លើប្រជាជនចំនួន ៥០គ្រួសារ នៅស្រុកច្បារមន និងស្រុកសំរោង ខេត្តកំពង់ស្ពឺ បានបង្ហាញឱ្យឃើញថាមាន ៧៦% នៃគ្រួសារដែលបានសំភាសន៍ ប្រកបរបរនេសាទជា លក្ខណៈគ្រួសារ (នេសាទទ្រង់ទ្រាយតូច) (នេសាទតាមវាលស្រែ ១០០%) នៅបឹង (២១%) តាមព្រែក (១៨%) និងនៅតាមស្ទឹង (៣%) ។

តារាង២.៤ **ភាគរយនៃគ្រួសារប្រកបរបរនេសាទ និងកសិកម្ម ១៩៩៦**

| ខេត្ត/ក្រុង | ប្រកបរបរនេសាទ | ប្រកបរបរកសិកម្ម |
|---|---|---|
| ភ្នំពេញ | ៤០.០៧ | ៤២.២៨ |
| កណ្តាល | ៣១.៤០ | ៧៦.៥០ |
| កំពង់ចាម | ៣៨.២០ | ៧៧.៦ |
| កំពង់ឆ្នាំង | ៥៤.២៦ | ៦៩.៧៩ |
| សៀមរាប | ៣៩.៧៧ | ៨៧.៣៨ |
| ពោធិសាត់ | ៤៨.៣៦ | ៨២.៧១ |
| បាត់ដំបង | ៤៦.៣៩ | ៧៧.៦៩ |
| កំពង់ធំ | ២១.៤៤ | ៨១.៥៣ |
| កំពង់ស្ពឺ | ៧៦.០០* | ១០០.០០ |

ប្រភព: អាមេត (១៩៩៨)* ភាគរយៈគ្រួសារធ្វើនេសាទជាលក្ខណៈគ្រួសារតែប៉ុណ្ណោះ

ស្ថានភាពក្រីក្រក៏ប្រែប្រួលខុសគ្នាទៅតាមកំរិតវប្បធម៌របស់មេគ្រួសារដែរ ។ ប្រមាណ ៤៧.១% នៃ ប្រជាជនក្រីក្ររស់នៅក្នុងគ្រួសារដែលមេគ្រួសារជាអនក្ខរជន ៣០.១% ក្នុងគ្រួសារដែលមេគ្រួសារមាន កំរិតវប្បធម៌ថ្នាក់មធ្យមសិក្សា និង ពុំមានអ្នកក្រីក្រទេ (០%) នៅក្នុងគ្រួសារដែលមេគ្រួសារមានកំរិតវប្បធម៌ ថ្នាក់វិទ្យាល័យ ឬ សាកលវិទ្យាល័យ ។

ទោះជាយ៉ាងណាក្តី គេពិនិត្យឃើញមានភាពឯកភាពគ្នាបន្តិចបន្តួចរវាងការប៉ាន់ប្រមាណសេដ្ឋកិច្ចសង្គម នៅបណ្តាខេត្តជុំវិញបឹងទន្លេសាប ទន្លេសាប ទន្លេមេគង្គ និងទន្លេបាសាក់ ។ កំរិតវប្បធម៌របស់មេគ្រួសារខុសគ្នា រវាងបណ្តាលខេត្ត (តារាង ២.៥) ។ អត្រាអ្នកចេះអក្សរ (ចេះអាន ចេះសរសេរអក្សរខ្មែរ) របស់មេគ្រួសារជា អ្នកនេសាទ (៣៦%) ទាបជាងអត្រាគិតតាមជនបទនៅទូទាំងប្រទេស (៧៦%) និងអត្រាមធ្យមទូទាំងប្រទេស (៦៦.៨%) និងទាបជាងអត្រាដែលទទួលបានពីការស្រាវជ្រាវផ្សេងទៀត ដូចជារបស់អង្គកាស្បៀងអាហារពិភពលោក (WFP-

Cambodia ១៩៩៩) មាន ៧០% ជាអ្នកចេះអក្សរ (នៅខេត្តបន្ទាយមានជ័យ បាត់ដំបង កំពង់ឆ្នាំង កំពង់ស្ពឺ ឧត្តរមានជ័យ ព្រះវិហារ និងសៀមរាប) និងអង្គការ UNICEF/WFP មាន ៧៧% ជាអ្នកចេះអក្សរ។

តារាង ២.៥: **ស្ថានភាពកំរិតវប្បធម៌របស់មេគ្រួសារនៅក្នុងបណ្តាខេត្តនេសាទចំនួន ៨ ជុំវិញបឹងទន្លេសាប ទន្លេមេគង្គ និងទន្លេបាសាក់ ១៩៩៦**

| កំរិតវប្បធម៌ | ភ្នំពេញ | កណ្តាល | កំពង់ចាម | កំពង់ឆ្នាំង | ស.រៀប | ពោធិសាត់ | បាត់ដំបង | កំពង់ធំ | សរុប |
|---|---|---|---|---|---|---|---|---|---|
| អនក្ខរភាព | ២៣.២ | ១២.០ | ២២.៣ | ២០.២ | ២៦.៤ | ២០.៨ | ២០.១ | ២៦.៨ | ២០.៣ |
| អាចអានបាន | ២៨.៣ | ៣០.៩ | ៣០.៦ | ៣៤.៩ | ៥៧.២ | ៣២.២ | ៥០.២ | ៣១.៤ | ៣៦.៣ |
| បឋមសិក្សា | ៣៦.៨ | ៣១.៤ | ៣១.៧ | ៣១.៥ | ៩.៩ | ២៦.៧ | ១៩.៣ | ២៥.១ | ២៧.១ |
| មធ្យមសិក្សាកំរិត១ | ៩.៦ | ២២.២ | ១១.៨ | ១២.៣ | ៥.៥ | ១៤.០ | ៨.៣ | ១៤.៤ | ១៣.៤ |
| មធ្យមសិក្សាកំរិត២ | ១.៨ | ៣.២ | ៣.៤ | ១.១ | ១.០ | ៦.៣ | ២.១ | ២.១ | ២.៨ |
| បរិញ្ញបត្រ័/ខ្ពស់ជាងនេ | ០.៤ | ០.៤ | ០.៣ | | | | | | ០.២ |

ប្រភព: អាមេត (១៩៩៨)

ផ្នែកអភិវឌ្ឍន៍ធនធានមនុស្សកម្ពុជារបស់កម្មវិធីអភិវឌ្ឍន៍របស់អង្គការសហប្រជាជាតិ (UNDP) បានរកឃើញសមមាត្រនៃមនុស្សពេញវ័យខ្ពស់ផុតអនក្ខរភាព មានពី ០,៨៤៤ នៅក្រុងភ្នំពេញទៅ ០,១៦៦ ប៉ុណ្ណោះនៅខេត្តមណ្ឌលគីរី (តារាង ២.៦) ។

តារាង ២.៦ **សមមាត្រនៃមនុស្សពេញវ័យចេះអក្សរ និងចំនួនឆ្នាំសិក្សាកំរិតជាមធ្យម តាមបណ្តាខេត្តកម្ពុជា ១៩៩៦**

| ខេត្ត/ក្រុង | សមមាត្រនៃមនុស្សពេញវ័យ (>១៥ឆ្នាំ) ចេះអក្សរ | ចំនួនឆ្នាំសិក្សាកំរិតជាមធ្យម |
|---|---|---|
| ភ្នំពេញ | ០,៨៤៤ | ៦,១៣ |
| កណ្តាល | ០,៧២៦ | ៤,០៨ |
| ក្រចេះ | ០,៧១៣ | ២,៨៤ |
| កំពង់ស្ពឺ | ០,៧០៨ | ៣,៧៤ |
| កំពង់ចាម | ០,៧០៧ | ៣,៦៣ |
| បាត់ដំបង | ០,៧០៣ | ៣,៨៤ |
| ពោធិសាត់ | ០,៦៩០ | ៣,៦៣ |
| កំពត | ០,៦៨៧ | ៣,៣៩ |
| ស្វាយរៀង | ០,៦៧៨ | ៣,៥៧ |
| ក្រុងព្រះសីហនុ | ០,៦៦៩ | ៣,៩០ |

| | | |
|---|---|---|
| ស្ទឹងត្រែង | ០.៦៦៨ | ៣.២៩ |
| កោះកុង | ០.៦៥៣ | ៣.១៦ |
| តាកែវ | ០.៦៥០ | ៣.៥៦ |
| បន្ទាយមានជ័យ | ០.៦២៩ | ៣.៣០ |
| ព្រៃវែង | ០.៦១៩ | ៣.៤៥ |
| កំពង់ឆ្នាំង | ០.៥៨៤ | ៣.២២ |
| កំពង់ធំ | ០.៥៥៤ | ២.៧៣ |
| កែប | ០.៥០៦ | ២.៣៧ |
| សៀមរាប | ០.៤៥៣ | ២.០៥ |
| រតនៈគិរី | ០.២៩៤ | ១.៥២ |
| មណ្ឌលគិរី | ០.១៦៦ | ០.៩៨ |
| កម្ពុជា | ០.៦៦៨ | ៣.៦៨ |

## ២.៣ . ការប្រើប្រាស់របស់មនុស្សម្នាក់ៗ:

ការសិក្សាស្រាវជ្រាវសេដ្ឋកិច្ចសង្គមនៅកម្ពុជារបស់ CSES ពុំបានអនុវត្តន៍នៅក្នុងបណ្ដាខេត្តចំនួន៦ (ព្រះវិហារ កោះកុង មណ្ឌលគិរី រតនៈគិរី ស្ទឹងត្រែង និងក្រចេះ) ក្នុងចំណោមបណ្ដាខេត្តទាំងអស់ចំនួន ២១ ដោយសារបញ្ហាអសន្តិសុខ។ ការចំណាយលើការប្រើប្រាស់ប្រចាំថ្ងៃរបស់ប្រជាជនម្នាក់ៗគិតជាមធ្យម នៅក្នុងបណ្ដាខេត្ត ចំនួន ១៥ មានបង្ហាញនៅក្នុងតារាង ២.៧ ។ នៅទីក្រុងភ្នំពេញ និងក្រុងព្រះសីហនុ មានលក្ខណៈប្រសើរជាងគេបំផុត។ ខេត្តចំនួនពីរនៅតំបន់ឆ្នេរ ក្រុងព្រះសីហនុ និងកំពតមានកំរិតនៃការប្រើប្រាស់ច្រើនជាងបណ្ដាតំបន់ផ្សេងទៀត។ បណ្ដាខេត្ត ដែលមានព្រំដែនជាប់ប្រទេសថៃ (ចុងខាងលិចនៃប្រទេសកម្ពុជា) និង វៀតណាម (ចុងខាងកើតនៃប្រទេសកម្ពុជា) មានកំរិតនៃការប្រើប្រាស់ទាបជាងគេបំផុត។ ការសិក្សាស្រាវជ្រាវពុំបានគ្របដណ្ដប់លើបណ្ដាខេត្តនៅខាងជើងបំផុតតាមបណ្ដាព្រំដែនវៀតណាម ឡាវ និងថៃ។ ខេត្តទាំងនោះ ត្រូវបានចាត់ចំណាត់ថ្នាក់ជាតំបន់ខ្ពង់រាបដែលមានខេត្ត ព្រះវិហារ រតនៈគិរី មណ្ឌលគិរី ស្ទឹងត្រែង និងក្រចេះ ដែលមានដង់ស៊ីតេប្រជាជនទាប និង កំរិតនៃការប្រើប្រាស់ទាបជាងតំបន់វាលទំនាប បឹងទន្លេសាប និង តំបន់ឆ្នេរ ហើយក៏ប្រហែលទាបជាងតំបន់ភ្នំ (ទំនាក់ ទំនងផ្ទាល់ជាមួយ ឯ.ឧ. សេងសឿន អគ្គនាយករងនៃ NIS/MoP ថ្ងៃទី ១៧ ខែតុលា ឆ្នាំ ២០០០)។ ខេត្តកោះកុងបែងចែកជាបីផ្នែក ដែលស្ថិតនៅតំបន់ឆ្នេរ ។ ការប្រើប្រាស់របស់ប្រជាជនម្នាក់ៗនៅក្នុងខេត្តកោះកុង មានកំរិតប្រហាក់ប្រហែលនឹងខេត្តកំពត និងក្រុងព្រះសីហនុ (ទំនាក់ទំនងផ្ទាល់ ជាមួយ ឯ.ឧ. សេងសឿន ខែតុលា ឆ្នាំ ២០០០) ។

តារាង ២.៧: **របាយនៃការប្រើប្រាស់របស់ប្រជាជនម្នាក់ៗតាមបណ្ដាខេត្ត/តំបន់ ១៩៩៧**

| ខេត្ត/តំបន់ | ចំនួនប្រជាជន (លាននាក់) | ចំនួនគ្រួសារដែលជួបសំភាសន៍ | ការប្រើប្រាស់របស់ប្រជាជនម្នាក់ៗ | | | ៩៥% ចន្លោះនៃសុក្រិតភាព | |
|---|---|---|---|---|---|---|---|
| | | | មេដ្យាន | មធ្យម | លំអៀងនៃមធ្យម | ចន្លោះលើ | ចន្លោះក្រោម |
| ភ្នំពេញ | ១.០០ (៨.៧%) | ១៧០៨ | ១២១៩ | ៤៣៦៧ | ១១៦ | ៤១៤០ | ៤៩៥៤ |
| កណ្ដាល | ១.០៧ (៩.៤%) | ៩១០ | ១៣៨១ | ១៦៤២ | ៤៥ | ១៥៥៣ | ១៧៣០ |
| កំពង់ចាម | ១.៦០ (១៤%) | ៦៦៤ | ១១៩៥ | ១៤២៦ | ៣៦ | ១៣៥៦ | ១៤៥៦ |
| ស្វាយរៀង | ០.៤៧ (៤.២%) | ២៧០ | ១០៥២ | ១១៩៤ | ៣៥ | ១១២៥ | ១២៦២ |
| ព្រៃវែង | ០.៩៤ (៨.៣%) | ៩៩៤ | ១២២៥ | ១៤៦៥ | ៣២ | ១៤០៣ | ១៥២៧ |
| តាកែវ | ០.៧៩ (៦.៩%) | ៤១៣ | ១២២៦ | ១៥២១ | ១០០ | ១៣២៥ | ១៧១៨ |
| តំបន់ទំនាប | ៥.៨៧ (៥១.៥%) | ៤១៥៩ | ១៣២៣ | ១៨៧៨ (០.៧៥$) | ៣៦ | ១៨០៨ | ១៩៤៩ |
| កំពង់ធំ | ០.៥៦ (៥.០%) | ៩៧ | ១២៦៩ | ១៧៧៩ | ១៤៣ | ១៤៥៥ | ២០៦៤ |
| សៀមរាប | ០.៧៨ (៦.១%) | ១៧៥ | ១២១៩ | ១៥៤៩ | ១១៤ | ១៣២៣ | ១៧៧៥ |
| បន្ទាយមានជ័យ | ០.៥៧ (៥.១%) | ២០៦ | ១១៣៧ | ១៤១២ | ១១១ | ១១៩៤ | ១៦៣១ |
| បាត់ដំបង | ០.៧៩ (៦.៩%) | ២៩៣ | ១១២៥ | ១៣៩២ | ៥៤ | ១២៨៦ | ១៤៩៧ |
| ពោធិសាត់ | ០.៣៦ (៣.២%) | ២០៧ | ១៣៣៣ | ១៦៩៧ | ៨៩ | ១៥២២ | ១៨៧២ |
| កំពង់ឆ្នាំង | ០.៤២ (៣.៧%) | ១៣៦ | ១២៧១ | ១៥៨៥ | ៩០ | ១៤០៨ | ១៧៦២ |
| តំបន់ទន្លេសាប | ៣.៤៨ (២៤.០%) | ១១១៤ | ១២១៩ | ១៥២៩ (០.៦១$) | ៣៩ | ១៤៥៣ | ១៦០៥ |
| ក្រុងព្រះសីហនុ | ០.១៥ (១.៤%) | ៧០ | ៤៣៩៥ | ៩១៦២ | ៣៧៨ | ៤៤០៧ | ៩៩១៧ |
| កំពត | ០.៥២ (៤.៦%) | ១៣០ | ១១៤៧ | ២១៩៩ | ៩៧៣ | ១០២៩ | ៣២៩៤ |
| តំបន់ឆ្នេរ | ០.៦៧ (៦.០%) | ២០០ | ១៣៩៧ | ២៨០៣ (១.១២$) | ៤៣១ | ១៩៥៣ | ៣៦៥២ |
| កំពង់ស្ពឺ | ០.៦ (៥.២%) | ១០៥ | ១២១៤ | ១២៩៦ | ៩៤ | ១១៨៩ | ១៤០៣ |
| តំបន់ភ្នំ | ០.៦ (៥.២%) | ១០៥ | ១២១៤ | ១២៩៦ (១.៥២ $) | ៩៤ | ១១៨៩ | ១៤០៣ |
| កម្ពុជា | ១០.៦ (៨៧.០%) | ៩៩៧៨ | ១៣០០ | ១៨៣៣ (០.៧៣$) | ៣២ | ១៧៧០ | ១៨៩៥ |

## ២.៤. **ភាគនៃអាហារ**

" ភាគនៃអាហារ" (Food share) គឺជាសញ្ញាណបញ្ជាក់ភាពក្រីក្រដែលប្រើប្រាស់នៅពេលដែលពុំមានទិន្នន័យនៃភាពក្រីក្រផ្សេងទៀត ដូចជា ភាគនៃចំណាយសរុបចំពោះអាហារក្នុងគ្រួសារ ។ គ្រួសារអ្នកក្រីក្រមានភាគចំណាយសរុបលើស្បៀងអាហារច្រើនជាងគ្រួសារអ្នកមាន (តារាង ២.៨) ។ នៅឆ្នាំ ១៩៩៦ ភាគចំណាយសរុបប្រចាំខែរបស់អ្នកក្រីក្រ

បំផុតមានរហូតដល់ ៦៦% ផ្ទុយទៅវិញគ្រួសារអ្នកមាន មានត្រឹម ៥០% ប៉ុណ្ណោះ។ ទោះជាយ៉ាងណាក្តីគេក៏ពិនិត្យឃើញមានការថយចុះនៃភាគរយចំណាយអាហារនៃគ្រួសារទាំងអស់ក្នុងរវាងឆ្នាំ ១៩៩៣/៩៤ និង១៩៩៦ ហើយភាគនៃស្បៀងអាហាររបស់អ្នកក្រីក្របំផុត បានចុះថយពី ៧២.៦% ទៅ ៦០.៦% ដែលមានការថយចុះ ប្រហែល ១០%។ ទិន្នន័យនេះបញ្ជាក់ថា អ្នកក្រីក្របំផុតមានប្រាក់ចំណូលប្រសើរជាងមុនក្នុងចន្លោះពេលនោះ។ ការថយចុះនេះប្រហែលជាមានភាពប្រហាក់ប្រហែលគ្នានៅតាមតំបន់ជនបទ និងទីក្រុង ។

តារាង ២.៨ **ភាគនៃអាហារការចំណាយប្រចាំខែរបស់ប្រជាជននៅទីក្រុង និងជនបទ កម្ពុជា ១៩៩៣/៩៤ និង១៩៩៦**

| ការចំណាយសរុប | ជនបទ | | ទីក្រុង | | សរុប | |
|---|---|---|---|---|---|---|
| | ១៩៩៣-៩៤ | ១៩៩៦ | ១៩៩៣-៩៤ | ១៩៩៦ | ១៩៩៣-៩៤ | ១៩៩៦ |
| ១.អ្នកក្របំផុត | ៧២.៧៤ | ៦៥.៤៨ | ៧០.៨៦ | ៦៤.២២ | ៧២.៥៥ | ៦៥.៦០ |
| ២. | ៧១.៩១ | ៦៦.៨៧ | ៦៧.៩៥ | ៦៣.៥៦ | ៧១.៧៤ | ៦៦.៧៦ |
| ៣. | ៧១.៥៤ | ៦៥.៥៣ | ៦២.២៨ | ៥៩.០៣ | ៧១.១២ | ៦៤.០៤ |
| ៤. | ៦៩.៥៧ | ៥៦.៧៥ | ៥៦.៣៤ | ៥៥.១៨ | ៦៧.២០ | ៥៦.០៣ |
| ៥.អ្នកមានបំផុត | ៦៣.៦៤ | ៤៨.២៣ | ៤៨.២៥ | ៤៥.៣៤ | ៥៧.៦៤ | ៤៨.១៨ |
| សរុប | ៦៩.៨៨ | ៦០.៥៧ | ៦១.១៥ | ៥៧.៤៧ | ៦៨.០៥ | ៦០.១២ |

សំគាល់: ការចំណាយនេះគណនាដោយផ្អែកលើមូលដ្ឋាននៃការចំណាយសរុបប្រចាំខែរបស់គ្រួសារដែលត្រូវបានជួបសំភាសន៍ ។

## ២.៥. ភាពគ្មានសមភាព និងភាពក្រីក្រ

មេគុណ Gini ជាសញ្ញាណបញ្ជាក់នូវភាពគ្មានសមភាពដែលមានកំរិតខ្ពស់ជាទូទៅនៅទីក្រុងភ្នំពេញ (០.៤៦) ថយមកទាបនៅតាមទីប្រជុំជន (០.៤៤) និងទាបបំផុតនៅជនបទ (០.៣៣) (តារាង ២.៩)។ មេគុណ Gini នៅប្រទេសជិតខាងមាន ០.៣០ នៅប្រទេសឡាវ ០.៣៥ នៅវៀតណាម និង ០.៣២ នៅប្រទេសឥណ្ឌូនេស៊ី។ កម្ពុជាមានភាពមិនសមភាពគ្នាខ្ពស់ជាទូទៅ បើប្រៀបធៀបនឹងបណ្តាប្រទេសជិតខាង ។

តារាង ២.៩ **រង្វាស់គ្មានសមភាពនៃការប្រើប្រាស់នៅកម្ពុជា ខែមិថុនា ឆ្នាំ ១៩៩៧**

| | មេគុណ Gini | រង្វាស់ Theil ដែលប្រៀបធៀបនឹងចំនួនប្រជាជន | រង្វាស់នៃការប្រើប្រាស់របស់ប្រជាជនម្នាក់១ | បំរែបំរួលឡូការីតនៃការប្រើប្រាស់របស់ប្រជាជនម្នាក់១ | ភាគនៃការប្រើប្រាស់របស់ប្រជាជនម្នាក់១ ក្នុងចំណោម ១០% នៃប្រជាជនក្រីក្របំផុត (%) | ភាគនៃការប្រើប្រាស់របស់ប្រជាជនម្នាក់១ ក្នុងចំណោម ១០% នៃ អ្នកមានបំផុត(%) |
|---|---|---|---|---|---|---|
| ក្រុងភ្នំពេញ | ០.៤៦ | ០.៧៨ | ០.៣៨ | ០.៤១ | ២.៦ | ៤០.៣ |
| ទីប្រជុំជន | ០.៤៤ | ០.៤៩ | ០.៣៣ | ០.៤៧ | ២.៧ | ៣៧.៦ |
| ជនបទ | ០.៣៣ | ០.២១ | ០.១៧ | ០.៣០ | ៣.៧ | ២៧.១ |
| សរុប | ០.៤២ | ០.៤៨ | ០.២៩ | ០.៤១ | ៣.០ | ៣៥.៣ |

ប្រភព: NIS 1999, 1998 (CSES 1993-94) Prescott និង Pradhan 1997) ។

## ២.៦ លក្ខណៈសេដ្ឋកិច្ច-សង្គមនៃភាពក្រីក្រ

ខណៈដែលវិធានការប្រើប្រាស់ជាមូលដ្ឋាននៃភាពក្រីក្រ គឺជារង្វាស់មួយដ៏សមរម្យសំរាប់វាស់វែងរបាយនៃស្តង់ដាជីវភាពក្នុងប្រជាជនកម្ពុជា។ ពួកគាត់មិនអាចបំពេញបានទាំងស្រុង ទៅនឹងលក្ខណៈសង្គមដ៏ទៃទៀតនៃភាពក្រីក្រ ដូចជា: អក្ខរកម្ម សុខភាព ឬសិទ្ធិទទួលបានទឹកស្អាត។ ផ្នែកនេះផ្តល់នូវទស្សនៈសង្ខេបនៃរបាយ ដែលការជ្រើសរើសមិនទាក់ទងនឹង ខាងរូបិយវត្ថុ ឬ កត្តាសន្ទស្សរបស់សង្គម នៃស្តង់ដាជីវភាពគ្រួសារ ដោយប្រើប្រាស់ទិន្នន័យ ដែលប្រមូលបានពី CSES (មើលតារាង២.១០)។

### សមាសភាពផ្ទះសម្បែង

ជនក្រីក្រមានទំនោរចង់រស់នៅយ៉ាងខ្លាំង ក្នុងផ្ទះធំទូលាយ ដោយមានចំនួនសមាជិកក្នុងគ្រួសារជាមធ្យម ៦.៦ នាក់ ចំពោះquintileក្របំផុត ប្រៀបធៀបទៅនឹង quintileដែលមានជាង គឺ ៤.៩។ ជនក្រីក្រមានទំនោរផងដែរ ក្នុងការរស់នៅជាគ្រួសារក្មេងខ្ចី ដែលមានកូនក្រោមអាយុ ១៥ ឆ្នាំ ក្នុងមួយគ្រួសារ(៣.៤) ២ដងនៃ poorest quintile ច្រើនជាង richest quintile ហើយមានបន្ទុកចបន្ទួចចំពោះមនុស្សចាស់ដែលមានអាយុច្រើនជាង៦០ឆ្នាំ។ គ្រួសារដែលប្រសើរបំផុតនោះ គឺមានទំនោរទៅរកគ្រួសារដែលមានមេគ្រួសារ ហើយមេគ្រួសារនោះមានអាយុច្រើន។ ការពន្យល់មួយអាចបញ្ជាក់ថា អាយុជាមធ្យមនៃស្ត្រីដែលជាមេគ្រួសារ(៥០.១ឆ្នាំ) គឺល្អប្រសើរជាងមេគ្រួសារដែលជាបុរស(៤២.៣ ឆ្នាំ)។ នៅប្រទេសកម្ពុជាអាត្រានៃភាពក្រីក្រថយចុះ ចំពោះអាយុជាមធ្យមនៃមេគ្រួសារដែលមានអាយុក្រោយ ៣៩។ ប៉ុន្តែ បើទុកជាបានធ្វើការវិនិច្ឆ័យអាយុផ្សេងគ្នាក៏ដោយ ក៏ភាពក្រីក្រនូវតែបញ្ជាក់យ៉ាងច្បាស់ថា គ្រួសារដែលដឹកនាំដោយស្ត្រីនៅតែទាបជាង (NIS/MoP/SIDA/UNDP/World Bank, 1999) ។

### អក្ខរកម្ម និង ការសិក្សា

អក្ខរកម្ម និង ការសិក្សា គឺជាកត្តាសំខាន់ណាស់សំរាប់គុណភាពនៃជីវិតដែលជាសិទ្ធិផ្ទាល់ខ្លួន ហើយក៏ជាគន្លឹះកំនត់នៃសមត្ថភាពនៃប្រជាជនក្រីក្រក្នុងការទទួលយកផលប្រយោជន៍ពីឱកាសដែលអាចបង្កើនចំណូល។ ប្រទេសកម្ពុជាទទួលបានការចេះអាន និង សរសេរជាមូលដ្ឋានក្នុងអាត្រាមធ្យម ៦៧ ភាគរយសំរាប់មនុស្សពេញវ័យដែលមានអាយុច្រើនជាង ១៥ឆ្នាំ បញ្ជាក់នូវកំរិតខ្ពស់ក្នុងចំណោមជនក្រីក្រ។ ចំណែកឆ្នាំសិក្សាក្នុងចំណោមមនុស្សពេញវ័យ អាយុលើសពី១៥ឆ្នាំ ជាមធ្យមត្រឹមតែ ៣.១ឆ្នាំប៉ុណ្ណោះនៃជនក្រីក្របំផុត គឺ២០ភាគរយនៃប្រជាជនទាំងអស់ ហើយកើនឡើងរហូតដល់ ៥.៣ឆ្នាំសិក្សា ក្នុងចំណោមអ្នកមានបំផុតគឺ ២០ ភាគរយ ( តារាង ២.១០ និង តារាង ២.៦)។ នេះគឺមានការបែងចែកភេទយ៉ាងខ្លាំង រវាងកំរិតនៃការទទួលបាន ចំពោះបុរស ៥.១ឆ្នាំសិក្សាប្រៀបធៀបនឹងស្ត្រី គឺ ៣.២ ឆ្នាំសិក្សា។

NIS(១៩៩៩)បានរាយការណ៍ថា ភាពក្រីក្រ headcount index ដោយរាយការណ៍ពីការចេះអាន និង សរសេរនៃមេគ្រួសារបង្ហាញពីភាពក្រីក្រ គឺទាបចំពោះអ្នកដែលចេះអាន និង សរសេរ (៣៤ភាគរយ) ជាងចំពោះអ្នកដែលមិនចេះអាន និង សរសេរ(៤២ភាគរយ)។ ចំនួន ២ភាគ៣នៃជនក្រីក្រដែលមេគ្រួសារនោះត្រូវបានរាយការណ៍ថាជាអ្នកដែលមិនចេះអាន និង សរសេរ។

**លក្ខខណ្ឌផ្ទះសំបែង និងទ្រព្យសម្បត្តិ**

លក្ខខណ្ឌផ្ទះសំបែង គឺជាធាតុសំខាន់មួយបែបទៀតក្នុងទស្សនៈផ្សេងៗ នៃសង្គមផងដែរ។ ទឹក និងអនាម័យ គឺមានឥទ្ធិពលយ៉ាងសំខាន់ទៅលើស្ថានភាពសុខភាព និងចំណីអាហារ។ CSES បង្ហាញថា ជនក្រីក្រគឺមិនអាចទទួលបានទាល់តែសោះនូវសិទ្ធិប្រើប្រាស់ការផ្គត់ផ្គង់ប្រភពទឹកស្អាត និងអនាម័យ។ មានត្រឹមតែ ៤ភាគរយប៉ុណ្ណោះនៃ quintile ជនក្រីក្របំផុតដែលទទួលបានសិទ្ធិប្រើប្រាស់ទឹកម៉ាស៊ីន ដែលជាមួយនោះច្រើនជាង ១៧ភាគរយជាអ្នកមានដែលទទួលបាន។ ចំពោះអនាម័យក៏មានភាពខុសគ្នាស្រដៀងគ្នានេះដែរ។ ជនក្រីក្រតិចតួច(៩ភាគរយ) អាចមានលទ្ធភាពមានបង្គន់ក្នុងផ្ទះ ដែលក្នុងពេលជាមួយនេះ អ្នកមានបំផុតជាងពាក់កណ្តាល(២០ភាគរយ) មានបង្គន់ក្នុងផ្ទះ។ កត្តាផ្សេងទៀតនៃស្តង់ដាផ្ទះសំបែងនោះ គឺសិទ្ធិក្នុងការប្រើប្រាស់អគ្គិសនី។ ជាថ្មីម្តងទៀតចំពោះអ្នកក្រ គឺនៅឆ្ងាយណាស់។ សិទ្ធិក្នុងការប្រើប្រាស់អគ្គិសនីដែលបានមកពីម៉ាស៊ីនភ្លើង និងការតបណ្តាញ លទ្ធភាពខ្ពស់បំផុតពីប្រភពទាំងនេះ គឺទាក់ទងយ៉ាងចំបងនឹងប្រាក់ចំណូល។ កើតឡើងតែ ១ ភាគរយប៉ុណ្ណោះ ចំណោមប្រជាជនដែលquintileក្រីក្របំផុត ទៅនឹង ៣៧ភាគនៃប្រជាជនកម្ពុជាដែល quintile មានបំផុត។ តារាង ២.១០ បង្ហាញផងដែរ៥ quintile នៃប្រជាជនដែលអាចប្រើប្រាស់កង់យានយន្ត និង ជាម្ចាស់កម្មសិទ្ធិវិតថៃរនៃ វិទ្យុ និងទូរទស្សន៍។

**តារាង ២,១០ ធាតុបំលែងផ្សេងៗគ្នានៃការបាន់ប្រមាណភាពក្រីក្រ**

**(កត្តាបង្ហាញពីភាពក្រីក្រនៃសេដ្ឋកិច្ចសង្គម)**

| | Quintile/a | | | | | | តំបន់ | | |
|---|---|---|---|---|---|---|---|---|---|
| | សរុប | ក្របំផុត | ២ | ៣ | ៤ | មានបំផុត | ភ្នំពេញ | ក្រុងផ្សេងៗ | ជនបទ |
| ទំហំគ្រួសារ | ៥.៦ | ៦,៥ | ៦.០ | ៥.៧ | ៥.០ | ៤.៩ | ៥.៩ | ៥.៩ | ៥.៥ |
| កូនក្នុងគ្រួសារ (អាយុ ០-១៤ឆ្នាំ) | ២.៤ | ៣.៥ | ២.៨ | ២.៥ | ១.៩ | ១.៨ | ២.៣ | ២.៦ | ២.៤ |
| មនុស្សចាស់ក្នុងគ្រួសារ (អាយុ +៦០ឆ្នាំ) | ០.៣ | ០.៣ | ០.៣ | ០.៣ | ០.៤ | ០.៤ | ០.៣ | ០.៣ | ០.៣ |
| ភាពឯករាជ្យ លែងធ្វើការបាន/b | ០.៨៤ | ០.៧៨ | ០.៩៣ | ០.៩៣ | ០.៩១ | ០.៦៨ | | | |
| អាយុមេគ្រួសារ | ៤៤.៦ | ៤៤.១ | ៤៣.០ | ៤៤.១ | ៤៥.២ | ៤៦.១ | ៤៥.០ | ៤៥.៣ | ៤៤.៥ |
| ស្ត្រីជាមេគ្រួសារ (%) | ២១.១ | ១៨.៦ | ១៧.៣ | ១៨.៩ | ២៣.៣ | ២៦.៦ | ២៥.៨ | ២៣.៤ | ២០.៤ |
| អក្ខរកម្ម (%អាយុពេញវ័យ +១៥) | ៦៦.៦ | ៥៧.៧ | ៦៤.៣ | ៦៦.២ | ៦៧.៩ | ៧៧.១ | ៨១.៨ | ៧២.៥ | ៦៧.៣ |
| ឆ្នាំសិក្សា (អាយុមធ្យមពេញវ័យ +១៥) | ៤.០ | ៣.១ | ៣.៧ | ៣.៨ | ៤.២ | ៥.២ | ៦.១ | ៤.៧ | ៣.៧ |
| ឆ្នាំសិក្សា/c (បុរសអាយុមធ្យម +១៥) | ៥.១ | ៣.១ | ៣.៧ | ៣.៨ | ៥.៤ | ៦.៦ | ៧.៣ | ៥.៨ | ៤.៧ |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ឆ្នាំសិក្សា/c (ស្ត្រីអាយុមធ្យម +១៥) | ៣.២ | ២.៤ | ២.៩ | ៣.០ | ៣.៣ | ៤.៣ | ៤.៩ | ៣.៨ | ២.៨ |
| ប្រើប្រាស់ទឹកម៉ាស៊ីន (%) | ៧.១ | ៤.៣ | ៣.៤ | ៣.៥ | ៥.៥ | ១៦.៧ | ៣៣.៦ | ១៣.៤ | ២.៩ |
| មានបង្គន់ក្នុងផ្ទះ (%) | ២២.១ | ៨.៧ | ១១.៣ | ១៣.៩ | ២១.១ | ៤៨.៧ | ៧៨.០ | ៤៦.៧ | ១១.៧ |
| ប្រើប្រាស់បណ្តាញអគ្គិសនី ឬ មានម៉ាស៊ីនភ្លើង(%) | ១២.៤ | ១.៣ | ២.១ | ៥.៥ | ១០.៤ | ៣៦.៨ | ៣៧.៤ | ៣០.២ | ៣.០ |
| មានវិទ្យុ (%) | ២៧.៧ | ២៣.០ | ២៥.១ | ២៥.៨ | ២៩.៩ | ៣៣.០ | ៣៨.៧ | ៣១.៤ | ២៥.៩ |
| មានទូរទស្សន៍ (%) | ១៣.៨ | ៣.០ | ៤.៨ | ៧.០ | ១២.៧ | ៣៥.៩ | ៥៧.០ | ២១.៦ | ៧.២ |
| មានកង់ (%) | ៦០.៩ | ៥៧.៧ | ៦៥.៣ | ៦៣.៣ | ៦១.៦ | ៥៦.៨ | ៤១.៣ | ៦០.៣ | ៦៣.៥ |
| មានឡាន, ហ្ស៊ីប ឬ ម៉ោចក្រយានយន្ត (%) | ១៨.០ | ៦.៤ | ៦.៧ | ១១.៧ | ១៨.៨ | ៤០.៥ | ៥៨.៨ | ២៧.១ | ១១.៦ |

ប្រភព: CSES 1993-94 and 1997; Pescott and Pradhan 1997

/a Quintile distribution based on real per capita expenditure using the implicit food poverty line price deflators

/b Dependency defined as number of disabled in family divided number of family members time 1000;

/c Average over all individual aged 15 and above. All other variables are averages across household.

## ២.៧ ការអភិវឌ្ឍន៍មនុស្ស និងជីវភាពរស់នៅ ក្នុងប្រទេសកម្ពុជា

ការអភិវឌ្ឍន៍មនុស្ស គឺសំដៅលើការធ្វើអោយល្អប្រសើរដល់ការរស់នៅរបស់ប្រជាជនសាមញ្ញ ដោយធ្វើអោយកាន់តែទូលំទូលាយនូវការជ្រើសរើស និង ជួយដល់ពួកគាត់អោយសំរេចបានទាំងស្រុង នូវសក្តានុពលភាពរបស់មនុស្ស។ ពេលដែលប្រាក់ចំណូលក្នុងម្នាក់ៗ គឺជាទិដ្ឋភាពដ៏ចំបងតែមួយគត់ក្នុងការធ្វើអោយល្អប្រសើរដល់ជីវភាពរស់នៅ។ សុខភាព និងការអប់រំក៏ជាកត្តាសំខាន់ផងដែរ ក្នុងការវិនិច្ឆ័យសុខុមាលភាពរបស់មនុស្ស។ តាមរបាយការណ៍ជាសកលឆ្នាំ ២០០០ នៃការអភិវឌ្ឍន៍មនុស្ស បានបូកបញ្ចូលបន្ថែមផងដែរ នូវសេរីភាព និង សិទ្ធិមនុស្សនៅក្នុងអត្ថន័យការអភិវឌ្ឍន៍មនុស្ស។

មានកត្តាសន្ទស្សន៍ជាច្រើនបានស្នើឡើង ដោយ UNDP សំរាប់វាស់វែងស្ថានភាពនៃការអភិវឌ្ឍន៍មនុស្សក្នុងប្រទេសដែលបង្ហាញនៅខាងក្រោម:

ក. កត្តាវិនិច្ឆ័យការអភិវឌ្ឍន៍មនុស្ស (HDI) គឺជារង្វាស់ដែលរួមបញ្ចូលនូវភាពមានអាយុវែង សមិទ្ធិកម្មអប់រំ និង ស្តង់ដានៃជីវភាពរស់នៅ។

ខ. កត្តាវិនិច្ឆ័យអភិវឌ្ឍន៍ទំនាក់ទំនងយេនឌ័រ (GDI) វាដូចគ្នានឹងកត្តាអភិវឌ្ឍន៍មនុស្ស ប៉ុន្តែបន្ថែមការយកចិត្តទុកដាក់ទៅលើភាពស្មើគ្នានៃភេទក្នុងអាយុកាលមធ្យមនៃជីវិត សមិទ្ធិកម្មអប់រំ និង ស្តង់ដានៃ ជីវភាពរស់នៅ។

គ. រង្វាស់នៃការផ្តល់អំណាចអោយយេនឌ័រ (GEM) វាគឺជាទំនាក់ទំនងនៃការចូលរួមរវាងស្ត្រី និង បុរសក្នុងវិស័យនយោបាយ និង សេដ្ឋកិច្ចនៃសកម្មភាព។

ឃ.កត្តាវិនិច្ឆ័យភាពក្រីក្រនៃមនុស្ស (HPI) វាគឺជារង្វាស់នៃភាពខ្វះខាត នៃធាតុសំខាន់១ ៣ក្នុងជីវិតមនុស្ស ភាពមានអាយុវែង ចំណេះដឹង និង កំរិតជីវភាពរស់នៅគ្រប់គ្រាន់។

**កត្តាវិនិច្ឆ័យការអភិវឌ្ឍន៍មនុស្សក្នុងប្រទេសកម្ពុជា**

HDI ដែលកម្ពុជាទទួលបានគឺ ០.៥១៧ តាមរយៈទិន្នន័យដែលធ្វើអង្កេតលើគ្រួសារ ក្រោយបំផុតពីជំរឿនប្រជាជនទូទៅ ឆ្នាំ ១៩៩៨ និងការអង្កេតសេដ្ឋកិច្ចសង្គមនៅកម្ពុជា (CSES) ឆ្នាំ ១៩៩៩។ នេះជាតួលេខមួយទាបបំផុតនៅអាស៊ី ដែលគ្រាន់តែខ្ពស់ជាងឡាវ (០.៤៨៤ និង បង់ក្លាដែស(០.៤៦១។ ឯ GDI របស់កម្ពុជា(០.៥១៤) វាប្រហាក់ប្រហែលនឹង HDI ដែលទទួលបាន។ ចំពោះតំលៃនៃ GEMសំរាប់កម្ពុជា គឺ ០.២៨៣ ។ មិនមាន GEM ត្រូវបានរាយការណ៍ទេក្នុងរបាយការណ៍អភិវឌ្ឍន៍របស់ UNDP ឆ្នាំ២០០០។ ជាចុងក្រោយនេះ HPI ដែលកម្ពុជាមានគឺ ៤២.៥៣ ដែលឆ្លុះបញ្ចាំងពីកំរិតខ្ពស់នៃអត្រាមរណៈភាព កុមារទទួលអាហារមិនគ្រប់គ្រាន់ និង ការផ្គត់ផ្គង់សេវាសាធារណៈមិនបានល្អនៅក្នុងប្រទេស។

**តារាង ២,១១ កត្តាវិនិច្ឆ័យការអភិវឌ្ឍន៍មនុស្សថ្នាក់ជាតិនៅកម្ពុជា ១៩៩៨**

| | កត្តាវិនិច្ឆ័យការអភិវឌ្ឍន៍មនុស្ស | | | |
|---|---|---|---|---|
| | HDI | GDI | GEM/a | HPI/a |
| **កម្ពុជា** | ០.៥១៧ | ០.៥១៤ | ០.២៨៣ | ៣៨ |

ប្រភព: UNDP Human Development Report 2000 and calculations from CSES 1999.

/a គណនាពី CSES ១៩៩៧

**របាយថ្នាក់ជាតិនៃការអភិវឌ្ឍន៍មនុស្សនៅកម្ពុជា**

ដូចGDPម្នាក់១ទទួលបានក្នុងមួយឆ្នាំ និងHDI ឬ GDI ដែលទទួលបានជាមធ្យមសំរាប់ប្រទេស អាចបិទបាំងជាសារវន្តនូវភាពមិនស្មើគ្នារបស់មនុស្ស និង ការអភិវឌ្ឍន៍ទំនាក់ទំនងភេទ ក្នុងក្រុមសេដ្ឋកិច្ច និង សង្គម នៅក្នុងប្រទេស។ នេះលេចឡើងសំរាប់ករណីប្រទេសកម្ពុជា ដូចតារាង ២.១៤។ ពិន្ទុនៃទីក្រុងប្រទេសកម្ពុជា គឺប្រមាណ ២១ភាគរយខ្ពស់ជាងពិន្ទុនៃជនបទកម្ពុជា។ ដូចគ្នានេះដែរ ភាពមិនស្មើគ្នាយ៉ាងខ្លាំងទាំង HDI និង GDI នៅក្នុងពួកសេដ្ឋកិច្ច។ អ្នកមានបំផុត ២០ភាគរយ នៃប្រទេសកម្ពុជាមានពិន្ទុ HDI គឺ ៤០ដែលខ្ពស់ជាងអ្នកក្រីក្របំផុត ២០ភាគរយ។

ដូចជាHDI និង GDI និង HPI ផងដែរ ខុសគ្នាយ៉ាងខ្លាំងប្រទះឃើញក្នុងក្រុមសេដ្ឋកិច្ចសង្គម (តារាង ២.១២)។ ដូចដែលបានរំពឹងទុក HPI គឺសំខាន់ណាស់ ក្នុងចំនោមquintileអ្នកក្រីក្របំផុតជាងអ្នកមានបំផុត។

**តារាង ២,១២ កត្តាវិនិច្ឆ័យការអភិវឌ្ឍន៍ធនធានមនុស្ស ការអភិវឌ្ឍន៍យេនឌ័ និង ភាពក្រីក្រ លក្ខណៈជាតិ ជនបទ និង ក្រុង និង តាមរយៈការចំណាយក្នុងម្នាក់ក្នុង១ឆ្នាំ នៅកម្ពុជា១៩៩៩**

| | កត្តាវិនិច្ឆ័យការអភិវឌ្ឍន៍ធនធានមនុស្ស | | |
|---|---|---|---|
| | HDI | GDI | HPI |
| **កម្ពុជា** | ០.៥១៧ | ០.៥១៤ | ៨៣ |
| ជនបទ | ០.៥០០ | ០.៤៨៦ | ៤០.៥២ |
| ក្រុង | ០.៦០៤ | ០.៦០១ | ២៧.៨៨ |
| ក្របំផុត ២០(%) | ០.៤៤៥ | ០.៤៤១ | ៤៤.៨៦ |
| ទីពីរ ២០(%) | ០.៤៧៣ | ០.៤៦៩ | ៤២.១០ |
| ទីបី ២០(%) | ០.៤៩៧ | ០.៤៩១ | ៣៩២៣. |
| ទីបួន ២០(%) | ០.៥៣១ | ០.៥២៥ | ៣៦.០០ |
| មានបំផុត ២០(%) | ០.៦២៣ | ៣.៦២០ | ២៩.០៥ |

**របាយថ្នាក់ខេត្ត និងតំបន់នៃការអភិវឌ្ឍន៍មនុស្សនៅកម្ពុជា**

UNDP បានដកស្រង់ពី CSCS ហើយរាយការណ៍ថា ការទទួលបាន HDI នៃខេត្តត្រូវបានបង្ហាញនៅក្នុងតារាង ២.១៥។ មិនមានអ្វីអោយឆ្ងល់ទេ ភ្នំពេញ(០.៨៦៥) និង ក្រុងព្រះសីហនុ(០.៧៥០)គឺមានពិន្ទុ HDIខ្ពស់បំផុតនៅក្នុងប្រទេស។ ខេត្តព្រៃវែង (០.២៧៧) កំពង់ស្ពឺ (០.២៨០) និង ក្រុងកែប (០.២៥៥)មានពិន្ទុ HDIទាបបំផុត។ តំបន់របៀងទន្លេមេគង្គ (០.៥៥៤) និង តំបន់ឆ្នេរ (០.៥២៧) មានពិន្ទុ HDI ខ្ពស់បំផុត ដែលជាមួយគ្នានេះនៅតំបន់ភ្នំមានពិន្ទុ HDIទាបបំផុត។ តំបន់វាលទំនាប(០.៤៨០ និងតំបន់បឹងទន្លេសាប(០.៤៣៥)មានពិន្ទុ HDIនៅចន្លោះតំបន់របៀងទន្លេ មេគង្គ និង តំបន់ភ្នំ។

តំបន់ផ្សេងៗ និង ខេត្តនៃប្រទេសកម្ពុជាមានពិន្ទុ GDI ខុសៗគ្នា (តារាង ២.១៣)។ ពិន្ទុ GDI ខ្ពស់បំផុតគឺ ០.៦០២ សំរាប់របៀងទន្លេមេគង្គ និង មានពិន្ទុទាបបំផុតគឺ ០.៤៤៨ សំរាប់តំបន់ភ្នំ។

**កត្តាវិនិច្ឆ័យការអភិវឌ្ឍន៍មនុស្សចំពោះកម្ពុជា**(CHDI)

ស្តង់ដា HDI រួមបញ្ចូល៤សមាសភាគៈ ជីវិតដែលអាយុកាលមធ្យម មនុស្សពេញវ័យចេះអាន និង សរសេរ កុមារបានចុះឈ្មោះចូលរៀន និង ការប្រើប្រាស់ចំណាយក្នុង១នាក់ក្នុង១ឆ្នាំ។ ទោះបីយ៉ាងណាក៏ដោយ ប៉ារ៉ាម៉ែត្រជាច្រើនដែលធ្វើអោយមានឥទ្ធិពលទៅលើគុណភាពនៃជីវិតក្នុងសហគមន៍ ទាំងនោះរាប់បញ្ចូល កុមារដែលទទួលអាហារមិនគ្រប់គ្រាន់ និង លទ្ធផលសុខភាព និង សិទ្ធិប្រើប្រាស់សេវាកម្មចាំបាច់ (ឧ. ទឹកស្អាតសំរាប់ផឹក អនាម័យ អគ្គិសនី) សេវាកម្មសុខភាព ផ្ទះសំបែង ការកំសាន្ត និងពត៌មាន។ ប៉ារ៉ាម៉ែត្រទាំងនោះ គឺសំខាន់ណាស់ក្នុងបរិបទនៃប្រទេសក្រីក្រ

ដូចកម្ពុជា។ កត្តាអភិវឌ្ឍន៍មនុស្សចំពោះកម្ពុជា(CHDI) ដោយសរុបជារួមទៅ ភាពខុសគ្នាខាងលើនៃកត្តាសេដ្ឋកិច្ច និងសង្គម។

ដូច្នោះ CHDI គ្របដណ្តប់យ៉ាងធំទូលាយ និង គំរិតសំបូរបែបនៃសង្គម មនុស្ស និង វង្វាស់សេដ្ឋកិច្ច ដែលជាស្តង់ដានៃ HDI ។ ផលប្រយោជន៍ដ៏ចំបងផ្សេងទៀតនៃ CHDI ទៅលើ HDI គឺសមាសភាពទាំងអស់របស់វាគឺកាន់តែស្រួលរកក្រោមឥទ្ធិពលនៃអន្តរាគមន៍ខាងនយោបាយក្នុងពេលដ៏ខ្លី។ HDI ត្រូវបានរិះគន់ពីថ្នាក់ក្រោមដែលសមាសភាពរបស់វា ( មនុស្សពេញវ័យចេះអាន និង សរសេរ និង ជីវិតដែលមានអាយុកាលមធ្យម) គឺមិននៅក្នុងអំណាចច្បាប់នៃអន្តរាគមន៍ អន្តរាគមន៍ខាងនយោបាយក្នុងពេលដ៏ខ្លី។

**តារាង ២,១៣ កត្តាទិនិច្ឆ័យការអភិវឌ្ឍន៍មនុស្ស ការអភិវឌ្ឍន៍ទំនាក់ទំនងយេនឌ័រ តាមតំបន់ និង ខេត្ត នៅកម្ពុជា ១៩៩៦**

| **ខេត្ត/តំបន់** | HDI | GDI | HDI **ពិសេសកម្ពុជា** |
|---|---|---|---|
| ភ្នំពេញ | ០,៨៦៥ | ០,៩១៤ | ០,៩៣៦ |
| កណ្តាល | ០,៤៧៤ | ០,៤៥៧ | ០,៤៥៦ |
| កំពង់ចាម | ០,៤១០ | ០,៤៨៧ | ០,៤៧៥ |
| ស្វាយរៀង | ០,៤០៧ | ០,៤៦៧ | ០,៤២៩ |
| ព្រៃវែង | ០,២៧៧ | ០,៣០៤ | ០,៤១៩ |
| តាកែវ | ០,៤៤៨ | ០,៤៥៣ | ០,៤៣២ |
| ***តំបន់ទំនាប*** | *០,៤៨០* | *០,៥១៣* | *០,៥៣១* |
| កំពង់ធំ | ០,៣១៦ | ០,៤៨៦ | ០,៣៣៦ |
| **សៀមរាប** | ០,៣៤៩ | ០,៣.៦៣ | ០,៣២៥ |
| បន្ទាយមានជ័យ | ០,៤៨៥ | ០,៤០៣ | ០,៤០៩ |
| បាត់ដំបង | ០,៥២១ | ០,៥៣៩ | ០,៤៥៦ |
| ពោធិសាត់ | ០,៤២៨ | ០,៤៧១ | ០,៤០១ |
| កំពង់ឆ្នាំង | ០,៥០២ | ០,៥០៧ | ០,៤៥៣ |
| ***តំបន់បឹងទន្លេសាប*** | *០,៤៣៥* | *០,៤៧៨* | *០,៣៩៦* |
| ក្រុងព្រះសីហនុ | ០,៧៥០ | ០,៦៧៤ | ០,៦៥៩ |
| **កំពត** | ០,៤៨៧ | ០,៥០០ | ០,៤៤៨ |
| កោះកុង | ០,៥៧៨ | ០,៤៩៣ | ០,៣៧៤ |
| ក្រុងកែប | ០,២៩៥ | ០,៣០៩ | ០,៣៧៤ |
| ***តំបន់ឆ្នេរសមុទ្រ*** | *០,៥២៧* | *០,៤៩៤* | *០,៤៦៣* |
| កំពង់ស្ពឺ | ០,២៨០ | ០,៣៩៧ | ០,៤៥៦ |

| | | | |
|---|---|---|---|
| មណ្ឌលគិរី | ០.៣២៩ | ០.៣៧៣ | ០.២១៦ |
| រតនគិរី | ០.៤៤៧ | ០.៥៧៥ | ០.៣៧៥ |
| **តំបន់ខ្ពង់រាប និងភ្នំ** | *០.៣៥២* | *០.៤៤៨* | *០.៣៤៩* |
| ស្ទឹងត្រែង | ០.៤៤០ | ០.៥០៩ | ០.៣៧១ |
| ក្រចេះ | ០.៦៦៨ | ០.៦៩៥ | ០.៥០៦ |
| **តំបន់ទន្លេមេគង្គ** | *០.៥៥៤* | *០.៦០២* | *០.៤៣៨* |
| **កម្ពុជា** | *០.៥១៧* | *០.៥១៤* | *០.៤៣៥* |

ដូច្នេះ CHDI ក៏ដូចជា HDI ដែរ គឺអាចចាត់ថ្នាក់ទាបពី ០ ដល់ខ្ពស់គឺ១ ដែលតំលៃកាន់តែខ្ពស់វាឆ្លុះបញ្ចាំងពីជីវភាពរស់នៅកាន់តែខ្ពស់។

ពេលដែលតំរូវការទិន្នន័យសំរាប់ CHDI កាន់តែសំខាន់ជាងទិន្នន័យសំរាប់ HDI នេះវាមិនអាចគណនាបានឡើយសំរាប់ប្រទេសនិមួយៗនៅក្នុងពិភពលោក។ ទោះបីយ៉ាងនេះក៏ដោយ ការប្រើប្រាស់អង្កេតលើគ្រួសារដោយធ្វើឡើងដោយ CSES ឆ្នាំ ១៩៩៦ អាចយកមកគណនា CHDI បានសំរាប់ប្រទេសនិមួយៗតាមតំបន់ និង តាមខេត្ត។ លទ្ធផលបានកំនត់ថា ចំណាត់ថ្នាក់ខ្ពស់បំផុតសំរាប់៣ ខេត្តមិនមានការប្រែប្រួលទេទោះបីប្រើប្រាស់ស្តង់ដា HDI ឬ CHDI ក៏ដោយ។ រាជធានីភ្នំពេញ ក្រុងព្រះសីហនុ និង ក្រចេះ ចាត់ក្នុងលំដាប់ខេត្តដែលទទួលបានពិន្ទុការអភិវឌ្ឍន៍ខ្ពស់បំផុត ដែលយើងគិតមិនដល់សំរាប់ការប្រើប្រាស់កត្តាវិនិច្ឆ័យ។ ចំណែកខេត្ត ៣ដែលទទួលបានពិន្ទុ HDI ទាបបំផុតនោះគឺ ខេត្តមណ្ឌលគិរី សៀមរាប និង កំពង់ធំ។ មិនមែនក្នុងខេត្តតែ១ ទទួលបានចំណាត់ HDI ទាបបំផុតដូចគ្នាទេ (ដូចជា ខេត្តព្រៃវែង កំពង់ស្ពឺ និងក្រុងកែប)។ មែនហើយបទពិសោធន៍ខេត្តកំពង់ស្ពឺ គឺការផ្លាស់ប្តូរយ៉ាងខ្លាំងតាមលំដាប់ក្នុងការប្រើប្រាស់ CHDI ។ វាធ្លាក់ចុះពីលំដាប់នៃ ៦ លើ HDI ទៅលំដាប់នៃ ២០ លើ CHDI ។

## ៣. ការបែងចែកភូមិសាស្ត្រនៃការប្រើប្រាស់ធនធានក្នុងប្រទេសកម្ពុជា ផ្តោតជាពិសេសទៅលើ ជីវភាពរស់នៅរបស់ជនក្រីក្រ

### ៣.១ មូលដ្ឋានភូមិសាស្ត្រ និង ធនធាននៅកម្ពុជា

វារីធនធានទឹកសាបកម្ពុជា គឺជាអាទិភាពនៃនេសាទទឹកសាប។ នេសាទទឹកសាបគ្របដណ្តប់ប្រព័ន្ធអេកូឡូស៊ី ២ ចំបងរួមមាន: តំបន់ទន្លេសាប (៦០ភាគរយ នៃផលិតផលនេសាទប្រចាំឆ្នាំជាលក្ខណៈពាណិជ្ជកម្មបានបង្ហាញក្នុងស្ថិតិរបស់រដ្ឋាភិបាល) និង តំបន់ព្រៃលិចទឹកមេគង្គ-បាសាក់។ ខេត្តទន្លេសាបមាន: កំពង់ធំ សៀមរាប បន្ទាយមានជ័យ បាត់ដំបង ពោធិសាត់ កំពង់ឆ្នាំង និង ផ្នែកខ្លះនៃកណ្តាលខាងជើងភ្នំពេញ។ តំបន់ព្រៃលិចទឹកមេគង្គ បាសាក់គ្របដណ្តប់ខេត្តកណ្តាលផ្នែកមួយចំនួន ខាងត្បូងភ្នំពេញ កំពង់ចាម ស្វាយរៀង ព្រៃវែង និងតាកែវ។ មានតែ ខេត្តស្វាយរៀងមួយគត់ដែលទីណាក៏ដោយ ការនេសាទអាចដំណើរនៅដែនសាធារណៈ និង មិនមានបង់ពន្ធដារទេ។ ខេត្ត៣ដូចជា សៀមរាប កំពង់ឆ្នាំង និង កណ្តាល ទទួលបាន៥០ភាគរយនៃផលចាប់សរុបទឹកសាប។ ចំពោះប្រព័ន្ធអេកូឡូស៊ីទី៣ មាននៅផ្នែកខាងលើនៃមេគង្គ និង តំបន់ទឹកប៉ែរនៃប្រទេសកម្ពុជា ខេត្តទាំងនោះមាន ក្រចេះ និង ស្ទឹងត្រែង ដែលមិន

សូវសំខាន់ចំពោះការនេសាទទឹកសាបជាលក្ខណៈពាណិជ្ជកម្ម ប៉ុន្តែផ្តល់យ៉ាងសំខាន់ចំពោះការភ្ជាប់អេកូឡូស៊ីនៃប្រភេទធ្វើចរាចរ និង ផ្តល់ការនេសាទសំរាប់ផ្គត់ផ្គង់គ្រួសារនៅតំបន់ក្បែរនេះ។ នាយកដ្ឋានជលផលបានយកចិត្តទុកដាក់យ៉ាងខ្លាំងចំពោះតំបន់ដែលបានរៀបរាប់ខាងលើ (រាប់បញ្ចូលទាំងភ្នំពេញ) ជាផលិតផលពាណិជ្ជកម្មនេសាទទឹកសាប និង មានរបាយការណ៍ផលចាប់ប្រចាំឆ្នាំនៃការនេសាទទឹកសាបពីបណ្តាលខេត្តទាំងនេះ (តារាង៣.១)។

**តារាង ៣.១ របាយផលិតផលនេសាទទឹកសាប តាមខេត្ត**

(ផលនេសាទ តោន)

| ខេត្ត | ១៩៨០ | ១៩៨៥ | ១៩៩០ | ១៩៩៥ | ១៩៩៩ |
|---|---|---|---|---|---|
| **ទំបន់ទន្លេមេគង្គ-បាសាក់)** | | | | | |
| ភ្នំពេញ | ២០០០ | ៤៧៤០ | ៤៦០០ | ៥៩៣៥ | ៥១០៦ |
| ១. កណ្តាល | ១៥០០ | ១០៣៧៥ | ១២៥០០ | ១៣៥៧០ | ១២៣៤៤ |
| ២. កំពង់ចាម | ៣៧០០ | ៤២៨០ | ៥១០០ | ៦៨៥០ | ៤៥០០ |
| ៣. ព្រៃវែង | ១០០០ | ២១៣៨ | ២២៣០ | ៣១០៥ | ២២០០ |
| ៤. តាកែវ | ៦០០ | ១៤៤៧ | ១៥០០ | ១៧៦០ | ១៥០០ |
| **ទំបន់បឹងទន្លេសាប** | | | | | |
| ៥. កំពង់ធំ | ២៥០០ | ២៤៧០ | ៤១០០ | ៤១០០ | ៦០០០ |
| ៦. សៀមរាប | ២០០០ | ៨៤៥០ | ៩០០០ | ៨០០០ | ៧០០០ |
| ៧. បន្ទាយមានជ័យ | - | - | ១៩០ | ១៩២ | ២០០ |
| ៨. បាត់ដំបង | ១៣០០ | ៣៧០០ | ៤៣០០ | ៤៧១២ | ៥២០០ |
| ៩. ពោធិសាត់ | ២៥០០ | ៥៤១០ | ៧២០០ | ៧៨៤៨ | ៧៣០០ |
| ១០. កំពង់ឆ្នាំង | ៣៧០០ | ១០២២០ | ១២០០០ | ១៤៤១៧ | ១៧៩០០ |
| **ទំបន់មេគង្គលើ** | | | | | |
| ១១. ស្ទឹងត្រែង | - | ៦៧០ | ៦៨០ | ៥១៥ | ៧០០ |
| ១៣. ក្រចេះ | ៣០០ | ១៥០០ | ១៣០០ | ១៤៥៦ | ១០៥០ |
| **សរុប** | **១៨៤០០** | **៤៦៤០០** | **៦៩១០០** | **៧២៤០០** | **៧១០០០** |
| **សរុបរួមបញ្ចូលសមុទ្រ** | **១៩៦០០** | **៦៧៤៧៨** | **១០៤០០០** | **១០៣០០០** | **១០៩០០០** |

ប្រភព: នាយកដ្ឋានជលផល ២០០០។ នាយកដ្ឋានជលផល ការប្រមូលទិន្នន័យនេសាទ និងស្ថិតិ ១៩៨០-១៩៩៩

## ៣.២ តួនាទីដ៏សំខាន់នៃនេសាទ ក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ

ការនេសាទនៅប្រទេសកម្ពុជាដើរតួនាទីយ៉ាងសំខាន់ ក្នុងការពង្រឹងសេដ្ឋកិច្ចជាតិ(ECFA,១៩៩២)។ បើគិតទៅលើទិន្នន័យរបស់នាយកដ្ឋានជលផល (១៩៩៩) ក្នុងប្រទេសកម្ពុជា ដោយយកតំលៃបាន់ស្មាន១គីឡូក្រាំថ្លៃ ១.៩៥០ រៀល (១ដុល្លាស្មើនឹង ៣.៨០០រៀល) លោកហៅ ធូក(១៩៩៩) បានរាយការណ៍ថា ការចូលរួមនៃការនេសាទទៅនឹងផលទុនជាតិ គឺ៣១១.៧ កោដិរៀល។ យោងតាមតួលេខថ្មីៗនៃផលទុនជាតិ ១០.៧៥០ កោដិរៀល (ក្រសួងសេដ្ឋកិច្ច

និងហិរញ្ញវត្ថុ, ១៩៩៩) ការនេសាទចូលរួមសរុបក្នុងផលទុនជាតិគឺ ៥.៤ ភាគរយ (តារាង ៣.២)។ ជាមួយនេះ លោក ណៅ ធួក និង ហ្សាលីង (១៩៩៩) និង ហាម៉េត (១៩៩៨) បានប៉ាន់ប្រមាណផលនេសាទទឹកសាបប្រចាំឆ្នាំគឺ ៣០០-៤០០ពាន់តោន និងចូលរួមក្នុងផលទុនជាតិពី ៨.៨ ទៅ១០.៣ ភាគរយ (នៅកន្លែង ឡើងត្រី)។ តំលៃប៉ាន់ប្រមាណដោយក្រសួងផែនការ(១៩៩៥) ក្នុងការគណនាតួនាទីរបស់នេសាទ ក្នុងសេដ្ឋកិច្ចគឺ ១.០ លាន/លានតោន (១ដុល្លាស្មើនឹង ២៥០០) ដូច្នេះការចូលរួមនៃនេសាទក្នុងផលទុនជាតិគឺ ១៤៨.៨ កោដិរៀល។ ជាមួយនឹងផលទុនជាតិ៧.២០០កោដិរៀលរបស់ ជាតិ(១៩៩៥) ការនេសាទចូលរួមក្នុងផលទុនជាតិគឺ ២.១។ ក្នុងឆ្នាំ ១៩៩០ ផលទុនជាតិជាមធ្យមគឺ១.៣៩៦ កោដិរៀល (១.៩៦៥ លានដុល្លា)( ធនាគារពិភពលោក, ១៩៩២)។ អង្គការ FAO(១៩៩៣) ផ្តល់យោបល់ថា ការនេសាទនៅកម្ពុជាចូលរួមប្រមាណ ២.០ភាគរយ នៃផលទុនជាតិ។ ទន្ទឹមនឹងនេះ ការសិក្សានៃមហាវិទ្យាល័យមីស៊ីហ្គេន (១៩៧៦) រកឃើញថា ការនេសាទជាលក្ខណៈពាណិជ្ជកម្ម និង គ្រួសារទូទាំងប្រទេសកម្ពុជាចូលរួម ៣.៥-៤.៥ ភាគរយក្នុងផលទុនជាតិ។

ការចាប់អារម្មណ៍ទៅលើការនេសាទទឹកសាប ផលិតផលនៃឆ្នាំទាំងនោះ ក្នុងស្ថិតិបង្ហាញថា ៧៥.៧០០ លានតោន( នាយកដ្ឋាន.១៩៩៩ )។ ជាមួយគ្នានេះ ផលិតផលពីការនេសាទគ្រួសារ គឺ ២៤.០០០ លានតោន (អង្គការ JICA, ១៩៩៧) ដែលផលនេសាទទឹកសាបសរុបគឺ ៩៩.៧០០ លានតោន និង តំលៃប្រហែល ១៩៤.៤ កោដិរៀល (១ដុល្លាស្មើ ៣.៨០០រៀល)។ ដូច្នោះផលចាប់នេសាទទឹកសាប តែឯងចូលរួមប្រមាណ ១.៨ភាគរយនៃផលទុនជាតិ។ ជាមួយគ្នានេះដែរ លោក ណៅ ធួក និង ស៊ីណា(១៩៩៧) បានប៉ាន់ប្រមាណថា ការចូលរួមពីបឹងទន្លេសាប គឺពី ១.៥ ទៅ ១.៨នៃផលទុនជាតិ។ ទោះយ៉ាងណា វ៉ាន់ហ្សាលីង (១៩៩៧) បានផ្តល់យោបល់ថា ការប៉ាន់ប្រមាណដោយប្រហាក់ប្រហែលផលិតផលនេសាទទឹកសាបសរុបក្នុងប្រទេសកម្ពុជា គឺមាននៅក្នុងចន្លោះ ៣០០-៤៥០ ពាន់តោនក្នុងមួយឆ្នាំ ជាមួយនឹងតំលៃនៅកន្លែងឡើងត្រី ពី ១០០-២២៥ លានដុល្លា និង បង្កើនដល់ ២៥០-៥០០លានដុល្លា បើគិតមាន ទីផ្សារ។ ជាមួយនឹងតំលៃនេះ ការនេសាទទឹកសាបចូលរួមយ៉ាងខ្លាំង ប្រែប្រួលពី ៣.២-៤.៩ ភាគរយ នៅកន្លែងឡើងត្រីនិងកើនដល់ ៨.៨-១៧.៦ តាមទីផ្សារទៅនឹងផលទុនជាតិ( ណៅ ធួក និង សូណាម, ១៩៩៩)។

តារាង ៣.២ បង្ហាញថា ភាពក្រីក្រនៅជនបទនៃប្រទេសកម្ពុជា ធ្វើការនេសាទ និង ទាក់ទងទៅនឹងសកម្មភាពនេសាទ មានចំនួនសរុប ២៤.០៨០ នាក់ ក្នុងឆ្នាំ ១៩៨២ និង កើនដល់ ១៣០.២២១ នាក់ក្នុងឆ្នាំ ១៩៩៨។ នេះបង្ហាញថា សារៈសំខាន់នៃនេសាទក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ និង ក្នុងការផ្តល់ការងារដល់ជនបទក្រីក្រ។ ផ្នែកបន្តទៅទៀតនឹងពិភាក្សាពីការចូលរួមនៃនេសាទក្នុងសន្តិសុខស្បៀងនៃប្រទេសកម្ពុជា ការផ្តល់ប្រូតេអ៊ីនក្នុងចំណីអាហារ និង ការប្រើប្រាស់ត្រីក្នុង១នាក់ក្នុង១ឆ្នាំ។

## ៣.៣ សារៈសំខាន់នៃត្រី ផលិតផលត្រី និង ជីវភាពរស់នៅតាមជនបទនៃប្រទេសកម្ពុជា

កម្ពុជាគឺជាប្រទេសមួយប្រកបទៅដោយព្រៃឈើ ទន្លេ បឹងបួរ និង វាលស្រែ។ ការប្រកបរបរកសិកម្ម ការនេសាទត្រី និង ការទាញយកប្រយោជន៍ពីផលិតផលព្រៃឈើ គឺជាមធ្យោបាយដ៏ចំបាច់ដើម្បីបង្កើតម្ហូបអាហារ សំភារៈថាមពល និង ចំណូលបន្ថែមសំរាប់ទ្រទ្រង់ការរស់នៅតាំងពីយូរអង្វែងមកហើយ។

ត្រី និង ផលិតផលត្រីដើរតួនាទីយ៉ាងសំខាន់ក្នុងសន្តិសុខស្បៀង ជាប្រភពផ្តល់ចំណីអាហារ ប្រាប់ចំណូលក្នុងគ្រួសារ និង ជួយគ្រាំទ្រជីវិភាពរស់នៅនៅជនបទកម្ពុជា។ ការប៉ាន់ប្រមាណទំនាក់ទំនងចំណីអាហារនៃត្រីដ៏ចំបងនៅកម្ពុជាដែលទទួលបានមានការប្រែប្រួល។ ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមលើកដំបូង (RGC)(១៩៩៦-២០០០) បានគត់សំគាល់ថា ត្រីនិងផលិតផលត្រូវបានជឿថា បានផ្តល់ប្រូតេអ៊ីនដល់ប្រជាជនក្រីក្រជាមធ្យមគឺ ៤០-៦០ភាគរយ (ហ្គាម, ១៩៩៧)។ ទោះបីយ៉ាងនេះក៏ដោយ នៅក្នុងតំបន់ខ្លះ (ឧ. ក្នុងភូមិ នៅក្បែរដែននេសាទទឹកសាប និង តាមតំបន់ឆ្នេរ) មានទំនាក់ទំនងដ៏សំខាន់ជាមួយត្រី ជាប្រភពនៃប្រូតេអ៊ីនខ្ពស់ជាងតំបន់ផ្សេងទៀត (ប្រមាណ ៧០-៧៥ភាគរយ)( ឪហ្គិន, ២០០០ ណៅ ធូក និង សូណាម, ១៩៩៩ ហាមេត, ១៩៩៨, ណៅ ធូក និង ស៊ីណា, ១៩៩៧ ក្រសួងបរិស្ថាន, ១៩៩៦ និង ហ្សាម និង ហាមេត, ១៩៩៦។ ភាគច្រើននៃប្រជាជន តុល្យភាពនៃប្រូតេអ៊ីនបានមកពីការប្រើប្រាស់សត្វតូចៗ ជាពិសេសបសុបក្សី និង ជ្រូក គ្រួសារជនបទភាគច្រើនរក្សាទុកទាំង២សំរាប់ជាអាហារផង និង លក់ដូរផង ជាប្រភពចំណូលបន្ថែម។

ការប្រើប្រាស់ត្រី គឺខ្ពស់ ជាប្រពៃណីទៅហើយនៅកម្ពុជាមានកំរិតពី ២០-២៥គីឡូក្រាមក្នុង១ម្នាក់ក្នុង១ឆ្នាំ ក្នុងឆ្នាំ ១៩៩៧ (ឡាកហ្គី, ១៩៧៦) ប៉ុន្តែបានធ្លាក់ចុះយ៉ាងខ្លាំងមកត្រឹម ១៣.៣-១៦ គីឡូក្រាមក្នុង១ម្នាក់ក្នុង១ឆ្នាំ ក្នុងឆ្នាំ ១៩៩០ (MS. ១៩៩២)តាមរយៈការប៉ាន់ប្រមាណផ្សេងៗ នេះប្រហែលជាការបំផ្លិចបំផ្លាញបរិស្ថាន កំនើនប្រជាជន (អត្រាកំនើនប្រចាំ ២.៥-៣ភាគរយ)(ធនាគារពិភពលោក, ១៩៩២។ ការពិនិត្យឡើងវិញនៃផ្នែកនេសាទ (MS. ១៩៩២) ប៉ាន់ប្រមាណថាការផ្គត់ផ្គង់ធ្លាក់ចុះរយៈពេលខ្លីនៃតំរូវការសំរាប់ ៧៧.០០០ លានតោនប្រចាំឆ្នាំ។ ផលនេសាទទឹកសាបគឺបានចាត់ទុករួចទៅហើយថា ខិតជិតទៅទិន្នផលអតិបរិមា ហើយការកើនឡើងនៃផលិតផលត្រី គឺបានមកពីផ្នែកវារីវប្បកម្មទៅតាមទំហំនៃការងារផ្សព្វផ្សាយ ឬ បានមកពីការនេសាទសមុទ្រ។

**តារាង ៣,២ ផលិតផលពាណិជ្ជកម្ម និង វារីវប្បកម្ម (តោន)នៃប្រទេសកម្ពុជា**

**១៩៨២-១៩៩៨**

| ឆ្នាំ | សរុប | ទឹកសាប | សមុទ្រ | វារីវប្បកម្ម | តំលៃ (លានដុល្លា) | ភាគរយ នៃGDP | ប្រជាជន បំរើការ |
|---|---|---|---|---|---|---|---|
| ១៩៨២ | ៦៨.៧១៩ | ៦៥.៧០០ | ៣.០១៩ | - | ៦២.២ | nd | ២៤.០៨០ |
| ១៩៨៣ | ៦៨.១៦១ | ៥៨.៧១៧ | ៩.៤៤៤ | - | ៧៧.៥ | nd | ៥.៣១៩ |
| ១៩៨៤ | ៦៤.៤២៤ | ៥៥.០៩៣ | ៧.៧២១ | ១.៦១០ | ៧០.៦ | nd | ២៦.០៧៨ |
| ១៩៨៥ | ៧០.៥៧៨ | ៥៦.៤០០ | ១១.១៧៨ | ៣.០០០ | ៨៤.៣ | nd | ៣.០៦៩ |
| ១៩៨៦ | ៧៣.៦២៨ | ៦៤.១៨១ | ៧.២៤៧ | ២.២០០ | ៧៦.៩ | nd | ៣១.៧៦៤ |
| ១៩៨៧ | ៨២.០៧១ | ៦២.១៥៤ | ១៧.៤១៧ | ២.៥០០ | ១០៨.៧ | nd | ៤២.៥៨២ |
| ១៩៨៨ | ៨៦.៨០០ | ៦១.២០០ | ២.១០០ | ៤.៦០០ | ១២១.៧ | nd | ៤២.៤៩៩ |
| ១៩៨៩ | ៨២.០៨៨ | ៥០.៥០០ | ២៦.០៥០ | ៥.៥៣៨ | ១៣០.៥ | nd | ៤៣.៤៥៦ |
| ១៩៩០ | ១១១.១៥០ | ៦៥.១០០ | ៣៩.៥០០ | ៦.៤០០ | ១៨៧.៩ | ៩.៧ | ៤៨.៦៩៧ |
| ១៩៩១ | ១១៧.៨០០ | ៧៤.៧០០ | ៣៦.៤០០ | ៦.៧០០ | ១៦៥.២ | ៩.២ | ៥០.០៧០ |
| ១៩៩២ | ១១១.១៥០ | ៦៨.៥០០ | ៣៣.៧០០ | ៨.៩៥០ | ១៥៥.១ | ៧.៥ | ៧៣.៦២២ |
| ១៩៩៣ | ១០៨.៥០០ | ៦៧.៥០០ | ៣៣.១០០ | ៧.៥០០ | ១៥១.៩ | ៧.៩ | ៨៩.១២០ |
| ១៩៩៤ | ១០៣.២០០ | ៦៥.០០០ | ៣០.០០០ | ៨.២០០ | ១៤០.៦ | ៥.៩ | ៩២.២៥១ |
| ១៩៩៥ | ១១២.៥១០ | ៧២.៥០០ | ៣០.៥០០ | ៩.៥១០ | ១៤៧.៦ | ៥.១ | ១០៤.៥៧១ |
| ១៩៩៦ | ១០៤.៣១០ | ៦៣.៥១០ | ៣១.២០០ | ៩.៦០០ | ១៣៨.៩ | ៤.៥ | ៩៩.៨៣៦ |
| ១៩៩៧ | ១១៤.៦០០ | ៧៣.០០០ | ២៩.៨០០ | ១១.៨០០ | ១៤០.៨ | ៤.៦ | ៩២.៨១៧ |
| ១៩៩៨ | ១២២.០០០ | ៧៥.៧០០ | ៣២.២០០ | ១៤.១០០ | ១៥២.១ | ៥.៤ | ១១.៣០០ |
| ១៩៩៩ + | ៣១០.០០០ | ២៥៥.០០០ | ៣៥.០០០ | ២០.០០០ | ១៧១.១ | ៥.២ | ១៣០.២២១ |
| ការប៉ាន់ប្រមាណ | | | | | | | |
| ២០០០ + | ៣២៥.០០០ | ២៥៥.០០០ | ៤៥.០០០ | ២៥.០០០ | ២០៨.៧ | ៥.៥ | ៤.៦៩០ |
| គំរោងការ | | | | | | | |
| មធ្យម | | | | | | | |
| ១៩៨៤-១៩៩០ | ៨១.៥៧០ | ២៩.២២៣ | ១៨.៦៤៥ | ៣.៦៩៣ | ១១១.៥ | ៩.៧ | ៥.២៨៧ |
| ភាគរយ | ១០០ | ៧២.៦ | ២២.៩ | ៤.៥ | | | |
| មធ្យម | | | | | | | |
| ១៩៩១-១៩៩៨ | ១១៨.៩៤៧ | ៧៣.១២១ | ៣៣.៦៩០ | ១២.១៣៦ | ១៤៦.៧ | ៦.១ | |
| ភាគរយ | ១០០ | ៦១.៤ | ២៨.៣ | ១០.២ | | | |

ប្រភព: នាយកដ្ឋានជលផល ២០០០ ។ នាយកដ្ឋានជលផល ការប្រមូលទិន្នន័យនេសាទ និងស្ថិតិ ១៩៨០-១៩៩៩

ណៅ ចូក និង សូណាម (១៩៩៩) និង នាយកដ្ឋាន(២០០០) បានរាយការណ៍ថា អត្រាថ្នាក់ជាតិនៃការប្រើប្រាស់ត្រីក្នុង ១នាក់ក្នុង១ឆ្នាំ គឺ ២០-៣០គីឡូក្រាមក្នុង១ឆ្នាំ។ ទោះបីយ៉ាងនេះក៏ដោយ ការប្រើប្រាស់ត្រីក្នុង ១នាក់ក្នុង១ឆ្នាំ សំរាប់កម្ពុជាបានធ្វើការប៉ាន់ប្រមាណផ្សេងៗគ្នា (តារាង៣,៣) គឺ ២៥គីឡូក្រាម (តាណា, ១៩៩៣)នៅប៉ែកអាគ្នេយ៍ប្រទេសកម្ពុជា ១៣,៥គីឡូក្រាម (ហ្សាវ៉ាស, ១៩៩៤) ៤០គីឡូក្រាម ( CIAPមិនបោះពុម្ព) នៅប៉ែកខាងត្បូង និង ៣៨គីឡូក្រាម(អង្គការ APHEDA,១៩៩៧)នៅប៉ែកខាងនិរតីប្រទេស។ ការចូលរួមគ្រប់គ្រងប្រភពធនធានធម្មជាតិ ក្នុងតំបន់បឹងទន្លេសាបរបស់អង្គការ FAO ប៉ាន់ប្រមាណគឺ ៧១គីឡូក្រាម /ម្នាក់១ឆ្នាំ នៅភូមិបណ្តែតទឹក និង ៣២គីឡូក្រាម/ម្នាក់១ឆ្នាំ នៅតំបន់ខាងលើ នៃខេត្តសៀមរាប(ហ៊ុ, ១៩៩៥)។ ជាមួយនេះដែរគ្រោងការគ្រប់គ្រង នេសាទទឹកសាប ដាណីដា/នាយកដ្ឋានជលផល/គណៈកម្មការទន្លេមេគង្គ(១៩៩៥) បានយកគំរូ ៨៣ឃុំ ដែលជាឃុំពឹង ផ្អែកលើ ការនេសាទ(៥១១៧បញ្ជីសំនួរ) ដែលអាចដំណាងអោយប្រជាជនសរុប ជាង២លាននាក់ បានបង្ហាញថាជាមធ្យម ប្រើប្រាស់ត្រីគឺ ៧៦,៨គីឡូក្រាម/ម្នាក់ឆ្នាំ។ ផ្អែកលើការប្រើប្រាស់ប្រចាំសប្តាហ៍ ការប្រើប្រាស់ក្នុងម្នាក់ត្រីស្រស់ (៤៣,៥គីឡូក្រាម/ឆ្នាំ) និងផលិតផលកែច្នៃ(២៧,៥គីឡូក្រាម/ឆ្នាំ គិតបញ្ចូលទាំង ទឹកត្រី) ក្នុងចំណោម ៧១គីឡូក្រាម per annum(ហាមេត, ១៩៩៨)។ ប្រសិនបើគិតបញ្ចូលទឹកត្រី ការប្រើប្រាស់ ត្រីក្នុងម្នាក់ក្នុង១ឆ្នាំ (ស្រស់ និង ស្មើនឹងស្រស់នៃការកែច្នៃ) នឹងកើនឡើងដល់ ៧៥,៦គីឡូក្រាម។ ចំពោះគ្រួសារនេសាទ ការប្រើប្រាស់ត្រីក្នុងម្នាក់ក្នុង ១ឆ្នាំ គឺប្រហែល ៨០គីឡូក្រាម per annum ប្រៀបធៀបទៅប្រហែល ៧៦គីឡូក្រាម សំរាប់គ្រួសារដែលមិនធ្វើនេសាទ។ ការសិក្សារបស់ គ្រេហ្គ៉ូរី (១៩៩៧) ក្នុងរយពេល៨ខែក្នុងភូមិចំនួន៣ នៅខេត្តស្វាយរៀង ដែលជាខេត្តក្បែតប្រភពនេសាទ បានរាយការណ៍ថា ការប្រើប្រាស់ត្រីគឺ ២១,៥គីឡូក្រាម/caput/ឆ្នាំ ៣៣,៨គីឡូក្រាម/caput/ ឆ្នាំ និង ៣៩,៥គីឡូក្រាម/ caput/ ឆ្នាំ នៅភូមិសាមគ្គី ថ្លល់កែង និង ថ្លុកព្រីង តាមលំដាប់លំដោយ។ មានភ្នាក់ងារអង្គការជាតិ និងអន្តរជាតិជាច្រើន បានប្រឹងប្រែងយ៉ាងពេញទំហឹង ហើយផ្តល់ថវិកាដើម្បីទទួលបានពត៌មាន ដែលអាចយកជាបានស្តីពីការប្រើប្រាស់នៅគ្រប់ តំបន់ក្នុងប្រទេសកម្ពុជា។ ទាំងនេះបង្ហាញថាតំលៃរបស់ត្រី និង ផលដែលបានមកពីទឹកផ្សេងៗទៀត គឺជាប្រភពដំបូង នៃប្រូតេអ៊ីនសត្វ និង ជាចំណីអាហារសំរាប់ប្រជាជនក្រីក្រនៅជនបទកម្ពុជា និង មានសារៈសំខាន់ណាស់ក្នុង សន្តិសុខស្បៀងរបស់ជាតិ ក៏ដូចជាធ្វើអោយសេដ្ឋកិច្ចល្អប្រសើរ។

**តារាង ៣,៣ របាយនៃការប្រើប្រាស់ត្រីក្នុងម្នាក់ក្នុង១ឆ្នាំ តាមតំបន់នានានៃកម្ពុជា**

| តំបន់ | ការប្រើប្រាស់ត្រីក្នុងម្នាក់ (គីឡូក្រាមក្នុងម្នាក់១ឆ្នាំ) | អ្នកនិពន្ធ |
|---|---|---|
| កម្ពុជា | ២០-៣០ | នាយកដ្ឋានជលផល, ២០០០ |
| ណោម | | |
| | | និង ណៅ ចូក, ១៩៩៩ |
| កម្ពុជា | ២៣-៣១ | សូណាម និង ណៅ ចូក, |

| | | |
|---|---|---|
| ១៩៩៩ | | |
| បឹងទន្លេសាប ( ត្រឹមតែសៀមរាប) | ៣២ | ហ៊ុ. ១៩៩៥ |
| បឹងទន្លេសាប ( ៦ ខេត្ត) | ៧១ | FAO/PNRM, ១៩៩៥ |
| បឹងទន្លេសាប ( ៨ ខេត្ត) | ៨៦.៨ | នាយកដ្ឋានជលផល/PNRM,១៩៩៥ |
| បឹងទន្លេសាប | ៧១ | ហាមេត, ១៩៩៨ |
| ( រួមបញ្ចូលកណ្តាល និងភ្នំពេញ) | | |
| ខាងកើត-ត្បូង( ស្វាយរៀង) | ២៥ | ឥាណា, ១៩៩៣ |
| ខាងកើត-ត្បូង( ស្វាយរៀង) | ២១.៥-៣៩.៥ | Gregory, ១៩៩៧ |
| ខាងលិច-ត្បូង( កំពត) | ៣៨ | APHEDA,១៩៩៧ |
| ខាងត្បូង( កណ្តាល និងតាកែវ) | ៣៨ | CIAP,មិនទាន់បោះពុម្ព |

ទោះយ៉ាងនេះក៏ដោយ ជាមួយនឹងការប៉ាន់ប្រមាណផលនេសាទទឹកសាបបច្ចុប្បន្ននេះ គឺ ៣០០-៤០០ ពាន់តោន (គណៈ កម្មការទន្លេមេគង្គ/នាយកដ្ឋានជលផល, ១៩៩៨/១៩៩៩) និងចំនួនប្រជាជន១១.៤ លាន នេះការប្រើប្រាស់ត្រីប្រចាំឆ្នាំ ក្នុង១ អាចប៉ាន់ប្រមាណប្រហែល ២៣-៣១ គីឡូក្រាម ( ណៅ ធូក និងសូណាម, ១៩៩៩)។ នេះមិនទាន់គិតបញ្ចូលការ ប្រើប្រាស់ត្រីក្នុង១នាក់ក្នុង១ឆ្នាំ ដែលបានមកពីវារីវប្បកម្មមានប្រហែល ១.២ គីឡូក្រាម។ ប្រៀបធៀបទៅនឹងការ ប្រើប្រាស់ប្រូតេអ៊ីន ដែលបានមកពីប្រភពផ្សេងៗគ្នា ដូចជា សាច់គោ (៣.៣គ.ក) សាច់ជ្រូក (៨.៥គ.ក) និង សាច់មាន់ (២.៨គ.ក) នោះប្រូតេអ៊ីនដែលបានមកពីសាច់ត្រីគឺសំខាន់ជាងមកពីប្រភពផ្សេងៗ (អង្គការស្បៀងពិភពលោក, ១៩៩៣)។ ជាងនេះទៅទៀត វាអាចប្រដូចទៅនឹងប្រទេសអាស៊ីអាគ្នេយ៍ផ្សេងៗទៀត។

ហាមេត(១៩៩៨)បានរាយការណ៍ថា ដំណាំស្រូវគ្របដណ្តប់ ៩០ភាគរយ នៃដីដំដុះសរុប ១.៨៤៤ លាន ហិកតា) និងផ្តល់ ៥៧ភាគរយ នៃកាឡូរីសរុប។ ស្រូវពឹងផ្អែកលើទឹកភ្លៀង មាន ៧៧ភាគរយ នៃផ្ទៃដីដាំដំណាំ និង ផលិត ៦៧ភាគរយនៃ ផលិតផលស្រូវប្រចាំឆ្នាំ។ ៨៤ភាគរយនៃកសិករដាំដុះលើដីពី ១-៥ហិកតា( អូវ៉ែរស៊ុន, ១៩៩៦)។ ស្រូវ និងត្រីគឺម្ហូប អាហារដែលសំខាន់ជាងគេ សំរាប់ប្រជាជនកម្ពុជា ជាពិសេស ៨០-៨៥ភាគរយ សំរាប់ប្រជាជនក្រីក្រតាមជនបទ (អង្គការ Oxfam GB២០០០, វីសលីយ៉ាំ ១៩៩៩, ហ្គាតមែន ១៩៩៩, ធូក និងឌីកហ្គិន, ១៩៩៨)។ អ្នកសិក្សាស្រាវជ្រាវជាច្រើន បានផ្តល់យោបល់ថា វារីធនធាន(ជាចំបងត្រី) បានគាំទ្រជីវភាព រស់នៅតាមជនបទ ត្រូវបានប៉ាន់ប្រមាណទាប ឬក្រឡេកមើលខ្ពស់ពេក (ហ្គាំ, ២០០០) ។ ហ្គេគូរី (១៩៩៧), ហ្គេគូរីនិងហ្គាតមែន ១៩៩៩ និងហ្គាតមែន ១៩៩៩ បានកំនត់បង្ហាញថា នេះជាការគត់សំគាល់នូវភាព សំខាន់នៃ ប្រព័ន្ធអេកូឡូស៊ីវាលស្រែ សំរាប់ការប្រើប្រាស់ទ្រព្យសម្បត្តិរួម ដូចជា ជលផល និង រុក្ខាប្រមាញ់ ( ណូម៉ា និង អាមេត, ១៩៩៦) និងសំរាប់ ការនេសាទជាទូទៅ(ឌីកហ្គិន, ២០០០, ផលសុវណ្ណ, ១៩៩៩, ធូក និងវ៉ាន់ហ្សាលីង, ១៩៩៩)។ អង្គការ Oxfam បានរាយការថា សកម្មភាពជីវភាពជា ចំបងនៃជីវភាពរស់នៅ ក្នុងតំបន់សិក្សា(៤ភូមិ ក្នុងខេត្តបាត់ដំបង) គឺការធ្វើស្រែ និងចំការ និងនេសាទត្រី (ការប្រមូលវារី ធនធានដទៃទៀត)។ វារីធនធានទាំងនេះ មិនត្រឹមតែផ្តល់ ប្រភពចំណីអាហារប៉ុណ្ណោះទេ វាក៏ជាប្រភពដ៏សំខាន់រកចំណូលប្រាក់កាក់ផងដែរ។ ការប្រើប្រាស់វារីធនធាន(ជាពិសេសត្រី)គឺសំខាន់ណាស់ក្នុងសកម្មភាព

រស់នៅ សំរាប់គ្រួសារទាំងអស់ នៅក្នុងតំបន់ដែលបានសិក្សា និង សំរាប់ប្រជាជនដែលគ្មានដីធ្លី ជាតំណាងអោយប្រភពនៃការរកចំណូល ។

វាលស្រែ និងទំនាបលិចទឹករបស់ប្រទេសកម្ពុជា នៅតែផលិតជាសំខាន់នូវចំណោមផលិតផលដែលបានពីទឹក ដូចជា ត្រី កំពីស កង្កែប ក្តាម និង ខ្យង ។ វាមានសារៈសំខាន់ជាសារវន្ត ចំពោះការផ្តល់ម្ហូបអាហារក្នុងស្រុក ប្រភពចំណូល និង ការចិញ្ចឹមជីវិតរបស់គ្រួសារកសិករ ។ ការប្រមូលបន្លែដែលដុះស្រាប់ និងការចាប់ត្រី ពីតំបន់ទំនាបលិចទឹក និង វាលស្រែ ជាសំខាន់ណាស់ជាគ្រឿងជំនួយទៅនឹងការផ្តល់អាហារប្រចាំឆ្នាំ និង ជាចំណូលនៅទីណាដែលការដាំដុះបរាជ័យ ដែលជា បាតុភូតធម្មតាមួយ ។ (អាមេត. ១៩៩៨, អូវ៉ារស៊ុន ១៩៩៦) ។

ប្រភេទអេកូឡូស៊ីទឹកផ្សេងទៀត មានព្រៃលិចទឹក ដែលមានតួនាទីសំខាន់ផងដែរ ក្នុងផលិតផលម្ហូបអាហារគ្រួសារ និង ប្រព័ន្ធប្រាក់ចំណូល ។ ទោះបីមានការទន្ទ្រានយក និងកាប់បំផ្លាញ ប្រទេសកម្ពុជានៅមាន ប្រហែល ៧០០ពាន់ហិកតា នូវតំបន់ព្រៃលិចទឹកទាំងនោះ ។ ការប្រើប្រាស់ព្រៃលិចទឹកជាធម្មតានោះគឺ កាប់ធ្វើធ្យូង អុសសំរាប់ដុត ទន្ទ្រានធ្វើកសិកម្ម ដុតចាប់សត្វ ធ្វើទីជំរក ជាឧបករណ៍នេសាទនានា និង សំភារៈសំណង់ផ្សេងៗ ។ ជាងនេះទៅទៀត ព្រៃលិចទឹកទាំងនោះ អាចធ្វើជាថ្នាំពេទ្យ ផលិតផលទឹកឃ្មុំ ថ្នាំជ្រលក់ពណ៌ និង ជ័រ ។ សត្វព្រៃទាំងឡាយរួមមាន ក្រពើ ពស់ អណ្តើក កង្កែប និង បក្សីបក្សាទឹក ដែលរស់នៅក្នុងព្រៃលិចទឹក ។ ពួកគេប្រមាញ់មិនរើសមុខសំរាប់ធ្វើអាហារ ជួញដូរ និងផលិតផល ផ្សេងៗ ។

## ៣.៤ របាយភូមិសាស្ត្រនៃធនធាន ដែលប្រើប្រាស់ក្នុងកម្ពុជា សង្កត់ទៅលើការប្រើប្រាស់ដោយប្រជាជនក្រីក្រ

ការប្រើប្រាស់ធនធានប្រកបទៅដោយនិរន្តរភាព( កានេសាទជាអាទិភាព) និង បរិស្ថានរបស់ពួកគេ គឺជាការ ដាក់ លក្ខខណ្ឌចាំបាច់ជាមុន សំរាប់ការបន្តផ្គត់ផ្គង់ត្រី និង ជីវភាពរស់នៅដល់ប្រជាជនជនបទក្រីក្រ ។ ជាសម្បត្តិធនធានរបស់ជាតិ ការអន្តរាគមន៍របស់មនុស្ស គឺខ្លាំងក្លាណាស់ក្នុងការថែទាំ នូវការនេសាទប្រកបដោយនិរន្តរភាព សំរាប់ប្រទេស កម្ពុជា ។

អ្នកនិពន្ធជាច្រើនបានសរសេរឡើងវិញ នូវការគ្រប់គ្រងនេសាទទឹកសាបកម្ពុជា (ឌីកហ្គេន. ២០០០ ហ្គាម. ២០០០ អង្គការ Oxfam GB. ២០០០ លីវុទ្ធី. ១៩៩៩ ធូក និងស៊ុណា. ១៩៩៧) ។ នាយកដ្ឋានជលផល ដែលស្ថិតនៅក្រោមក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានអាណត្តិរបស់ខ្លួន ក្នុងការគ្រប់គ្រងនេសាទ និង ធនធាននៅក្នុងប្រទេស កម្ពុជា ។ ច្បាប់ជលផលស្តីពី "ការគ្រប់គ្រងនេសាទ និងកិច្ចការរដ្ឋបាល " បានចេញប្រើប្រាស់នៅថ្ងៃ ៩ ខែ មិនា ឆ្នាំ ១៩៨៧ ។ ច្បាប់នេះបានបែងចែងផ្ទៃទឹកទាំងអស់ជា ប្រភេទចិន្ត្រៃយ៍ និង អចិន្ត្រៃយ៍ ដែលរាប់បញ្ចូលទាំងប្រភេទព្រៃលិច ទឹក ជាដែននេសាទ ។ តាណោ (១៩៩០)បានកំនត់ថា នៅក្នុងដែននេសាទ រាល់វារីសត្វ និងរុក្ខជាតិទាំងឡាយ ដែលបង្ក បង្កើតនៅទីនោះ ចាត់ទុកថាជាសម្បត្តិរបស់រដ្ឋ ។ យោលទៅតាមច្បាប់ ដែននេសាទ ត្រូវបានចែកចេញជា ដែននេសាទឡូត៍ ដោយពូក និង ដែននេសាទដែលត្រូវការពារ ។ ការកំនត់ប្រភេទនិមួយ និងព្រំប្រទល់ពិតប្រាកដនៃតំបន់ទាំងនេះ គឺកំនត់ដោយប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (តាណោ. ១៩៩០) ។

ដែននេសាទដែលឡូត៍ដោយពូកមាន:

- តំបន់ដែលកំនត់ជាឡូត៍នេសាទ (ផ្តល់សិទ្ធិផ្តាច់មុខ) សំរាប់ធ្វើអាជីវកម្មពាណិជ្ជកម្ម

- តំបន់ដែលកំនត់ជាកន្លែងបំរុងទុក។ កន្លែងទាំងនោះ រក្សាទុកសំរាប់ត្រីបន្តពូជ ទាំងរដូវប្រាំងនិងវស្សា ដែលជាកន្លែងដែលមានជំរៅជ្រៅជាងគេ នៅក្នុងដែននេសាទ និងសំរាប់ការស្រាវជ្រាវវិទ្យាសាស្ត្រ។ កន្លែងបំរុងទុកទាំងនេះមាន ១៣ នៅកន្លែងទូទៅប្រទេស ក្នុងនោះ ៨ កន្លែងនៅក្នុងបឹងទន្លេសាប (នាយកដ្ឋានជលផល. ១៩៩០)។

-តំបន់ដែលកំនត់ជានាទីព្រៃលិចទឹក។ តំបន់នោះរួមមានព្រៃដែលលិចទឹកតាមរដូវកាល នៃមូសុង និងមានសារៈសំខាន់ណាស់ជាជំរកសំរាប់ត្រីពងកូន និងស្វែងរកចំណី( ច្បាប់ជលផល. ១៩៨៧)។ វាត្រូវបានប៉ាន់ប្រមាណថា ៨៥ភាគរយ នៃព្រៃលិចទឹកទឹកសាបនៅសល់ គឺនៅជុំវិញបឹងទន្លេសាប ( AWB , ១៩៩៣ ហ្គាម. ១៩៩៨)។ នេះរាប់បញ្ចូលទាំងតំបន់ព្រៃលិចទឹក ដែលនៅក្នុងឡូត៍នេសាទ ( ឌីកហ្គេន និង ធូក. ១៩៩៨)។

ដែននេសាទដែលត្រូវការពារ ជាតំបន់នេសាទ ក្រៅអំពីដែននេសាទដែលរៀបដោយពួក។ ការនេសាទគឺកំនត់ដោយចែកជា ទៅតាមប្រភេទឧបករណ៍នេសាទ ជាលក្ខណៈគ្រួសារឬទ្រង់ទ្រាយតូច និងលក្ខណៈសិប្បកម្ម។ ទាំងឧបករណ៍ នេសាទសិប្បកម្មក៏ដូចជាឧស្សាហកម្ម (ឡូត៍នេសាទ/ដាយត្រី) គឺបានអនុញ្ញាតិអោយធ្វើ តែក្នុងរដូវបើកនេសាទប៉ុណ្ណោះ លើកលែងតែឧបករណ៍នេសាទជាលក្ខណៈគ្រួសារទេ ដែលអាចនេសាទបានពេញមួយឆ្នាំ (តាន់. ១៩៧១ ពាណា. ១៩៩៦)។ រដូវបើកនេសាទមានដូចតទៅនេះ:

- ពីថ្ងៃទី ១ ខែ តុលា ដល់ ថ្ងៃទី ៣០ ខែ ឧសភា សំរាប់តំបន់ដែលស្ថិតនៅ ខាងជើងខ្សែស្របទន្លេចតុមុខ។
- ពីថ្ងៃទី ១ ខែ វិច្ឆិកា ដល់ ថ្ងៃទី ៣០ ខែ មិថុនា សំរាប់តំបន់ដែលស្ថិតនៅ ខាងត្បូងខ្សែស្របទន្លេចតុមុខ។

ប្រព័ន្ធគ្រប់គ្រងការនេសាទគឺផ្អែកលើលក្ខណៈនៃការនេសាទ ដូចជាការនេសាទជាលក្ខណៈគ្រួសារ លក្ខណៈសិប្បកម្ម និង លក្ខណៈឧស្សាហកម្ម ដែលកំនត់ដោយប្រកាស។ លក្ខណៈនៃការបែងចែកនៃឧបករណ៍និមួយៗគឺអាស្រ័យទៅតាម ទំហំរបស់ឧបករណ៍ និងវិធីសាស្ត្រនៃការនេសាទ និងសមត្ថភាពចាប់របស់ឧបករណ៍។

### ៣.៤.១ នេសាទលក្ខណៈទ្រង់ទ្រាយធំ ឬឧស្សាហកម្ម

សំរាប់ការនេសាទទ្រង់ទ្រាយធំ ជាតំបន់ដែលត្រូវបានផ្តល់សិទ្ធិផ្តាច់មុខ ដោយកំនត់តំបន់ភូមិសាស្ត្រ (ឡូត៍/ដាយ)។ ទំហំនៃឡូត៍នេសាទ មានពី ២០ គីឡូម៉ែត្រការេ ទៅ ៣៥០ គីឡូម៉ែត្រការេ ដែលរាប់បញ្ចូលទាំង តំបន់បឹង តំបន់ទន្លេ និង ព្រៃលិចទឹក។ វុទ្ធី (១៩៩៥) បានកំនត់ថា ជាប្រពៃណីឡូត៍នេសាទត្រូវបានផ្តល់អោយ តាមរយៈប្រកួតប្រជែង ប្រព័ន្ធដេញ ថ្លៃសាធារណៈសំរាប់រយៈពេល ២ឆ្នាំវៀងគ្នា ដោយតំលៃដេញបានសំរាប់ឆ្នាំទី១ និងទី២ដូចគ្នា។ ជាសរុបមានឡូត៍នេសាទ ចំនួន ២៧០ឡូត៍នេសាទ និងឡូត៍ដាយ (រូប ៣.១ តារាង ៣.៤)ទូទៅប្រទេស ដែលចែកជា: (១) ឡូត៍នេសាទបឹងព្រែក (១៣៥) (២)ឡូត៍នេសាទឆ្នេរខ្សាច់ (២០) និង (៣)ឡូត៍ដាយ(១១៥) ដែលចាប់ត្រីតូចៗ ប្រភេទត្រីស បង្កង និង ត្រីប្រាពូជ។ តារាង ៣.៤ បង្ហាញពី របាយនៃឡូត៍នេសាទ និងឡូត៍ដាយតាមខេត្ត។ ១២ ក្នុង ២៤ ខេត្ត-ក្រុងមានឡូត៍ នេសាទ និងឡូត៍ដាយ។ ខេត្តកណ្តាលមាន ឡូត៍នេសាទ និងឡូត៍ដាយ ចំនួន ៨០ បើប្រៀបទៅនឹងខេត្តបន្ទាយមានជ័យ ដែលមានតែ៤ ឡូត៍នេសាទ។ ឡូត៍ដាយបង្កងមានតែនៅក្នុងខេត្តព្រៃវែងប៉ុណ្ណោះ(១៣ ដាយ)។ ខេត្ត២ដែលមាន ឡូត៍ដាយចាប់កូនត្រីប្រា គឺខេត្តព្រៃវែង (១០) និងខេត្តកណ្តាល (២១)។

## តារាង ៣.៤ របាយឡូតិ៍នេសាទ និងដាយត្រី តាមខេត្ត កម្ពុជា១៩៩៨

| ខេត្ត | ឡូតិ៍បឹង_ព្រែក | ឡូតិ៍ដាយ | ឡូតិ៍ដាយត្រីលិញ | ឡូតិ៍ដាយបង្កង | ដាយកូនត្រីប្រាម៉ៅ | ឡូតិ៍ធ្នូឡេខ្សាច់ | សរុប |
|---|---|---|---|---|---|---|---|
| **តំបន់ទន្លេ( មេគង្គ-បាសាក់)** | | | | | | | |
| ១. ភ្នំពេញ | ១ | ២៥ | | | | | ២៦ |
| ២. កណ្ដាល | ១៩ | ៣៨ | ១ | | ២១ | ១ | ៨០ |
| ៣. កំពង់ចាម | ១២ | | | | | ១២ | ២៤ |
| ៤. ព្រៃវែង | ១៩ | | ៧ | ១៣ | ១០ | | ៤៩ |
| ៥. តាកែវ | ២០ | | | | | | ២០ |
| **តំបន់បឹងទន្លេសាប** | | | | | | | |
| ៦. កំពង់ធំ | ៧ | | | | | | ៧ |
| ៧. សៀមរាប | ៧ | | | | | | ៧ |
| ៨. បន្ទាយមានជ័យ | ៤ | | | | | | ៤ |
| ៩. បាត់ដំបង | ១២ | | | | | | ១២ |
| ១០. ពោធិសាត់ | ៧ | | | | | | ៧ |
| ១១. កំពង់ឆ្នាំង | ១៩ | | | | | | ១៩ |
| **តំបន់មេគង្គលើ** | | | | | | | |
| ១២. ក្រចេះ | ៨ | | | | | ៧ | ១៥ |
| **សរុប** | **១៣៥** | **៦៣** | **៨** | **១៣** | **៣១** | **២០** | **២៧០** |

ប្រភព: នាយកដ្ឋានជលផល. ការិយាល័យអាជីវកម្ម( ២០០០)

ប្រព័ន្ធឡូតិ៍នេសាទ ត្រូវបានរៀបចំប្រមូលជាក្រុមដំបូង ក្នុងឆ្នាំ១៩០៨ និងមកដល់ពេលនេះ គ្របដណ្ដប់ប្រហែល ៨.៥២៩ គីឡូម៉ែត្រការេ នៃតំបន់នេសាទសំខាន់ៗស្ទើរទាំងអស់ ក្នុងប្រទេស (ហ្គាម, ២០០០)។ ឡូតិ៍នេសាទធំៗភាគច្រើននៅក្នុង បឹងទន្លេសាប ដែលមានប្រមាណ ៨០ភាគរយនៃផ្ទៃក្រឡាទាំងមូលរបស់បឹង។ ម្ចាស់ឡូតិ៍នេសាទនិមួយៗ មានសិទ្ធិផ្តាច់មុខ ក្នុងការប្រមូលផលនេសាទ ពីឡូតិ៍របស់គេតាមការណែនាំច្បាស់លាស់មួយគឺ " សៀវភៅបន្ទុក " សំរាប់ឡូតិ៍និមួយ។ ការណែនាំនេះ បានពិពណ៌នាពីរដូវបើកនេសាទ ពេលវេលាបង់លុយ ការអនុញ្ញាតិអោយប្រើប្រាស់ឧបករណ៍ព្រំប្រទល់ លក្ខណៈភូមិសាស្ត្រសំខាន់ៗ និង កំណត់តំបន់ដែននេសាទសាធារណៈ សំរាប់ឡូតិ៍និមួយ( ឌីកហ្គេន និងធូក. ១៩៩៨)។

ប្រព័ន្ធឡូតិ៍នេសាទដាយគឺ មានទីតាំងស្ថិតទន្លេនឹងមួយកន្លែង ដែលមានសាច់សំណាញ់បើកទូលាយ អាចចាប់បានត្រីតូចៗ ដ៏ច្រើនសន្ធឹកសន្ធាប់ដែលធ្វើចរាចរ " ត្រីស ភាគច្រើនជា cyprinid carp ដូចជាត្រីរៀល/ត្រីលិញ " ការធ្វើចរាចរនេះ លេចឡើងខ្លាំងតាមរដូវ និងទាក់ទងទៅនឹងវដ្តនៃច័ន្ទគិត។ រដូវនេសាទដែលត្រូវខ្លាំង ត្រីជាច្រើនរយ គីឡូក្រាម

ឬ រហូតដល់១តោន ដែលគេអាចចាប់បានក្នុងរយៈពេល ៥-១០ នាទីម្តង ( ចូក និងស៊ីណា, ១៩៩៧) ។ ឡូត៍នេសាទដាយ រួមចំណែកពី ១០-២០ភាគរយនៃផលចាប់សរុប ៧២.៥០០តោន ពីការនេសាទទ្រង់ទ្រាយធំ ក្នុងឆ្នាំ ១៩៩៥ (ដៀប, ១៩៩៩)។ ផលចាប់សរុបរបស់ឡូត៍នេសាទដាយ ក្នុងខេត្តកណ្តាល និង រាជធានីភ្នំពេញ ត្រូវបានបង្ហាញនៅក្នុងតារាង ៣.៥។ ការនេសាទនេះផ្តល់យ៉ាងសំខាន់នូវ ប្រហុក ទឹកត្រី ចំណីត្រី និងម្សៅត្រីសំរាប់ការអភិវឌ្ឍន៍វារីវប្បកម្ម។ ជារៀងរាល់ឆ្នាំ ពេលដែលត្រីធ្វើចរចារខ្លាំង នៅតាមទន្លេសាបកម្ពុជា មានការដោះដូរស្រូវ និងត្រីតូចៗ (ត្រីសំណល់) ដើម្បីកែច្នៃ ធ្វើជាប្រហុក នេះគឺជាសមាភាគដ៏សំខាន់សំរាប់សន្តិភាពស្បៀងប្រចាំរដូវ នៃកសិករក្រីក្រ។

**តារាង ៣,៥ ផលនេសាទដោយដាយ នៅកណ្តាល និងរាជធានីភ្នំពេញ កម្ពុជា, ១៩៩៩**

| ឆ្នាំ | ចំនួនឡោ | ផលនេសាទតាមខែ (តោន) | | | | | | |
|---|---|---|---|---|---|---|---|---|
| | | តុលា | វិច្ឆិកា | ធ្នូ | មករា | កុម្ភៈ | មិនា | សរុប(តោន) |
| ១៩៩៥ | ៦៣ | ១២៨ | ៣៨៦ | ៥៣៧៩ | ៦៩៧៩ | ១៥៦៩ | ១៤៤២៩ | |
| ១៩៩៦ | ៦៨ | ៨ | ៧១ | ៣៦៣ | ១០១០៤ | ៣៣៦១ | ៣៣៦១ | ១៥៤៨៨ |
| ១៩៩៧ | ៦៨ | | ៩២ | ៩៨៩ | ១១០៤៣ | ១៦៦០២ | ៩៤៩ | ១៤៦៧១ |
| ១៩៩៨ | ៦៣ | ១២ | ១៩ | ៤៩៤២ | ៣៨០៣ | ១៩៩ | | ៨៨៩៤ |

ប្រភព: ដៀប ឡឹង (១៩៩៩)

ម៉ៅ ប៉េងប៊ុន (១៩៩៩) បានរាយការណ៍ថា ការប្រមូលកូនត្រីប្រាម្សៅ (*Pangasius hypophthalmus*) ដោយ ឧបករណ៍ស្នែមុង គឺជាមុខរបរដែលទទួលបានកំរៃយ៉ាងខ្ពស់ ហើយការនេសាទបែបនេះមានតាំងតែពីទសវត្ស ១៩៨០ ដែលប្រព្រឹត្តិឡើងតែរយៈពេលខ្លី ចាប់ពី ខែមិថុនាដល់កក្កដា ហើយពេលខ្លះដល់ខែសីហា។ ការធ្វើនេសាទនេះភាគច្រើន ធ្វើដោយ អ្នកនេសាទជាជនជាតិវៀតណាម ដែលមានបង្អែកពីក្រោយជាក្រុមយោធា និងអ្នកនេសាទកម្ពុជា ដោយមានការ គ្រាំទ្រពីមន្ត្រីថ្នាក់ខ្ពស់ទាំងស៊ីវិល និងយោធា នៅខេត្តសំខាន់១៤ គឺខេត្តកំពង់ចាម កណ្តាល (ពីអ្នកលឿង ចុះទៅដល់ព្រំដែន កម្ពុជា-វៀតណាម ក្នុងស្រុកលើកដែក) ព្រៃវែង និង ភ្នំពេញ។ កូនត្រីម្សៅរាប់លានក្បាល ត្រូវបាននាំយកទៅបំប៉ន ដោយឯកជន នៅខេត្តដុងថាប់ ប្រទេសវៀតណាម សំរាប់ការចែកចាយបន្តទៅសហគ្រាសចិញ្ចឹម ក្នុងស្រះ និងបែ នៅ ខេត្តផ្សេងៗនៃវៀតណាមខាងត្បូង ដែលចំនួនតិចតួចប៉ុណ្ណោះដែលទុកចិញ្ចឹមក្នុងប្រទេសកម្ពុជា។ ក្នុងឆ្នាំ ១៩៨៩ ការនេសាទ នេះបានបង្កើតជាសាជីវកម្ម ដូចការឡូត៍នេសាទនេសាទដាយ នៅក្នុងច្បាប់ជលផល ដើម្បីគ្រប់គ្រងផលស្តុករបស់វា និងធ្វើ អោយប្រសើរឡើងផលិតកម្ម សំរាប់សន្តិសុខស្បៀងនៅជនបទប្រទេសកម្ពុជា។ ការប្រមូលយកតែកូនត្រីមួយប្រភេទគត់ នៃត្រីប្រាធំ(*P. hypophthalmus*)( ប្រហែល ២០ភាគរយ) ត្រូវបានប៉ះពាល់ជាអវិជ្ជមានលើប្រភេទផ្សេងៗទៀត ជាពិសេសត្រីស្រកាតូចៗ ប្រមាណ ៧០-៨០ភាគរយនៃផលចាប់សរុប( តាណា, ១៩៩២)។ ការនេសាទកូនត្រីម្សៅនេះ បានរីករាលដាល ក្នុងដែនសំខាន់១នៃទន្លេមេគង្គពីព្រំប្រទល់កំពង់ចាម-ក្រចេះ ចុះទៅដល់ព្រំដែន កម្ពុជា-វៀតណាម។ វាកើតឡើងផងដែរនៅក្នុងទន្លេតូចទាំងមូល ក្នុងខេត្តកំពង់ចាម និងព្រៃវែង និងនៅតាមទន្លេសាប ពីភ្នំពេញ ទៅដល់ ព្រែកក្តាម។ ប៊ុន, ១៩៩៩ បានរាយការណ៍ផងដែរពី ផលចាប់សរុបដែលមានពី

០.៥ ទៅ ១.០ លានកូនក្នុង១ដាយ១ថ្ងៃ ក្នុងស្រុកមុខកំពូល ខេត្តកណ្តាល។ ចំនួនដាយ និងកូនត្រីប្រាម៉ៅសរុប នឹងសង្ខេបក្នុងតារាង ៣.៦។ គណៈកម្មការ ទន្លេមេគង្គបានរាយការណ៍ថា រៀងរាល់ឆ្នាំ យ៉ាងហោចក៏បាននាំចេញទៅប្រទេសវៀតណាម ១០០លានកូនដែរ។

**តារាង ៣.៦ របាយនៃដាយកូនត្រី និងកូនត្រីប្រាម៉ៅ** (*P. hypophthalmus*) **តាមខេត្ត, កម្ពុជា១៩៩៨**

| | កណ្តាល/ភ្នំពេញ | កំពង់ចាម | ព្រៃវែង | សរុប |
|---|---|---|---|---|
| **ចំនួនដាយ(ឯកតា)** | **៦៥២** | **១៦១** | **១៣៦** | **៩៤៩** |
| កូនត្រីប្រាម៉ៅ (P. hypophthalmus) | ៧០៣-១.៨៦២ | ១៧៣.៩-៣៨៦.៤ | ១.៤-៤.៧ | ៨៧៨.៣-២.២៥៣ |

ប្រភព: គណនាពី ដោបេង ប៊ុន (១៩៩៩)

ហាមេត (១៩៩៨) បានរាយការណ៍ថា ការចូលរួមក្នុងនេសាទទ្រង់ទ្រាយធំ ដោយគ្រួសារដែលរស់នៅ ក្នុងឃុំដែលពឹងផ្អែក លើការនេសាទគឺជាទូទៅមានកំនត់។ ឡូត៍នេសាទត្រូវបានជួលទៅអោយអ្នកមានលុយ ដែលមាន ពីខាងក្រៅសហគមន៍នេសាទ កម្មករនេសាទគឺត្រូវយកមកផងដែរពីតំបន់ខាងក្រៅ។ តាណា និងហាមេត (១៩៩៦) បានរកឃើញថា ប្រជាជន តិចតួច ដែលរស់នៅជាអចិន្ត្រៃយ៍ ឬនៅក្បែរសហគមន៍នេសាទ ត្រូវបានជួលឬជ្រើសរើស អោយធ្វើការជាកម្មករនៅក្នុង សកម្មភាពនេសាទទ្រង់ទ្រាយធំនេះ។ ដូចមានបង្ហាញក្នុងតារាង ៣.៧ មានតែ ២៣ មេគ្រួសារប៉ុណ្ណោះក្នុងគ្រួសារសរុបចំនួន ១៩៨៥ តំណាងអោយ ១.២ភាគរយនៃគ្រួសារអ្នកនេសាទ ត្រូវបានចូលរួម ក្នុងការនេសាទទ្រង់ទ្រាយធំនេះ។ ជាមួយគ្នានេះដែរ មិនមានគ្រួសារដែលមកពីខេត្តកណ្តាល សៀមរាប និង ពោធិសាត់ បានចូលរួមក្នុងលក្ខណៈឧស្សាហកម្មនេះ ជាអ្នកជួល ឬអ្នកជួលបន្ត ទោះបីឡូត៍នេសាទទាំងនោះស្ថិតនៅក្នុង ខេត្តទាំងនេះ ក៏ដោយ (មើលតារាង ៣.៤ផង)។

**តារាង ៣.៧ របាយនៃគ្រួសារនេសាទ* តាមប្រភេទនេសាទក្នុងរដូវបើកនេសាទ កម្ពុជា, ១៩៩៦**

| | មេគ្រួសារ | | គ្រួសារទាំងអស់ | |
|---|---|---|---|---|
| **ប្រភេទនេសាទ** | **ចំនួនគ្រួសារ** | **ភាគរយ/b** | **ចំនួនគ្រួសារ** | **ភាគរយ/c** |
| នេសាទជាលក្ខណៈគ្រួសារ | ១៥៩៩ | ៨៧ | ១៩៧៤ | ៩៩ |
| នេសាទជាលក្ខណៈសិប្បកម្ម | ១៧២ | ៩ | ២៨៣ | ១៤ |
| នេសាទជាលក្ខណៈឧស្សាហកម្ម | ១៩ | ១ | ២៣ | ១ |

| | | | | |
|---|---|---|---|---|
| កម្មករឡូត៍នេសាទ | ៤៥ | ៣ | ៩៣ | ៣ |
| **សរុប/a** | **1835** | **100** | **2330** | **177** |

ប្រភព: ហាមេត ( ១៩៩៨)

- គ្រួសាររស់នៅក្នុងតំបន់បឹងទន្លេសាប ( ៦ខេត្ត) និង តំបន់ធម្មតា ( ២ខេត្ត និងភ្នំពេញ)

_a ក្នុងសរុបអាចលើសចំនួននៃគ្រួសារដែលចូលរួមនេសាទ ជាសមាជិកដែលនេសាទលើសពី ១ប្រភេទនេសាទ

_b គិតជាភាគរយ នៃគ្រួសារដែលជាមេគ្រួសារធ្វើនេសាទ (n=1835)

_c គិតជាភាគរយ នៃចំនួនសរុបគ្រួសារនេសាទ (n=1985)

របាយនៃគ្រួសារដែលចូលរួម ក្នុងការនេសាទទ្រង់ទ្រាយធំ តាមប្រភេទនៃដែននេសាទ ឬតាមឡូត៍នេសាទ ក្នុងខេត្ត កណ្តាល កំពង់ចាម កំពង់ឆ្នាំង កំពង់ធំ មានបង្ហាញនៅក្នុងតារាង ៣.៨។ ក្រឡាផ្ទៃជាមធ្យមនៃឡូត៍នេសាទគឺ ២៤.១៨២ ម៉ែត្រការេ សំរាប់ឡូត៍នេសាទដែលជួល ឬជួលបន្ត ដោយមេគ្រួសារ ( ហាមេត. ១៩៩៨) ។ ១៦.៧ភាគរយនៃគ្រួសារគិតជាមធ្យម បានចូលរួម ក្នុងការនេសាទទ្រង់ទ្រាយធំនេះ នៅបឹងទន្លេសាប ( ៥ខេត្ត) និង តំបន់ទំនាបមេគង្គ-បាសាក់ ( ៣ខេត្ត) ។ មេគ្រួសារទាំងនោះ បានដំណើរការឡូត៍នេសាទរបស់ខ្លួន ជាមធ្យមពី ២ ទៅ ១០ឆ្នាំ ប៉ុន្តែពួកគាត់បានចូលរួមក្នុងសកម្មភាពនេសាទនេះពី ៩ ទៅ ៣០ឆ្នាំ។

**តារាង៣,៨ របាយនៃគ្រួសារនេសាទ(ចំនួន)ដែលចូលរួមក្នុងនេសាទឧស្សាហកម្ម តាមដែលនេសាទនានា**

**កម្ពុជា, ១៩៩៩**

| ដែននេសាទ | ភ្នំពេញ | កណ្តាល | កំ.ចាម | កំ.ឆ្នាំង | សៀមរាប | ពោធិសាត់ | បាត់ដំបង | កំ.ធំ | សរុប |
|---|---|---|---|---|---|---|---|---|---|
| ឡូត៍បឹង-ព្រែក | ២ | ០ | ៥ | ៤ | ០ | ០ | - | ២ | ១៣ |
| ឡូត៍ដាយត្រី | ១ | ០ | ០ | ០ | ០ | ០ | - | ០ | ១ |
| ឡូត៍ឆ្នេរខ្សាច់ | ០ | ០ | ៤ | ០ | ០ | ០ | - | ០ | ៤ |
| ឡូត៍ដាយបង្កង | ០ | ០ | ០ | ០ | ០ | ០ | - | ០ | ០ |
| ផ្សេងៗ | ០ | ០ | ០ | ១ | ០ | ០ | - | ០ | ១ |
| សរុប | ៣ | ០ | ៩ | ៥ | ០ | ០ | ៤ | ២ | ៣ |
| **ភាគរយនៃគ្រួសារចូលរួមក្នុងនេសាទឧស្សាហកម្ម** | **៧,៧** | **០** | **៣៧,៥** | **២៦,៣** | **០** | **០** | **៣៣,៣** | **២៨,៥** | **១៦,៧** |

ប្រភព: គណនាពីហាមេត( ១៩៩៨) តារាង ៣.៤៧

- ពត៌មានស្តីពីរបាយគ្រួសារតាមដែននេសាទ មិនមានសំរាប់ខេត្តបាត់ដំបង

ផលិតផលត្រីសរុប ដែលបានមកពីការនេសាទទ្រង់ទ្រាយធំ (ឡូត៍នេសាទ) ពីខេត្តមួយខេត្ត និង លក្ខណៈជាតិ គឺត្រូវបាន បង្ហាញក្នុងតារាង ៣.១ និងតារាង ៣.២។ ផលិតផលត្រីជាលក្ខណៈពាណិជ្ជកម្ម តាមលក្ខណៈជាតិប្រែប្រួលពី ១៨.៤០០ តោនក្នុងឆ្នាំ ១៩៨០ ទៅ ៧១.០០០តោនក្នុងឆ្នាំ ១៩៩៥។ ខេត្តកំពង់ឆ្នាំង ចាប់បានត្រីច្រើនជាងគេ (១១៧.៩០០តោន) បន្ទាប់មកខេត្តកណ្ដាល (១២.៣៤៤តោន) និងពោធិសាត់ (៧.៣០០តោន) និងសៀមរាប (៧.០០០តោន)ក្នុងឆ្នាំ ១៩៩៥។ វ៉ាន់ហ្សាលីង និង ធូក (១៩៩៥) បានកំនត់បង្ហាញថា ការនេសាទទ្រង់ទ្រាយធំចាប់ បានពីចន្លោះ ៤៥.០០០-៨០.០០០ តោន(តារាង ៣.៩) ដែលប្រៀបធៀបទៅនឹង តួលេខនៃផលចាប់ត្រីពាណិជ្ជកម្ម (ការនេសាទទ្រង់ទ្រាយធំ និង សិប្បកម្ម) បានអោយដឹងដោយនាយកដ្ឋានជលផល។

## តារាង៣,៩ បរិមាណតាមលំដាប់ ផលនេសាទទឹកសាបប្រចាំឆ្នាំ ពី១៩៩៤_១៩៩៨ នៅកម្ពុជា

| បរិមាណផលនេសាទទឹកសាបប្រចាំឆ្នាំ នៅកម្ពុជា | ផលចាប់ក្នុងឆ្នាំ ពី១៩៩៤ ដល់ ១៩៩៧ |
|---|---|
| | ផលនេសាទទឹកសាបប្រចាំឆ្នាំ(គិតជាតោន) |
| + នេសាទឧស្សាហកម្ម | |
| - ឡូត៍នេសាទ[1] : | 30.000-60.000 |
| - ដាយ[2] : | 15.000-20.000 |
| + នេសាទសិប្បកម្ម:[3] | 85.000-100.000 |
| + នេសាទគ្រួសារ:[3] | 115.000-140.000 |
| + នេសាទតាមវាលស្រែ:[4] | 45.000-110.000 |
| **សរុបផលនេសាទទឹកសាប** | 290.000-430.000 |

1. ស្ថិតនៅចន្លោះដែលខ្ពស់បំផុត និងទាបបំផុត
2. ការប្រមាណដែលខ្ពស់ និងទាបបំផុត ក្នុងឆ្នាំ ១៩៩៤-៩៨
3. ផ្អែកលើការធ្វើអង្កេតសេដ្ឋកិច្ច-សង្គមដែលទិន្នន័យត្រូវបានគណនាសរុបទូទាំងប្រទេស
4. ប្រហែល 1.8លានហិកតា គុណនឹង ទិន្នផលត្រីពី 25-62 គីឡូក្រាម/ហិកតា

វ៉ែនបូត (១៩៩៦) បានរកឃើញថាប្រព័ន្ធអេកូឡូស៊ីទន្លេ និងបឹងនៃប្រទេសកម្ពុជា ផ្ដល់នូវត្រីចំរុះដ៏សំបូរបែប។ សមាភាព ប្រភេទត្រីក្នុងផលចាប់នៃគ្រួសារ ប្រែប្រួលនៅតាមរដូវកាល ប្រភេទនៃការនេសាទ ទីតាំងភូមិសាស្ត្រ។ នៅក្នុងការអង្កេត សេដ្ឋកិច្ចសង្គមគ្រួសារ ដែលធ្វើដោយ នាយកដ្ឋានជលផល/គ្រោងការណ៍គ្រប់គ្រងនេសាទទឹកសាប កម្ពុជា ក្នុងស្រុកនេសាទ នៃខេត្តចំនួន៨ (៥.១១៧ គ្រួសារ) ពួកគេរកឃើញថា ១៥ប្រភេទត្រីដែលសំខាន់បំផុត ក្នុងន័យបរិមាណច្រើនក្នុងផលចាប់ ដោយគ្រួសារ(តារាង ៣.១០)។ ចំនួនដ៏ច្រើនដែលចាប់បានដោយគ្រួសារ គ្រប់ប្រភេទ នេសាទ ត្រូវបានរាយការណ៍ថាជា ត្រីរៀល(mud carp) គឺជាប្រភេទត្រីដ៏សំខាន់បំផុត ក្នុងន័យបរិមាណច្រើនក្នុង ផលចាប់របស់គេ។ ជាបន្ទាប់បន្ត ជា ប្រភេទត្រីក្រាញ់ស្រែ (Climbing perch) ត្រីរស់/ផ្ទក់(snakehead) និង ត្រីកំភ្លាញ(moonlight gourami)។ ធូក និង វ៉ាន់ហ្សាលីង(២000) រាយការណ៍ថា ក្នុង១២ខេត្ត ដែលជា

ពួកគាត់កំពុងធ្វើការឥឡូវនេះ ដោយសហការជំ ជិតស្និទជាមួយនាយកដ្ឋាន ហើយត្រូវធ្វើជាឡូត៍នេសាទ (តារាង៣.៤) សមាសភាពប្រភេទត្រី ដែលចាប់បាន ខុសគ្នា ផងដែរទៅតាមប្រភេទនេសាទ រដូវកាល និងទីតាំង ភូមិសាស្ត្រ។ ក្នុងតារាង ៣.១១ បង្ហាញពីត្រីសំខាន់១០ប្រភេទ ដែល មានបរិមាណច្រើន និង មានតំលៃក្នុង លក្ខណៈជាតិ។ ប្រភេទដែលស្ថិតនៅលំដាប់លើគេគឺត្រីរៀល ត្រូវបានចាប់ ៣៦.៥ ភាគរយ នៃគ្រួសារនៅជនបទ ប្រៀបធៀបជាមធ្យម មានត្រឹមតែ ២១ ភាគរយ ក្នុងកំរិតថ្នាក់ជាតិ។ ៣ប្រភេទផ្សេង ទៀត មានត្រីរស់ ត្រីព្រួល និង ត្រីប្រា ត្រូវបានចាប់ ដោយទាំងគ្រួសារជនបទ និងទូទៅប្រទេស ( គ្រប់កំរិត ឬ quintiles នៃប្រជាជន)។ ឧបករណ៍នេសាទ ប្រកបដោយប្រសិទ្ធខ្ពស់ ត្រូវបានប្រើប្រាស់ក្នុងឡូត៍នេសាទ ដូចជារបាំងព្រួល ឬស្បៃ ភ្ជាប់ជាមួយលប ឬសិង ដែលអាចបាំងជុំវិញបានធំទូលាយ និង សាច់អ៊ួន ដែលបិទមែនអោយត្រីលោតបាន។ ឧបករណ៍ភាគច្រើន ដែលបាន ប្រើក្នុងឡូត៍នេសាទ គឺត្រូវមានម្ចាស់រួមគ្នា ដោយបែងចែកភាគហ៊ុន។

**តារាង៣,១០ ភាគរយនៃគ្រួសាររាយការណ៍ពីប្រភេទត្រីសំខាន់ៗដែលនេសាទបាន(រៀបតាមសំដាប់លេខ១ រៀបមកនៃបរិមាណផលនេសាទ), ១៩៩៦**

| ឈ្មោះត្រី | ឈ្មោះវិទ្យាសាស្ត្រ | នេសាទគ្រួសារ (n= 1758) | នេសាទសិប្បកម្ម (n= 207) | នេសាទឧស្សាហកម្ម (n= 22) | សរុប |
|---|---|---|---|---|---|
| រៀល | *Henicorhynchus spp.* | ៣៣.២ | ៤៤.៤ | ៣១.៨ | ៣៦.៥ |
| ក្រាញ់ស្រែ | *Anabas testudinus* | ១០.៥ | | ៤.៥ | |
| រស់ | *Chana marulius* | ៨.៦ | ៤.៣ | | |
| កំភ្លាញ | *Triochogaster microlepis* | ៦.០ | | ៤.៥ | |
| កញ្ចុះ | *Mystus spp.* | ៣.២ | | | |
| កំពឹស | | ៣.១ | ២.៤ | | |
| ចង្វា | *Danio aeguipinnatus* | ២.៤ | ៤.៣ | ៩.១ | ៥.១ |
| គេស | *Micronema spp.* | ២.០ | | ១៣.៦ | |
| អណ្តែង | *Claria spp.* | ២.៣ | | | |
| ឆ្លាំង | *Mystus nemerus* | ១.៩ | | | |
| លិញ | *Thynnichthys thynnoides* | ១.៥ | ១.៩ | | |
| តាអោន | *Ompok hypophthalmus* | ១.៦ | ៤.៨ | ៩.១ | ៥.១ |
| ព្រួល | *Cirrhinus micrlepis* | | ៣.៤ | | |
| ប្រា | *P. hypophthalmus* | | ២.៤ | | |
| ក្ាំងហាយ | *Belodontchthys dinema* | | ១.៩ | | |

ប្រភព: បាមេត(១៩៩៨)

### តារាងទី៣: ឆ្នាំ១៩៩៥/៩៦ សមាសភាពប្រភេទត្រីចំនួន១០ប្រភេទ ដែលចាប់ដោយប្រភេទឧបករណ៍នេសាទ (ដៀប, ១៩៩៨)

| ប្រភេទត្រី | ឡូត៍នេសាទ (%) | ដាយត្រី (%) | ឧបករណ៍សិប្បកម្ម (%) | ផលចាប់សរុប (%) | តំលៃសរុប (%) |
|---|---|---|---|---|---|
| ១. ត្រីរៀល | ១១ | ៤០ | ២០ | ២១ | ៩ |
| ២. ត្រីឆ្ពោ/ដៀប | ១៦ | - | ៨ | ៩ | ១៩ |
| ៣. ត្រីឆ្កោក | ៨ | ១ | ១៣ | ៩ | ៨ |
| ៤. ត្រីខ្នងវែង | ៥ | ៦ | ៧ | ៦ | ២ |
| ៥. ត្រីក្រុស | ២ | ១០ | ២ | ៤ | ២ |
| ៦. ត្រីព្រួល/ក្រឡង់ | ៥ | ៣ | ២ | ៣ | ៤ |
| ៧. ត្រីប្រា | ៨ | ០ | ១ | ៣ | ៣ |
| ៨. ត្រីឆ្កិន | ៣ | ០ | ៤ | ៣ | ២ |
| ៩. ត្រីស្លឹកឫស្សី | ១ | ១១ | ០ | ៣ | ១ |
| ១០. ត្រីរ៉ស់/ផ្ទក់ | ៥ | - | ១ | ២ | ៦ |
| ទំងន់ (%) នៃត្រី១០ប្រភេទ | ៦៤ | ៧០ | ៥៩ | ៦៣ | ៥៦ |
| ភាគរយក្នុងផលចាប់សរុប | ៣៣ | ២៣ | ៤៤ | ១០០ | |
| ភាគរយក្នុងតំលៃសរុប | ៤១ | ១៥ | ៤៤ | ១០០ | |
| ចំនួនប្រភេទត្រីដែលបានកត់ត្រា | ៧៥ | ៤៤ | ៦២ | | |

តារាង ៣.១១ មិនបញ្ចូលការនេសាទគ្រួសារ និងវាលស្រែ ដោយពុំមានទិន្នន័យគ្រប់គ្រាន់

ពេលថ្មីៗនេះ នាយកដ្ឋានជលផល បានណែនាំនូវប្រភេទគ្រប់គ្រងថ្មីមួយ នោះគឺ "ឡូត៍នេសាទស្រាវជ្រាវ"។ ការកើតឡើងនៃឡូត៍នេសាទស្រាវជ្រាវ ចាប់ផ្តើមនៅឆ្នាំ ១៩៩៧ ដោយមានចំនួន ៧ឡូត៍នេសាទ។ ក្នុងអំឡុងពេលនៃការដេញថ្លៃសំរាប់ឆ្នាំ ១៩៩៩-២០០០ ប្រព័ន្ធឡូត៍នេសាទនេះពង្រីកទៅដល់ចំនួន ៦៩។ លក្ខណៈជាគន្លឹះ នៃឡូត៍នេសាទស្រាវជ្រាវ គឺថាឡូត៍ទាំងនេះមិនបានដាក់អោយដេញថ្លៃជាសាធារណៈទេ និងជំនួសដោយរៀបចំឡើង និងគ្រប់គ្រងដោយផ្ទាល់ រវាងម្ចាស់ឡូត៍នេសាទ និង នាយកដ្ឋានជលផល/ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ។ បន្ថែមពីនេះ ឡូត៍នេសាទ ស្រាវជ្រាវមានតំលៃពី ៤-៦ឆ្នាំ (ស្រីឡើត និង ឡាំបឺត, ២០០០)។ បំណងកើតឡើង ដើម្បីបែងចែកជាថ្មីនូវឡូត៍នេសាទបឹង-ព្រៃកជាឡូត៍នេសាទស្រាវជ្រាវ។ គោលបំនងគឺដើម្បីធ្វើអោយល្អប្រសើរឡើង ការងារគ្រប់គ្រងឡូត៍ ពាមរយៈផលចាប់ ជីវសាស្រ្តត្រី គុណភាពទឹក និង ផលប៉ះពាល់ ការធ្វើនេសាទ និង លក្ខ័ខណ្ឌសេដ្ឋកិច្ចសង្គម នៃទីតាំងសហគមន៍នេសាទ ។ វុទ្ធី (១៩៩៩) បានរាយការណ៍ថា នាយកដ្ឋានជលផល បានបន្ថែមលក្ខ័ខណ្ឌថ្មីៗ ក្នុងការគ្រប់គ្រងនូវឡូត៍នេសាទទាំងនេះ ដូចជា កំនត់ព្រំប្រទល់ ការស្តារឡើងវិញនូវព្រែក ការដាំព្រៃលិចទឹក ។ល។

### ៣.៤.២ នេសាទលក្ខណៈសិប្បកម្ម

ការនេសាទលក្ខណៈសិប្បកម្ម តំរូវអោយមានលិខិតអនុញ្ញាតិ ពីនាយកដ្ឋានជលផល។ ឧបករណ៍ដែលមានលិខិតអនុញ្ញាតិ នេះត្រូវបង់ពន្ធ ដោយផ្អែកទៅលើ ផលនេសាទក្នុង១រដូវ/ប្រភេទឧបករណ៍នេសាទ។ វាមាន មង អួន លបរួម ផ្សំព្រួល សន្ទូចរនង ឆ្នុក លបដែលមានអង្កត់ផ្ចិតធំជាង ៣០ ស.ម. ។ល។ ការនេសាទនេះអាចប្រព្រឹត្តិទៅបាន ក្នុងដែននេសាទ ប៉ុន្តែបានតែក្នុងរដូវបើកនេសាទប៉ុណ្ណោះ និង ក្រៅពីឡូត៍នេសាទ និងឡូត៍បំរុងទុក។

ឧបករណ៍នេសាទភាគច្រើន ធ្វើសកម្មភាពនៅទន្លេមេគង្គខាងលើ (៣៧ភាគរយ) និង នៅទន្លេសាប (៣១ភាគរយ) (ហាមេត. ១៩៩៨)។ នេសាទទាំងនេះ នៅតាមបឹងទន្លេសាប ដែលតភ្ជាប់ទៅព្រែក/បឹងតូចៗ មាន ១៨ភាគរយ នៃចំនួនសរុបអ្នកនេសាទឧបករណ៍សិប្បកម្ម (តារាង ៣.៣១)។ ការចូលរួមទាំងនេះ នៃការនេសាទឧបករណ៍សិប្បកម្ម គឺភាគច្រើនអ្នកទទួលលិខិតអនុញ្ញាត ដោយមានការចូលហ៊ុនពីម្នាក់ទៀត មានស្ថិតនៅស្ទើរគ្រប់ខេត្តដែល បានធ្វើការសិក្សា លើកលែងតែ ខេត្តកណ្តាល និងបាត់ដំបង។

**តារាង៣.១៣ ចំនួនគ្រួសារចូលរួមក្នុងការនេសាទសិប្បកម្ម តំបន់ដែលនេសាទនានាក្នុងខេត្ត៨ នៃទន្លេសាប ដៃរបស់វា/បឹង និង មេគង្គ/បាសាក់**

| ដែននេសាទ | ភ្នំពេញ | កណ្ដាល | កំ.ចាម | កំ.ឆ្នាំង | សៀមរាប | ពោធិសាត់ | បាត់ដំបង | កំ.ធំ | សរុប | ភាគរយ |
|---|---|---|---|---|---|---|---|---|---|---|
| ទន្លេសាប | ៣១ | ៦ | ០ | ៣២ | ០ | ០ | ១ | ១៧ | ៨៧ | ៣០.៧ |
| បឹងទន្លេសាប | ០ | ០ | ០ | ២ | ៥ | ០ | ១៤ | ០ | ២១ | ៧.៤ |
| មេគង្គលើ | ១៦ | ០ | ៩០ | ០ | ០ | ០ | ០ | ០ | ១០៦ | ៣៧.៥ |
| មេគង្គក្រោម | ២ | ០ | ៤ | ០ | ០ | ០ | ០ | ០ | ៦ | ២.១ |
| ទន្លេបាសាក់ | ៤ | ០ | ០ | ០ | ០ | ០ | ០ | ០ | ៤ | ១.៤ |
| បឹងនិងព្រែកតូចៗ ភ្ជាប់នឹងទន្លេសាប | ១ | ០ | ០ | ៥ | ០ | ០ | ០ | ១១ | ១៧ | ៥.៧ |
| បឹងនិងព្រែកតូចៗ ភ្ជាប់នឹងបឹងទន្លេសាប | ០ | ០ | ០ | ០ | ០ | ៣០ | ០ | ០ | ៣០ | ១០.៦ |
| បឹងនិងព្រែកតូចៗ ភ្ជាប់នឹងទន្លេមេគង្គ /បាសាក់ | ៤ | ១ | ៧ | ០ | ០ | ០ | ០ | ០ | ១២ | ៤.២ |
| ផ្សេងៗ | ០ | ១ | ០ | ០ | ០ | ០ | ០ | ០ | ១ | ០.៤ |
| សរុប | ៩៨ | ៨ | ១០១ | ៣៩ | ៩ | ៣០ | ១៩ | ២៨ | ២៨៤ | |
| **ភាគរយ/a** | **២១,៣២** | **០,៧០** | **៨,៦៨** | **៨,៣០** | **០,៩១** | **៦,៩៦** | **២,៤១** | **៩,៩៤** | **៩,៩៩** | **១០០** |

/a ភាគរយនៃចំនួនគ្រួសារបានអង្កេត

ឧបករណ៍នេសាទសិប្បកម្ម ធ្វើសកម្មភាពផងដែរ នៅក្នុងខេត្ត តាកែវ ព្រៃវែង ក្រចេះ ស្ទឹងត្រែង បន្ទាយមានជ័យ។ តារាង ៣.១៤ បង្ហាញពីចំនួននៃឧបករណ៍នេសាទសិប្បកម្មដែលមានលិខិតអនុញ្ញាត ក្នុងឆ្នាំ ១៩៩៩។

**តារាង៣,១៤ របាយនៃឧបករណ៍នេសាទសិប្បកម្ម ដែលផ្តល់លិខិតអនុញ្ញាត តាមខេត្ត កម្ពុជា,១៩៩៩**

| ខេត្ត | មង (ម៉ែត្រ) | អួន (ឯកតា) | នាម (ឯកតា) | ផន (ឯកតា) | ចៃកាំ (ឯកតា) | លប (ឯកតា) | លបលលារ (ឯកតា) | សន្ទូចនេង (ឯកតា) |
|---|---|---|---|---|---|---|---|---|
| ១. ភ្នំពេញ | ២៣០០០ | ៣ | ៥០ | ៥ | ១៦ | ១០ | | ១៥០០ |
| ២. កណ្តាល | ៣៦១៥០ | ២៧ | ៣៦ | ១១ | ២៧ | | | ៧០៥០ |
| ៣. កំពង់ចាម | ៣២២៣០ | ១២៥០ | ១ | | ២២ | | | |
| ៤. ព្រៃវែង | ១៦២០ | ១ | ៨ | | ៣៨ | | | |
| ៥. តាកែវ | - | ៧១ | | | | | | |
| ៦. កំពង់ធំ | ៣៧០០ | ៤០ | | | | | | ១៨០០០ |
| ៧.សៀមរាប | ១០០០០០ | ២៥ | | | | | ១១ | ៦៥០០ |
| ៨. បន្ទាយមានជ័យ | ៨១៥០០ | ៥៣ | | | | | | |
| ៩. បាត់ដំបង | ៦៨៥០០ | ៣៨ | | ១៥ | | | ៧២ | |
| ១០.ពោធិសាត់ | ១៣៥០៤០ | ៤២ | | | | ៦០០ | ១០ | ៧២៤៥០ |
| ១១.កំពង់ឆ្នាំង | ១៤៤៥០០ | ៣៥ | ៩២ | ៥០ | ៤៥ | ២៨០០ | | |
| ១២.ក្រចេះ | ១០០០០ | ៦០ | | ១ | ១ | | | |
| ១៣. ស្ទឹងត្រែង | ៥៥០០០ | ១២ | | | | | | |
| សរុប | ៧២៤៥៤០ | ១៦៩៧ | ១៨៧ | ៨៩ | ៥០០ | ៣៧៩៦ | ២០០ | ១៦៤០០០ |

ប្រភព: នាយកដ្ឋានជលផល (២០០០), ទិន្នន័យ និងស្ថិតិនេសាទ

ផលិតផលសរុបនៃឧបករណ៍នេសាទសិប្បកម្មប្រែប្រួលពី ៨៥.០០០ ទៅ ១០០.០០០ តោន អាស្រ័យទៅតាមវដ្តរ កាល និងភាពមិនទៀងទាត់នៃកិតផលចាប់ពិតប្រាកដ (តារាង ៣.៩)។ ផលចាប់នេះចូលរួមប្រហែល ២៣ភាគរយ នៃផលចាប់នេសាទទឹកសាបសរុប ដែលរាប់បញ្ចូលទាំងផលនេសាទគ្រួសារ និងវាលស្រែ និង ៤៤ភាគរយ មិនរាប់បញ្ចូលការនេសាទទាំង២ប្រភេទខាងលើ (តារាង ៣.១១)។ យោងទៅតាមការធ្វើអង្កេតសេដ្ឋកិច្ចសង្គម គ្រួសារ (៥.១១៧ គ្រួសារ) ក្នុងខេត្តដែលជ្រើសរើសចំនួន ៨ ជុំវិញទន្លេសាប និងមេគង្គ/បាសាក់ មានតែ ៥.៥ភាគរយ ប៉ុណ្ណោះនៃចំនួនសរុប ដែលគ្រួសារទាំងអស់បានចូលរួមក្នុងការនេសាទសិប្បកម្ម ដែលជាមធ្យមផលចាប់ ៣.៤តោន ក្នុងមួយគ្រួសារក្នុងមួយឆ្នាំ។ វាមានន័យថា ចំនួនតិចតួចណាស់នៃប្រជាជនក្រីក្រជនបទ បានចូលរួមក្នុងការ នេសាទនេះ។ ការប៉ាន់ប្រមាណផលចាប់ ៨៤.៨២៦តោន ក្នុងមួយឆ្នាំ ត្រូវបានរាយការណ៍ពី៨ខេត្តប៉ុណ្ណោះ (គ្រួសារសរុប ៤៥២ ៧១៤) បើប្រៀបធៀប ទៅនឹងផលនេសាទសរុប នៃឧបករណ៍សិប្បកម្ម ក្នុងប្រទេសកម្ពុជា (តារាង ៣.១៥)។ ប្រភេទត្រី ១០ស្ថិតនៅក្នុង លំដាប់ខ្ពស់ជាងគេ ទាំងផលចាប់ និងតំលៃដែលចាប់ ហើយឧបករណ៍សិប្បកម្មត្រូវបានបង្ហាញ

នៅក្នុងតារាង ៣.១១។ ហាមេត. (១៩៩៨) បានរាយការណ៍ផងដែរ នូវប្រភេទ ត្រីសំខាន់ ចំនួន ១៥ ដែលចាប់ដោយ ២០៧គ្រួសារ ចូលរួមក្នុងឧបករណ៍នេសាទសិប្បកម្ម (តារាង ៣.១០)។

**តារាង៣,១៤ ការប៉ាន់ប្រមាណផលនេសាទមធ្យមប្រចាំឆ្នាំ សំរាប់នេសាទសិប្បកម្ម និងនេសាទគ្រួសារ សិក្សាតាមខេត្ត កម្ពុជា,១៩៩៦**

| ខេត្ត | ចំនួនសរុប គ្រួសារ/a | ភាគរយនៃគ្រួសារដែលចូលរួម/b: នេសាទគ្រួសារ | ភាគរយនៃគ្រួសារដែលចូលរួម/b: នេសាទសិប្បកម្ម | ចំនួននៃគ្រួសារដែលចូលរួម: នេសាទគ្រួសារ | ចំនួននៃគ្រួសារដែលចូលរួម: នេសាទសិប្បកម្ម | ផលនេសាទជាមធ្យម/គ្រួសារ: នេសាទគ្រួសារ | ផលនេសាទជាមធ្យម/គ្រួសារ: នេសាទសិប្បកម្ម | ផលនេសាទក្នុង១ឆ្នាំ: នេសាទគ្រួសារ | ផលនេសាទក្នុង១ឆ្នាំ: នេសាទសិប្បកម្ម | ផលនេសាទក្នុង១ឆ្នាំ: សរុប |
|---|---|---|---|---|---|---|---|---|---|---|
| ភ្នំពេញ | ២៧២២៤ | ២១.៣២ | ៣៤.៩៣ | ៥៨០៥ | ៩៥០៨ | ៣៨៩៦ | ១១១១ | ២២៦១៧ | ១០៥៦៥ | ៣៣១៧៨ |
| កណ្តាល | ១៣៤២២០ | ០.៧០ | ២៩.៩០ | ៩៤៤ | ៤០១៣៦ | ២៦១០ | ៩០៥ | ២៤៦៥ | ៣៦៣១៩ | ៣៨៧៧១ |
| កំពង់ចាម | ៩៦៧១២ | ៨.៦៨ | ៣៨.៤០ | ៨៣៩២ | ៣៧១៣៩ | ១៣៣៤ | ២៦៣ | ១១១៩៤ | ៩៧៦៧ | ២០៩៦៦ |
| កំពង់ឆ្នាំង | ៤២៣៣៥ | ៨.៣០ | ៥៤.៦៨ | ៣៥១៣ | ២៣១៤៥ | ១៥៨១ | ១១៣៧ | ៦៩៥៩ | ២៦៣២០ | ៣៣២៨១ |
| សៀមរាប | ៣៥៩៣៧ | ០.៩៦ | ៣៨.៨១ | ៣៤៤ | ១៣៩៤៩ | ៨៧៥០ | ៤៦២ | ៣០០៦ | ៦៤៤៤ | ៩៤៦២ |
| ពោធិសាត់ | ៣៤៧៦៦ | ០.៥៦ | ៥២.០៨ | ២២៨២ | ១៨១០៦ | ៥២៤៨ | ៣៥៤ | ១១៩៧៧ | ៦៤១០ | ១៨៣៧៨ |
| បាត់ដំបង | ៤៧៧២៤ | ០.៤១ | ៤៦.០៧ | ១១៤៩ | ២១៩៨៥ | ៣៩២៩ | ៧០៤ | ៤៥១៥ | ១៥៤៧៥ | ១៩៩៩៤ |
| កំពង់ធំ | ៣៣៧៩៦ | ៥.៩៤ | ២២.០៨ | ២០០៩ | ៧៤៦២ | ៦៨០២ | ៨៣៦ | ១៣៦៦៦ | ៦២៣៨ | ១៩៨៩៣ |
| សរុប | ៤៥២៧១៤ | ៥.៥៥ | ៣៨.៥២ | ២៥១២៦ | ១៧៤៣៧៩ | ៣៣៧៦ | ៦៥៨ | ៨៤៨២៦ | ១១៤៦៨៦ | ១៩៩២០៤ |

ប្រភព: ហាមេត(១៩៩៨), តារាង ៣.៤៨ ៣.៤៩ ៣.៤៥ និង ៣.៥៥

/a ផ្អែកលើចំនួនគ្រួសារសរុប ទាំង៨ខេត្ត

/b ផ្អែកលើភាគរយ នៃគ្រួសារដែលចូលរួម ក្នុងនេសាទសិប្បកម្ម (៥.៥ %) និង នេសាទគ្រួសារ (៣៨.៥ %)

### ៣.៤.៣ នេសាទគ្រួសារ និងនេសាទត្រឹមតែផ្គត់ផ្គង់បរិភោគ

ការនេសាទជាលក្ខណៈគ្រួសារ ពុំមានលិខិតអនុញ្ញាតិទេ និងអាចនេសាទបានពេញមួយឆ្នាំ និងគ្រប់ដែននេសាទទាំងអស់ លើកលែងតែនៅក្នុងកន្លែងនេសាទបំរុងទុក។ ឧបករណ៍នេសាទគ្រួសារអាចនេសាទ បាននៅក្នុងឡូត៍នេសាទក្នុងតំបន់ដែល បានកំនត់ជា " ដែនរាស្ត្រ" សំរាប់ប្រជាជន ក្នុងរដូវបើកនេសាទ និងនៅក្នុងឡូត៍នេសាទទាំងមូល នៅរដូវបិទនេសាទ (ច្បាប ជលផលកម្ពុជា, ១៩៨៧)។

ច្បាប់បានចែងនូវសិទ្ធិនៃដែននេសាទ "លក្ខណៈនេសាទគ្រួសារ" សំរាប់ធ្វើនេសាទ ដែលផ្សេងពីសកម្មភាពនេសាទទ្រង់ទ្រាយធំ។ អត្ថន័យនៃការនេសាទត្រឹមតែផ្គត់ផ្គង់ គឺផ្អែកទៅលើ សមត្ថភាពនេសាទ និងការត្រួតពិនិត្យទំហំឧបករណ៍នេសាទ។ ទោះបីជាអត្ថន័យនេះ មិនបានផ្អែកទៅលើ កំរិតនៃសមត្ថភាពនេសាទជាតំរូវការ ដើម្បីធ្វើអោយទៅជា ការផ្គត់ផ្គង់ជីវភាពរស់នៅក៏ដោយ។ ដូច្នេះដើម្បីអោយប្រជាជនក្រីក្រអាចជំរុញជីវភាពរស់នៅ តាមរយៈការនេសាទនេះ ពួកគេត្រូវតែធ្វើការនេសាទ នូវកំរិតសមត្ថភាពនេសាទមួយ ដែលមិនត្រូវអនុញ្ញាតិដោយច្បាប់។ ទាំងនេះត្រូវបានទទួល ការទទួលស្គាល់ដោយអាជ្ញាធមិដែនដីជាច្រើន ដែលមិនអាចជំរុញអ្នកនេសាទឧបករណ៍គ្រួសារនេះ បានឡើង។ យ៉ាងណាក៏ដោយ ភាពច្រើននៃឯកជននៃការនេសាទទឹកសាប បាននាំអោយមានជំលោះ រវាងអ្នកនេសាទ គ្រួសារជាមួយនិងម្ចាស់ ឡូត៍នេសាទ (ពេលខ្លះបង្កើតជាអំពើហឹង្សា)។

ច្បាប់ជលផល បានចែងជាមុនស្រាច់ ដល់ការនេសាទគ្រួសារ មិនអោយធ្វើការជួញដូរត្រី ដែលថ្មីៗនេះ បានផ្តល់នូវមូលដ្ឋាន មិនច្បាស់លាស់ ដល់ប្រជាជនក្នុងគេចផុតពីភាពក្រីក្រ តាមរយៈការកើនចំនួនបន្ថែម ក្នុងសមត្ថភាពឧបករណ៍នេសាទ។

អ្នកនិពន្ធជាច្រើនបានពិភាក្សាពីវារីធនធាន (ការនេសាទជាអាទិភាព) និង ជីវភាពរស់នៅ និង សិទ្ធិប្រើប្រាស់ និង ជំលោះក្នុងខេត្តមួយចំនួនជាកំនត់ ជាពិសេសខេត្តដែលនៅជុំវិញបឹងទន្លេសាប (អាហ្សីមី,២០០០, ហ្គាម,២០០០, អង្គការ អុកហ្វាម.២០០០, នីកហ្គីន,២០០០ កាសែតកម្ពុជាប្រចាំថ្ងៃ, ២០០០ សុថារិទ្ធិ, ២០០០ កាតូ,១៩៩៩ ធូក និងសុង, ១៩៩៩ ស្វីហ្វថ៍, ១៩៩៩ វ៉ាន់អាហ្គ័រ, ១៩៩៩ និង ហាមេ, ២០០០) និង ការសិក្សាមួយចំនួនតូច ពីស្ថានភាពខេត្តនៅរ៉ែក ខាងលើទន្លេមេគង្គ និងដៃសំខាន់ៗរបស់វា ដូចជាខេត្តស្ទឹងត្រែង (EGW, ២០០០) និង រតនគិរី (ផែក, ២០០០ FPO , ២០០០)។ អ្នកនិពន្ធខាងលើបានសន្និដ្ឋានថា អ្នកនេសាទ ឬ ជីវភាពរស់នៅរបស់ជនបទក្រីក្រ គឺពឹងផ្អែកលើវារីធនធាន (នេសាទជាចំបង) សំរាប់និរន្តភាពម្ហូបអាហារ និង ប្រាក់ចំណូលរបស់គ្រួសារ ហើយពួកគេត្រូវបានកំនត់សិទ្ធិប្រើប្រាស់ ធនធានជលផល ជាពិសេសដែននេសាទដែលមានផលិតកម្ម និង ឡូត៍នេសាទ។

ហាមេត (១៩៩៨) បានរាយការណ៍ពី របាយក្នុងតំបន់នៃគ្រួសារ ដែលចូលរួមក្នុងការនេសាទលក្ខណៈគ្រួសារនេះ។ គេរកឃើញថា អ្នកនេសាទជាលក្ខណៈគ្រួសារ ប្រមូលផ្តុំ នៅតែក្នុងព្រែក និង បឹងតូចៗ (៣៩ ភាគរយ) បន្ទាប់មកនៅតាមតំបន់ ព្រៃលិចទឹក (១៧ភាគរយ) និង នៅទន្លេសាប (១៥ភាគរយ) (តារាង ៣.១៦ និង តារាង ៣.១៧)។ ភាគរយសរុប នៃគ្រួសារដែលចូលរួមក្នុងនេសាទនេះ ក្នុងខេត្តដែលបានសិក្សាគឺ ៣៩ភាគរយ ស្មើនឹង ១៧៤.៣៧៩ គ្រួសារនៃចំនួន ៤៥២.៧១៤ គ្រួសារ រស់នៅក្នុងស្រុកនេសាទ ទាំង៨ខេត្តនៅជុំវិញបឹងទន្លេសាប និងតំបន់មេគង្គ/បាសាក់ (តារាង ៣.១៥)។ សំគាល់ថាអ្នកនេសាទគ្រួសារ ត្រូវបានកំនត់សិទ្ធិចូលទៅ នេសាទក្នុងដែននេសាទល្អៗ ប្រការនេះពួកគាត់ងាយ រំលោភក្នុងកន្លែងបំរុងទុក និងចូលជ្រុលទៅក្នុងព្រំប្រទល់ឡូត៍នេសាទ ដើម្បីហើយសមត្ថភាពចាប់ពួកគាត់បាន ច្រើនឡើង (ហាមេត, ១៩៩៨ និង ១៩៩៦)។

## តារាង៣,១៦ ចំនួនគ្រួសារចូលរួម ក្នុងការនេសាទគ្រួសាររដូវពេល បើកនេសាទ នៅតាមដែននេសាទនានា តាមខេត្ត កម្ពុជា, ១៩៩៦

| ដែននេសាទ | ភ្នំពេញ (n=95) | កណ្ដាល (n=340) | កំ.ចាម (n=447) | កំ.ឆ្នាំង (n=257) | សៀមរាប (n=203) | ពោធិសាត់ (n=238) | បាត់ដំបង (n=287) | កំ.ធំ (n=340) | សរុប (n=340) |
|---|---|---|---|---|---|---|---|---|---|
| ទន្លេសាប | ០ | ០ | ០ | ៤ | ៣៣ | ២ | ០ | ៦ | ៤៥ |
| បឹងទន្លេសាប | ១៣ | ៥ | ៣៧ | ១៥០ | ១២ | ០ | ០ | ០ | ២១៧ |
| វាលស្រែលិចទឹក | ២១ | ៧៦ | ៧១ | ៥៨ | ៥៦ | ១៦ | ១៤១ | ៣៥ | ៥១៨ |
| មេគង្គក្រោម | ០ | ១១ | ១៣១ | ១ | ១ | ០ | ០ | ០ | ១៤៤ |
| ទន្លេបាសាក់ | ០ | ៣០ | ១២ | ២ | ៥ | ២ | ០ | ១ | ៥២ |
| បឹងនិងព្រែកតូចៗ | ២៧ | ២៦៨ | ១៦៩ | ១២២ | ១៤៧ | ២៥៧ | ២៤៥ | ៧០ | ១២០៥ |
| ព្រៃលិចទឹក | ១៦ | ៦៤ | ៣៣ | ៦៧ | ៨១ | ៣០ | ១៥៧ | ២៥ | ៥១៧ |
| ផ្សេងៗ | ០ | ០ | ០ | ០ | ០ | ០ | ១ | ០ | ១ |
| **សរុប/a** | **៧៧** | **៤៥៤** | **៤៥៣** | **៤០៤** | **៣៧៥** | **២..៧** | **៥៨៤** | **១៤៥** | **២៦៩៩** |

ប្រភព: ហាមេត (១៩៩៨)

/a គំនត់ពីគ្រួសារដែលចូលរួមនេសាទ។ រួមបញ្ចូលចំនួនសរុបគ្រួសារដែលចូលរួមក្នុងនេសាទគ្រួសារ ក្នុងខេត្តមួយចំនួន ហើយគ្រួសារខ្លះនេសាទក្នុងដែលនេសាទ ច្រើនជាងមួយ។

## តារាង៣,១៧ ចំនួនគ្រួសារចូលរួម ក្នុងការនេសាទគ្រួសាររដូវពេល បិទនេសាទ នៅតាមដែននេសាទនានា តាមខេត្ត កម្ពុជា,១៩៩៦

| ដែននេសាទ | ភ្នំពេញ (n=95) | កណ្ដាល (n=340) | កំ.ចាម (n=447) | កំ.ឆ្នាំង (n=257 | សៀមរាប (n=203) | ពោធិសាត់ (n=238) | បាត់ដំបង (n=287) | កំ.ធំ (n=340) | សរុប (n=340) |
|---|---|---|---|---|---|---|---|---|---|
| ទន្លេសាប | ០ | ០ | ០ | ៤ | ៣ | ៤ | ០ | ០ | ៤៣ |
| បឹងទន្លេសាប | ២៨ | ៣ | ២៧ | ១៣៦ | ៦ | ០ | ០ | ៦ | ២០៦ |
| វាលស្រែលិចទឹក | ៤៣ | ៦០ | ១១៧ | ៦៧ | ១០៧ | ២០៤ | ១១១ | ៤៥ | ៧៦៣ |
| មេគង្គក្រោម | ៨ | ១១ | ១៣៣ | ០ | ១ | ០ | ០ | ០ | ១៥៣ |
| ទន្លេបាសាក់ | ៤ | ២៤ | ១៦ | ២ | ៤ | ២ | ០ | ១ | ៥៣ |
| បឹងនិងព្រែកតូចៗ | ៣៦ | ២៦៤ | ២១៥ | ១២៤ | ៩៣ | ១២៥ | ២១៧ | ៧២ | ១១៤៦ |
| ព្រៃលិចទឹក | ២៧ | ៥៦ | ៥០ | ៧៧ | ៨០ | ៣៣ | ១៤៨ | ៣១ | ៥០២ |
| ផ្សេងៗ | ១ | ០ | ០ | ០ | ០ | ០ | ០ | ០ | ១ |
| **សរុប/a** | **១៤៧** | **៤១៨** | **៥៥៨** | **៤១៩** | **៣២៦** | **៣៦** | **៤៧** | **១៥៥** | **២៨៦៧** |

ប្រភព: បាមេត (១៩៩៨)

/a គំនត់ពីគ្រួសារដែលចូលរួមនេសាទ។ រួមបញ្ចូលចំនួនសរុបគ្រួសារដែលចូលរួមក្នុងនេសាទគ្រួសារ ក្នុងខេត្តមួយចំនួន ហើយគ្រួសារខ្លះនេសាទក្នុងដែលនេសាទ ច្រើនជាងមួយ។

ផលនេសាទនៃលក្ខណៈនេសាទគ្រួសារ ប្រែប្រួលពី ១១៥.០០០ ទៅ ១៤០.០០០ តោនក្នុង១ឆ្នាំ ដែលចូលរួមចំណែក ៣២.៥ ភាគរយនៃផលិតនេសាទទឹកសាបសរុប ដែលរាប់បញ្ចូលទាំង ការនេសាទតាមវាលស្រែ( តារាង ៣.៩) ។ ក្នុងរយៈ ពេល ១៥ ឆ្នាំក្រោយនេះ ផលចាប់នៃលក្ខណៈគ្រួសារ ពុំឃើញមាននៅក្នុងតារាងស្ថិតិរដ្ឋាភិបាល ដែលគេពុំបានផ្តោត ការយល់យកចិត្តទុកដាក់ទៅលើ ជីវភាពរស់នៅរស់ប្រជាជនក្រីក្រ ដែលពួកគេពឹងផ្អែកទៅលើ ធនធានជលផលសំរាប់សន្តិសុខស្បៀងរស់ពួកគេ ហើយនឹងការង្កើនប្រាក់ចំណូល។ ថ្មីៗនេះការនេសាទគ្រួសារត្រូវបានទទួលស្គាល់ទាំងស្រុងហើយរដ្ឋាភិបាល (នាយកដ្ឋានជលផល/ក្រសួងកសិកម្ម) ព្រមទទួលយកផលចាប់នៃនេសាទគ្រួសារពី គ្រោងការគ្រប់គ្រងនេសាទទឹកសាកម្ពុជា ក្នុងឆ្នាំ ១៩៩៨ ដោយសារពួកគេមិនមានថវិកាគ្រប់គ្រាន់ ដើម្បីធ្វើការស្រាវជ្រាវនិងប្រមូលទិន្នន័យ និងពត៌មាន។ នាយកដ្ឋានជលផលបានជំរុញ អោយការិយាល័យជលផលខេត្ត-ក្រុងទាំង២៤ ចាប់អារម្មណ៍យ៉ាងផុលផុស ប្រមូលទិន្នន័យទាំងនេះ ហើយផ្តោតទៅលើខេត្តដែលមានទីតាំងនៅឆ្ងាយពី បឹងទន្លេសាប ទន្លេមេគង្គ និងទន្លេបាសាក់ ដូចជា ខេត្តកំពង់ស្ពឺ រតនគិរី មណ្ឌលគិរី ព្រះវិហារ និង ឧត្តរមានជ័យ ដែលមិនសូវសំបូរធនធានជលផល ។

តារាង ៣.១៥ បង្ហាញពីភាគរយ និងចំនួនគ្រួសារដែលចូលរួម ក្នុងការនេសាទគ្រួសារ ក្នុងខេត្តទាំង ៨ ជុំវិញបឹងទន្លេសាប និងតំបន់មេគង្គបាសាក់ ផលចាប់ជាមធ្យមក្នុង១គ្រួសារ និង ផលចាប់សរុបនៃការនេសាទគ្រួសារក្នុងខេត្តទាំងនោះ ។ ត្រី១៥ប្រភេទសំខាន់ត្រូវបានបង្ហាញក្នុងតារាង ៣.១០។

ប្រភេទឧបករណ៍/សំភារៈ នេសាទ គឺអាស្រ័យទៅលើលក្ខខណ្ឌបរិស្ថាន និង ប្រភេទត្រីដែលត្រូវចាប់។ មានការកំនត់ តឹងរឹងនូវប្រភេទឧបករណ៍នេសាទ ដែលអាចប្រើប្រាស់បានក្នុងការនេសាទ( តាណា, ១៩៧១)។ អ្នកនេសាទគ្រួសារប្រើប្រាស់ឧបករណ៍នេសាទ តូចជាងការនេសាទសិប្បកម្ម និងការនេសាទទ្រង់ទ្រាយធំចំនួនខ្នងផ្ទះប្រហែល ១០២.៦០៣ ( ៦៥% នៃប្រជាជនសរុប ទាក់ទងទៅនឹងការនេសាទដែលមានទ្រង់ទ្រាយ ជាគ្រួសារ ) មកពីខេត្តទាំង០៨ ដែលប្រើប្រាស់អួនក្រឡាតូចក្នុងកំឡុងពេលរដូវបិទនេសាទ ។ ចំនួនខ្នងផ្ទះប្រមាណ ៤៤.៣៤២ (២៨%)បានប្រើប្រាស់ទ្រូឬលបធ្វើពីផ្តៅ និងឫស្សី ។ ឧបករណ៍ស្ទូ សំណាញ់ និងសន្ទូចផ្លែមួយ ក៏ត្រូវបានប្រើប្រាស់ដោយអ្នកនេសាទជាលក្ខណៈគ្រួសារទាំងរដូវនេសាទ និងរដូវបិទនេសាទ ១ហាមដេ តេ ាល ។១៩៩៨ថ។

(Ahmed et al., 1998) ក៏បានរាយការណ៍ផងដែរថា ក្រៅពីការធ្វើការនេសាទដោយផ្ទាល់ ប្រជាជនមួយចំនួនធំមាន ជាប់ទាក់ទងនឹងសកម្មភាពនេសាទផ្សេងៗដូចជាការកែច្នៃផលិតផលត្រី ព្រួល ឬសិងធ្វើពីឫស្សី ការផលិតឬការជួសជុលមង ឬសំណាញ់ ការទិញ-លក់ត្រី ជុំ ឬរាយ និងការចំរាញ់យកខ្លាញ់ត្រី ។ ការកែច្នៃ ផលិតផលត្រីគឺជាសកម្មភាពសំខាន់តែមួយគត់នៅក្នុងឃុំនេសាទឯករាជ្យ ។ ចំនួនសរុប ៣០% នៃចំនួនខ្នងផ្ទះ បានរាយ ការណ៍ថាមានការពាក់ពាន់ទៅនឹងការកែច្នៃផលិតផលត្រី ដែលជាសកម្មភាពប្រកបជីវភាពរស់នៅដ៏សំខាន់មួយ ។ ការលក់ត្រីនិងការផលិតមង សំណាញ់ គឺធ្វើឡើងដោយប្រជាជន ១៥% និង១១% ។

ដូច្នេះការនេសាទត្រី និងសកម្មភាពទាក់ទងនឹងការនេសាទ គឺមានសារៈសំខាន់សំរាប់ជីវិតរស់នៅប្រចាំថ្ងៃរបស់អ្នកនេសាទជាលក្ខណៈគ្រួសារ ។ ទិដ្ឋភាពខាងក្រោមនេះ ជីវភាពរស់នៅរបស់អ្នកនេសាទជាលក្ខណៈគ្រួសារ និងធនធានក្នុងទឹក ជាពិសេស គឺការនេសាទដែលត្រូវគេបានលើកមកពិភាក្សា ។

ជីវិតរស់នៅរបស់អ្នកប្រកបរបរនេសាទ និងការប្រើប្រាស់ធនធានក្នុងទឹកមិនបានល្អអ្នកនិពន្ធ ជាច្រើនបានរាយការណ៍ថា ធនធានក្នុងទឹក (ជាពិសេសការនេសាទត្រី) បានដើរតួរនាទីយ៉ាងសំខាន់ក្នុង សន្តិសុខម្ហូបអាហាររបស់ប្រជាជនក្រីក្រ ។ ការសិក្សាស្រាវជ្រាវត្រូវបានគេធ្វើឡើងនៅតំបន់បីផ្សេងៗគ្នា ដូចជា សហគមន៍ដែលធ្វើសកម្មភាពនេសាទត្រីខ្នាំងក្បាលនៅតំបន់បឹងទន្លេសាប និងទន្លេមេគង្គ ឬទន្លេបាសាក់ (ហាមេត, ១៩៩៨) ហគមន៍គោលដៅសង្គ្រោះមានរយះពេលយូរ ដែលភាគច្រើនជាប្រជាជនគ្មានទីជំរកនៅតំបន់ខ្ពស់ (ហេលម៉ែរ និងហ គិនិហ្វិក,១៩៩៩) និងសហគមន៍កសិករនៅតំបន់ទំនាបដែលមានឱកាសតិចតួចដើម្បីយល់ដឹងពី ផលិតភាពដី (ហ្វ្រិកកូរី, ១៩៩៩)។ ប្រធានបទរួមនៃការសិក្សានេះគឺធ្វើការសាកល្បងលើប្រជាជនរស់នៅជនបទ ដាច់ស្រយាល បានបង្ហាញថា ត្រីគឺជាអាហារ ដ៏ចំបងដែលត្រូវបាននាំយក ឬក៏ទិញ ដែលជាការចែកចាយជា ភាគរយពីប្រភព ដោយពឹងផ្អែកលើតំបន់ ដែលអាចរកត្រីបានរបស់ប្រជាជន ។

ហ្គាម (២០០០) បានរាយការណ៍ថា ការប្រើប្រាស់តំបន់នេសាទបាន គឺជាប្រធានបទដ៏សំខាន់មួយតាមរយៈអក្សរសាស្ត្រ ដែលបានកែសំរួល ។ ការប្រើប្រាស់តំបន់នេសាទមានកត្តាសំខាន់ពីរគឺ តំបន់ដែលអាចប្រើប្រាស់បានដើម្បីនេសាទត្រី និងសិទ្ធិដែលអាចប្រើប្រាស់បានដើម្បីនេសាទត្រីនៅតំបន់ទាំងនេះ ។ តំបន់ដែលអាចប្រើប្រាស់បានដើម្បីនេសាទត្រី មានដូចជា បឹង ប្រឡាយ ព្រែកជីក វាលស្រែ ព្រៃរនាម ។ល។ ដែលហាក់ដូចជាមិនជាបញ្ហាសំខាន់ទេ ។ ស្ទើរតែគ្រប់ផ្ទៃដីទាំងអស់នៃប្រទេសកម្ពុជាលាតសន្ធឹងដោយតំបន់ទំនាបលិចទឹកទន្លេមេគង្គ ហើយនាយកដ្ឋានជលផលបានចាត់ទុកខេត្តចំនួន១៣ ក្រៅពីខេត្ត-ក្រុងទាំង២៤ ជាផលិតផលពាណិជ្ជកម្មត្រីទឹកសាប ។ ខេត្តទាំងនេះ មានចំនួនប្រជាជនយ៉ាងច្រើនកុះករហើយអាចសន្មតថាមានតំបន់នេសាទសសំរាប់អោយប្រជាជនភាគច្រើនអាចរកត្រីបាន ។ ដូច្នេះបញ្ហា ចំបងផ្តោតទៅលើសិទ្ធិចំពោះតំបន់នេសាទត្រីទាំងនេះ ។

ហាមេត ១៩៩៨ នៅក្នុងការអង្កេតចំនួនខ្នងផ្ទះចំនួន ៥.១១៧ នៅក្នុងខេត្តចំនួន៨ បានបង្ហាញអោយ ឃើញថា ៩២% នៃប្រជាជនត្រូវបានគេរាយការណ៍ថាពួកគេមានលទ្ធភាពទទួលយកធនធានសម្បត្តិរួម (CPRs) មានដូចជា: ព្រៃឡេវម ទន្លេ ស្ទឹង បឹង ស្រែលិចទឹក ទំនប់ប្រឡាយ ដែលស្ថិតនៅខាងក្នុង និងខាងក្រៅឃុំរបស់ពួកគេ ការប្រើប្រាស់ដីចំបងនៃតំបន់ទាំងនេះរួមមានការប្រមូលផ្តុំស្បៀង ការដាំស្មៅសំរាប់បសុសត្វ ការដាំដំណាំ និងការប្រើប្រាស់ទឹក។ នឹងអាចមានឥទ្ធិពលអវិជ្ជមានដ៏សំខាន់មួយទៅលើជីវភាពរស់នៅរបស់ប្រជាជន។ ជាពិសេសចំពោះគ្រួសារតូចតាចដែលជំរើសរបស់ពួកគេមានកំរោត់ ប្រសិនបើលក្ខខណ្ឌតឹងរឹងត្រូវបានគេដាក់ទៅលើការនេសាទនេះ និងការធ្វើអាជីវកម្មពីតំបន់សម្បត្តិរួមទាំងនេះ ។

ឌីកហ្គិន (២០០០) វ៉ាន់ហ្សាលីង និងធូក (១៩៩៩) ធូន និងស៊ុណោ (១៩៩៧) ហ្គាម និង ហាមេត (១៩៩៦) បានផ្តល់ពត៌មានថា សមាសភាគការនេសាទជាលក្ខណៈគ្រួសារនៃ ការរកត្រីរបស់ជាតិ គឺត្រូវបាន ចាត់ទុកជាកត្តាសំខាន់ដូចសមាសភាគជាលក្ខណៈពាណិជ្ជកម្ម ក្នុងន័យផលិតកម្ម និងការចែកចាយ ។

ក្នុងការសិក្សាស្រាវជ្រាវដំណាក់កាលពាក់កណ្តាល នៅក្នុងស្រុកចំនួន៤របស់ខេត្តបាត់ដំបង បានបង្ហញថាការប្រើប្រាស់ ប្រភពនៃការនេសាទមិនគ្រាន់តែផ្តល់នូវប្រភពស្បៀងអាហារប៉ុណ្ណោះទេ តែផ្តល់នូវប្រភពជាសាច់ប្រាក់យ៉ាងសំខាន់ផងដែរ ។ ៧០ ទៅ ៩០% នៃចំនួនខ្នងផ្ទះសរុបទាំងអស់ ដែលបានធ្វើបទសម្ភាស (បីផ្នែក : ទីមួយ គ្រួសារដែលគ្មានដីធ្លី ទីពីរ គ្រួសារដែលមានដី និងសត្វពាហនៈ ទីបី គ្រួសារដែលមានដី តែគ្មានសត្វពាហនៈ) បានបញ្ជាក់ថា

មានភាពសកម្មក្នុងការនេសាទត្រី ហើយ ២០ ទៅ ៤២% សកម្មនឹងការប្រមូលរុក្ខជាតិដុះក្នុងទឹក ។ ចំនួនខ្នងផ្ទះមួយចំនួនដែលបានធ្វើបទសម្ភាសបានឈប់ប្រើប្រាស់ដីស្រែ ( លិចទឹក កណ្ដុរច្រើន និងមានការបរាជ័យខ្លាំងនៃ ផលិតផល ដំណាំ) និងត្រូវបានរាយការណ៍ថា ការនេសាទត្រីធ្វើអោយគ្រួសារមានលទ្ធភាពទិញម្ហូបអាហារបាន។

ឌីកហ្គីន (២០០០) ទោះបីជាយ៉ាងណាក៏ដោយ បានប្រាប់អោយដឹងថា ទោះជាសារៈសំខាន់នៃការ នេសាទជាលក្ខណៈគ្រួសារ វាគឺមិនត្រូវបានគេរាប់បញ្ចូលយ៉ាងច្រើនពីនយោបាយគ្រប់គ្រងការនេសាទ ។ ជាងនេះទៅ ទៀត ពួកគេបានសង្កេតឃើញថា យុទ្ធសាស្ត្រជីវិតរស់នៅជាលក្ខណៈគ្រួសារជនបទ ដែលរួមគ្នាជាមួយនឹងកត្តានៃការ ប្រើប្រាស់ធនធានសម្បត្តិរួម និងឯកជន បានផ្ដល់នូវការប្រើប្រាស់ដែលមានសមធម៌ ដោយគ្មានសេចក្ដីត្រូវការនៃ ដើម ទុនដំបូង ។ ជាងនេះទៅទៀត ការនេសាទគឺជាធនធានសម្បត្តិរួមយ៉ាងច្រើន និងមានតំរូវការដើម្បីកំណត់នូវ សិទ្ធិអ្នក ប្រើប្រាស់ក្នុងការនេសាទជាមួយវា និងភាពមានសិទ្ធិនៃការចែកចាយ ។

ការគំរាមកំហែងពិតប្រាកដចំពោះជីវភាពរស់នៅរបស់អ្នកជនបទ គឺការបញ្ចូលគ្នានៃការគាបសង្កត់ដីដែលចេះតែកើនឡើង និងការថយចុះនៃការចូលទៅដល់ធនធានសម្បត្តិរួម វ៉ាន់ អាកយ័រ(១៩៩៩) ។ ជាងនេះទៅទៀង ការថយចុះនៃ ការចូលទៅដល់ធនធានសម្បត្តិរួម នឹងប៉ះពាល់ដល់ជីវភាពរស់នៅរបស់គ្រួសារក្រីក្របន្ថែមទៀត បើប្រៀបធៀបទៅ នឹងប្រជាជនដែលមានទ្រព្យសម្បត្តិច្រើន និងជីវភាពធូរធារ។ ស្រដៀងគ្នានេះដែរ កាតូ(១៩៩៩) ក្នុងការសិក្សាស្រាវជ្រាវរបស់នាងចំពោះប្រជាជនដែលគ្មានដីធ្លី នៅខេត្តតាកែវ បានបញ្ជាក់ថា ការប្រើប្រាស់ ធនធានសម្បត្តិរួមបានក្លាយទៅតឹងរឹងបន្ថែមទៀត តូចទៅៗ និងមានតំលៃថ្លៃ ភាពក្រីក្រ និងភាពដែលអាចគ្រោះ ថ្នាក់នៃប្រជាជនក្រីក្រកម្ពុជា នឹងមានកាន់តែច្រើនឡើងៗ ។

ការសិក្សាទៅលើយុទ្ធសាស្ត្រនៃជីវភាពរស់នៅ នៅក្នុងខេត្តពោធិសាត់ បានអោយដឹងថា ចំនួនប្រជាជនភាគច្រើននៅ ភាគពាយព្យនៃប្រទេសកម្ពុជា គឺពឹងផ្អែកទៅលើប្រព័ន្ធកសិកម្ម និងចំណើសត្វជាលក្ខណៈគ្រួសារ ។ ដូច្នេះ យុទ្ធសាស្ត្រ នៃជីវភាពរស់នៅតាមជនបទជាធម្មតា គឺជាតុល្យភាពរវាង ារប្រើប្រាស់ដីកសិកម្ម (កម្មសិទ្ធិឯកជន) និងការនេសាទ និងព្រៃឈើ (កម្មសិទ្ធិរួម) ។ ទោះបីជាយ៉ាងណាក៏ដោយ ក្នុងអត្ថបទកម្ពុជាជនបទ ការប្រើប្រាស់សមហេតុសមផល នៃធនធានសម្បត្តិរួមនៅក្នុងការបញ្ចូលគ្នាជាមួយផលិតផលកសិកម្ម នឹងជាយុទ្ធសាស្ត្រដែលមាននិរន្តភាពយូរអង្វែង សំរាប់សន្តិសុខស្បៀង ជាជាងពឹងផ្អែកទៅលើផលិតផលកសិកម្មតែឯង ។

អាហ្សីមី (២០០០) បានកត់សំគាល់ថា ១៥% នៃចំនួនប្រជាជនកម្ពុជា បាននិយាយដោយពឹងផ្អែកការនេសាទនៅបឹងទន្លេសាបសំរាប់ជីវភាពរស់នៅរបស់ពួកគេ ហើយ ធូក និងស៊ីណា(១៩៩៧) បានប៉ាន់ស្មានថា ៨៨ % នៃចំនួនប្រជាជននៅ ១៧០ ភូមិ នៅក្នុង និងជុំវិញតំបន់ព្រៃលិចទឹក តាមជាយបឹងទន្លេសាប គឺពឹងផ្អែក ការនេសាទ និងសកម្មភាពទាក់ទងនឹងការនេសាទ ។ ហ្គាម (១៩៩៨) បានចងក្រងឯកសារអំពីការពឹងពាក់ស្ទើរតែ ទាំងស្រុងទៅលើការនេសាទតាមតំបន់ និងធនធានព្រៃឈើ នៃភូមិចំនួន ១២ (មានប្រជាជនចំនួន ១៣.០០០ នាក់) ដែលស្ថិតនៅក្នុងតំបន់ព្រៃលិចទឹក ។ ធូក និងស៊ីណា(១៩៩៧) បានបញ្ជាក់ថា ៦៧% នៃចំនួនប្រជាជន នៅឃុំ កំពង់ឃ្លាំង នៅខេត្តសៀមរាប ដែលជាតំបន់ស្ថិតនៅក្នុងតំបន់ព្រៃរនាម មានដីធ្លីបន្តិចបន្តួច និងពឹងផ្អែកលើ ការនេសាទ ។

EWG (2000), Cheav (2000) , Phiak (2000) and PFO (2000) បានរាយការណ៍ថា ៩០% នៃ ប្រជាជន ( មកពីក្រុមកុលសម្ព័ន្ធផ្សេងគ្នាទាំង៩ ) រស់នៅតាមបណ្តោយដងទន្លេមេគង្គទាំងបួន និងដៃទន្លេសំខាន់ៗរបស់ខ្លួននៅ ទន្លេសេកុង ទន្លេសេសាន និងស្រែពកនៅខេត្តស្ទឹងត្រែង ភាគឦសាននៃប្រទេសកម្ពុជា ពឹងផ្អែកទៅលើការនេសាទ សំរាប់ការរស់នៅ និងម្ហូបអាហារប្រចាំថ្ងៃរបស់ពួកគេ ។ ប្រជាជនទាំងនេះពឹងផ្អែកយ៉ាងខ្លាំងទៅលើការនេសាទ និងការប្រមូលបន្លែដុះតាមទន្លេសំរាប់ជាម្ហូបអាហារ និងថ្នាំ ព្រមទាំងការប្រមូលពងនៃសត្វបក្សី និងសត្វល្អូនដែល ធ្វើសំបុកនៅបាតទន្លេ ។

**ការនេសាទតាមវាលស្រែ**

ការនេសាទតាមវាលស្រែគឺមិនបានកំណត់នៅក្នុងក្រឹត្យច្បាប់ជលផលឆ្នាំ១៩៨៧ កន្លងមក និងច្បាប់កែសំរួលថ្មីឆ្នាំ ១៩៩៩ ។ តាណោ (១៩៩០)បានគូសបញ្ជាក់ថា ក្នុងខណៈដែលការនេសាទនៅវាលស្រែ គឺជាប្រភពដ៏សំខាន់មួយនៃការគាំទ្រជីវភាពរស់នៅ ។ ជាទូទៅ ការនេសាទនេះមិនត្រូវបានគ្រប់គ្រងជាផ្លូវការដោយទីភ្នាក់ងាររដ្ឋាភិបាលណាមួយឡើយ ទោះបីជាពួកគេស្ថិតនៅក្នុងនាយកដ្ឋានជលផលក៏ដោយ (DoF) ។

ប្រព័ន្ធអេកូឡូស៊ីតាមវាលស្រែ គឺសំបូរទៅដោយធនធានជីវិតក្នុងទឹក ដូចជា ត្រី កំពឹស ក្តាម ខ្យងសត្វល្អិត និងពពួកបន្លែក្នុងទឹក ដូចជា ត្រកួន ឈូក និងព្រលិត ។ ប្រភពធនធានទាំងនេះត្រូវបានប្រើប្រាស់ដោយ អ្នកក្រីក្រតាមជនបទធ្វើជាធនធានម្ហូបអាហារ និងជីវភាពរស់នៅ ដែលតំណាងអោយធនធានដ៏សំខាន់នៃម្ហូបអាហារ និងប្រាក់ចំណូល ដែលជាប្រពៃណី អាចអនុវត្តទៅដល់ប្រជាជននៅតាមជនបទ ហើយតំរូវអោយមានការវិនិយោគ ដើមទុនបន្តិចបន្តួច ដើម្បីធ្វើអាជីវកម្ម ។ ទោះបីជាយ៉ាងណាក៏ដោយ សារៈសំខាន់នៃធនធានទាំងនេះធនធានទាំងនេះ ជាទូទៅមិនត្រូវបានកោតសរសើរដោយរដ្ឋាភិបាល និង អង្គការអភិវឌ្ឍន៍ និង មានផលវិបាកមួយគឺត្រូវបានគំរាមកំហែងដោយគំរោងដែលជំរុញការផ្លាស់ប្តូរនៃដីជាំទឹក ទៅជាដីកសិកម្ម ការប្រើប្រាស់នៃថ្នាំកសិកម្ម និងការផ្លាស់ប្តូរវាលស្រែដែលលិចទឹក ។

ប្រព័ន្ធក្សេត្រ-បរិស្ថាន ០៤ អាចមានលក្ខណៈប្លែកគ្នា នៃព្រៃលិចជុំវិញបឹងទន្លេសាប និងនៅក្នុងដីសណ្តរដីល្បប់ ដីតាមមាត់ទន្លេ និងដីទំនប់តាមដងទនេមេគង្គ និងទន្លេបាសាក់ និងដីភក់ និងបឹងខាងក្រោយទំនប់ ។ នៅក្នុងប្រទេសកម្ពុជា ផ្ទៃដីប្រហែល ២០% គឺត្រូវបានគេដាំដុះ ហើយ ៨៥ ទៅ ៩០% នៃតំបន់ដាំដុះគឺស្ថិតនៅក្រោមផលិតកម្មស្រូវ ដែលជាទូទៅគឺជាឯកវប្បកម្ម ។ តារាងលេខ ៣.១៨ បង្ហាញប្រព័ន្ធដាំដុះស្រូវនៅប្រទេសកម្ពុជា ។

**តារាងលេខ ៣.១៨ : ប្រព័ន្ធដាំដុះស្រូវនៅប្រទេសកម្ពុជា**

| ប្រព័ន្ធ | រយៈពេលដាំដុះ | ការប្រមូលផល | ទំហំសរុប( % ) | ផលិតផល |
|---|---|---|---|---|
| ដីទំនាបដែលមានភ្លៀងធ្លាក់ | មិថុនា-តុលា ( ស្ទូង ) | តុលា-ធ្នូ | ៨៥ | ១-១.៥ត/ហិកតា |
| ស្រូវឡើងទឹក | ឧសភា-មិថុនា ( ព្រោះ ) | ធ្នូ-មករា | ៦ | |
| ស្រូវប្រដេញទឹក | វិច្ឆិកា-មិនា ( ស្ទូង ) | កុម្ភៈ-មិនា | ៨ | ៣ត/ហិកតា |
| តំបន់ប្រព័ន្ធស្រោចស្រប់ | វិច្ឆិកា-មិនា ( ស្ទូង ) | កុម្ភៈ-មិនា | <១ | ៣ត/ហិកតា |
| ដីតំបន់ខ្ពស់ | មេសា-មិថុនា ( ព្រោះ ) | ធ្នូ | <១ | |

Oversen et al, 1996

ទឹកជំនន់ និងគ្រោះរាំងស្ងួត បានប៉ះពាល់ដល់ការប្រមូលផលជាញឹកញាប់ ។ ជាទូទៅ ដីគ្មានជីជាតិ ជាពិសេសនៅខេត្តកំពង់ស្ពឺ ខេត្តកំពង់ឆ្នាំង និងខេត្តតាកែវ ក្រៅពីឯកវប្បកម្មស្រូវដែលលេចធ្លោជាងគេ ជីវភាពគ្រួសារ កសិករមួយចំនួនពឹងផ្អែកលើស្រូវ និងស្ករត្នោត ។ ដីខ្សាច់គ្មានជីជាតិនៅតាកែវគឺសមរម្យណាស់សំរាប់ដើមត្នោត ។ តំលៃប្រាក់ចំណូល ជាសាច់ប្រាក់បានមកពីដើមត្នោតធ្វើស្ករចំនួន២០ដើម គឺស្មើនឹងតំលៃស្រូវ០១ហិកតា ។ (Oversen, 1996) ៕

## រយៈពេលដែលមិនសូវបានផលល្អគឺចាប់ពីពាក់កណ្តាលខែកក្កដា ទៅដល់ពាក់កណ្តាលខែតុលា ដែលស្របគ្នានៅនឹង

រយៈពេលនៃការប្រមូលផលស្រូវ និងមុនការប្រមូលផលស្រូវ ។ មធ្យោបាយជាច្រើនដើម្បីផ្តល់ឥណទានក្នុងកំឡុងរយៈពេលនេះ ។ ធនធានជីវិតក្នុងទឹកត្រូវបានប្រមូលនៅខែកក្កដា និងខែសីហា ។ ការស្វែងរកចំណីសត្វរាល់ថ្ងៃ នៅក្នុង និងជុំវិញវាលស្រែបានផ្តល់នូវបន្លែដែលដុះដោយធម្មជាតិ ដូចជា ក្រអៅឈូក ត្រី កង្កែប និងសត្វល្អូន ។ ការសិក្សានៃសមាមាត្រប្រាក់ចំណូលតាមប្រភព នៅខេត្តចំនួន០៣ បានបញ្ជាក់ថា ការបរបាញ់ /ការប្រមូល មានចំនួន ១៨ -១៩% នៃប្រាក់ចំណូល (សមាមាត្រស្រដៀងគ្នានេះបានមកពីពលកម្មរបស់មនុស្សប្រុស ) (Murshid, 1998) ស្ត្រី និងកុមារជារឿយៗធ្វើកិច្ចការនេះដែរ ។

ការនេសាទតាមវាលស្រែនៅក្នុងប្រទេសកម្ពុជា ត្រូវបានធ្វើការសិក្សាដោយ គ្រិចគូរី(១៩៩៨) គ្រិចគូរី និង ហ្គាតមេន (១៩៩៩) ស្តីអំពីទស្សនៈទូទៅនៃការនេសាទតាមវាលស្រែនៅខេត្តស្វាយរៀង (នៅភាគអគ្នេយ៍ប្រទេស) និង ដោយ ហ្គាម (១៩៩៨) នៅខេត្តបាត់ដំបង ហ្សាម និងហាមេត (១៩៩៦ នៅខេត្តពោធិសាត់ ហ្សាម និងហុងនៅខេត្តកំពង់ធំ និង ហាមេត(១៩៩៨) នៅខេត្តចំនួន០៨ ដែលនៅជុំវិញបឹង ទន្លេសាបនៅភាគពាយព្យ ប្រទេសកម្ពុជា ។

ការរកត្រីតាមវាលស្រែសរុប គឺចាប់ពី ៤៥,០០០-១១០,០០០ តោន ក្នុងមួយ យោលទៅតាម តំបន់ភូមិសាស្ត្រ និងរដូវដែលចូលរួមចំណែក ១៦-២៦% ចំពោះការនេសាទចាប់ត្រីនៅទឹកសាប (តារាងទី ៣.៩) ហាមេត (១៩៩៨) បានរាយការណ៍ថា ទិន្នផលត្រីដែលចាប់បានពីវាលស្រែគឺមានចាប់ពី ២៥-៦២ គីឡូក្រាម ក្នុងមួយហិកតានៃ វាលស្រែ ១,៨ ហិកតា នៅក្នុងប្រទេសកម្ពុជា បើប្រៀបធៀបទៅនឹង ៥០ គីឡូក្រាម ក្នុងមួយហិកតា នៅខេត្ត ស្វាយរៀង គ្រិចគូរី និងហ្គាតមេន (១៩៩៩) ហ្គាតមេន (១៩៩៩) ១៨% នៃវាលស្រែនេះ មានសត្វរស់នៅក្នុងទឹក ច្រើនជាងត្រី មានដូចជា កំពឹស កង្កែប ខ្យង និងក្តាម ។ ពួកសត្វទាំងនេះមានតំលៃចំពោះ ការចាប់តាមវាលស្រែ ប្រមាណប្រហែល ១០០ ដុល្លា ក្នុងមួយគ្រួសារ ក្នុងមួយឆ្នាំ ដែលបានកើនឡើងដល់ ៤២% នៃតំលៃមធ្យមសរុបនៃផលិតកម្មស្រូវរបស់គ្រួសារដែលបានធ្វើការសិក្សាស្រាវជ្រាវ ។

អ្នកនេសាទជាលក្ខណៈគ្រួសារ មិនគ្រាន់តែយកចិត្តទុកដាក់ជាចំបងទៅលើស្ទឹង និងបឹងតូចៗ ប៉ុណ្ណោះទេតែថែមទាំង ទៅលើវាលស្រែលិចទឹកផងដែរ (រដូវនេសាទមានចំនួន ២៦% និងរដូវបិទនេសាទមានចំនួន ៣៩%) នៅក្នុងខេត្តដែលបានជ្រើសរើសទាំង០៨ស្ថិតនៅជុំវិញបឹងទន្លេសាប និងទន្លេមេគង្គ-បាសាក់ ដើម្បីប្រមូលសត្វ និងរុក្ខជាតិដែលរស់នៅក្នុងទឹក សំរាប់អាហារប្រចាំថ្ងៃ និងចំណូលក្នុងគ្រួសាររបស់គេ ( ចូរមើលតារាង ៣.១៦ និង ៣.១៧ ) ។

### ៣.៤.៩ វារីវប្បកម្ម និងជីវភាពរស់នៅក្នុងប្រទេសកម្ពុជា

នៅក្នុងក្រឹត្យច្បាប់ជលផលពីមុននៅឆ្នាំ (១៩៨៧) គឺជាវិស័យថ្មីមួយនៃការអភិវឌ្ឍន៍ ច្បាប់វារីវប្បកម្មដ៏ជាក់លាក់ ដែលមានទំនាក់ទំនងទៅនិងបរិស្ថាន ការស្រាវជ្រាវ ការអភិវឌ្ឍន៍ និងការគ្រប់គ្រង និងសន្តិសុខស្បៀងជនបទ គឺមិនអាចធ្វើទៅបានទៅបានឡើយ ។ ដូច្នេះ គឺគ្មាននិយមន័យស្របច្បាប់នៃវារីវប្បកម្ម ។ ទោះបីជាយ៉ាងណាក៏ដោយ កសិដ្ឋានវារីវប្បកម្មនៅក្នុងស្រះ ក្នុងស៊ង ឬបែរ ដែលមានទំហំលើសពីកន្លះហិកតា ឬបែរ / ស៊ង ដែលមានទំហំ លើសពី ១៥ ម$^{២}$ ការចិញ្ចឹមក្រពើច្រើនជាង ០៥ ក្បាល អណ្តើកច្រើនជាង ៤០ ក្បាល ការចិញ្ចឹមពស់ថ្លាន់ ឬពស់អត់ពីសច្រើនជាង ២០ ក្បាល ការបង្កើតកន្លែងលក់ ការកែច្នៃផលិតផលត្រីក៏វិតមធ្យមដែលច្រើនជាង ០១ តោនក្នុងមួយឆ្នាំ ឬឧស្សាហកម្មកែច្នៃផលិតផលត្រី អាចនឹងកើតមានឡើងជាយថាហេតុ ដែលមានការអនុញ្ញាត (មាត្រាទី១៩ ជំពូកទី២ មាត្រាទី៣០ ជំពូកទី៣ នៅថ្ងៃទី៩ ខែមិនា ឆ្នាំ១៩៨៧ មាត្រាទី២ ដែលចេញសេចក្តី ប្រកាស នៅថ្ងៃទី ១០ ខែមករា ឆ្នាំ១៩៨៩ ) ។ ការចេញអាជ្ញាប័ណ្ណ និងការអនុញ្ញាត ត្រូវបានធ្វើឡើងដោយ នាយកដ្ឋានជលផលមន្ទីរជលផលខេត្ត ។

ផលិតកម្មវារីវប្បកម្មសរុប តំលៃ ផលិតកម្មជាភាគរយនៃផលិតផលក្នុងស្រុកដុល និងបុគ្គលិកធ្វើការនិងត្រូវ បានបង្ហាញនៅក្នុតារាងលេខ ៣.១៩ ខាងក្រោមនេះ :

## តារាង ៣.១៩: ផលិតកម្មវារីវប្បកម្ម (តោន)ក្នុងប្រទេសកម្ពុជា (១៩៨៤_១៩៩៨)

| ខេត្ត-ក្រុង | ១៩៨៤ | ១៩៨៥ | ១៩៨៦ | ១៩៨៧ | ១៩៨៨ | ១៩៨៩ | ១៩៩០ | ១៩៩១ | ១៩៩២ | ១៩៩៣ | ១៩៩៤ | ១៩៩៥ | ១៩៩៦ | ១៩៩៧ | ១៩៩៨ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| បន្ទាយមានជ័យ | - | - | - | - | - | - | ២ | ២ | ១០ | ៧ | ៥ | ៥ | ៧ | ២ | ២០ |
| បាត់ដំបង | ១៥២ | ៦៣១៣ | ៣៥០ | ២៥២ | ៤៥០ | ៨០០ | ៨៥០ | ៧៥០ | ១.៣០០ | ១.០០០ | ៥០០ | ២៧៣ | ៤៧០ | ២.២៨៥ | ១.២០០ |
| កំពត | - | ១០០ | - | ១ | ២៥ | - | ២១ | - | ៣១ | ៣០ | ១៥ | ៨៣ | ៤៣ | ៥០ | ៨០ |
| កណ្ដាល | ៦៣៨ | ៤៩៥ | ៦០០ | ៩៧០ | ១.០២០ | ៩៦៥ | ៨៩៩ | ៩៣៧ | ១.៨១៣ | ៧៥០ | ១.១៣៦ | ១.០៤៥ | ១.២៤៥ | ១.៤៥០ | ២.៣០០ |
| ក្រុងកែប | - | - | - | - | - | - | - | - | - | - | - | - | ២ | ៣ | ៤ |
| កោះកុង | - | - | - | - | ៦០ | ៦០ | ១០ | - | ៧០ | ៥០០ | ៩៦០ | ៧៤០ | ១៥ | ២៦៦ | ១.៤៤៣ |
| កំពង់ចាម | ២៨ | ៣៦ | ៣៥ | ៨០ | ១០០ | ២០០ | ៣៣៦ | ៤០០ | ៣២៦ | ៣៩៧ | ២៥០ | ៤៨០ | ៤២០ | ៤១០ | ៤៥០ |
| កំពង់ឆ្នាំង | ២០ | ១៨០ | ១៥០ | ១៣០ | ៤៥០ | ៥៤០ | ១.២១២ | ៥០០ | ៨០០ | ៦០៥ | ១.២១៨ | ១.៦០០ | ១.៧១០ | ១.៨២៦ | ១.៨០០ |
| កំពង់ស្ពឺ | - | ៣៧ | - | ៥ | ១០ | ១០ | - | - | ៧ | ១០ | ២០ | ៥៤ | ២៥ | ១០ | ១៥ |
| កំពង់ធំ | - | ៧០ | ២៨ | ៥០ | ១៥០ | ២៣៨ | ២៦០ | ៣៨០ | ៩៨០ | ១.២០០ | ១.០៥០ | ១.០១០ | ៩៤០ | ១.៥៥០ | ១.៨០០ |
| ក្រចេះ | ៩៦ | ១១៥ | ១២៥ | ១៣០ | ២៤០ | ១៣០ | ៩៣ | ១០៨ | ១០៧ | ១០១ | ៧០ | ១២៤ | ១៥០ | ១០០ | ១០៥ |
| ភ្នំពេញ | ៤១៩ | ៧៥០ | ៦២៥ | ៧៨២ | ១.១១០ | ១.០៥០ | ១.០០៧ | ១.០៥០ | ១.១៤៣ | ១.០០០ | ១.១៥០ | ១.១០៣ | ១.២១០ | ១.០៥០ | ១.២៨៥ |
| ព្រៃវែង | ១៣៤ | ២៨ | ៩៣ | ៤០ | ៦០ | ៦៥ | ៥០ | ១០២ | ១៣៦ | ៩៨ | ១១០ | ៣៦២ | ៣៨៥ | ៤០០ | ៤៥០ |
| ពោធិ៍សាត់ | - | ៩២ | ៨០ | ៨០ | ២៧៥ | ៣០០ | ៤៦០ | ៧៣៦ | ៥៥០ | ៦៥០ | ៨៥៦ | ១.៣៨០ | ១.៤៥០ | ១.២២៦ | ១.៦០០ |
| សៀមរាប | ៩ | ៤៧២ | ១៥០ | ៣៧៤ | ៥៨០ | ១.០០៨ | ៩១៣ | ១.៤១០ | ១.១៤៣ | ១.៣៧២ | ១.០៧០ | ១.០៥០ | ៧៥០ | ៩០០ | ១.២០០ |
| ក្រុងសីហនុ | ២៨ | - | - | - | ១៥ | ៥០ | ៥៧ | ៣០ | ១៣ | ១៥ | ៣៥ | ២២ | ៣៥ | ២៦ | ២៣ |
| ស្ទឹងត្រែង | - | - | - | - | - | ៨ | ១០ | - | ៦ | ៥ | ៥ | ២៧ | ១៩ | ១៥ | ១៥ |
| ស្វាយរៀង | ១៤ | ៤ | - | ៥ | ១០ | ១០ | - | - | ៥ | ៥០ | ៦០ | ៦១ | ៩០ | ១០០ | ១១០ |
| តាកែវ | - | - | - | - | ៤៥ | ១០០ | ២១៥ | ២៩៥ | ៦០ | ១៥០ | ៥០ | ៨១ | ៣០ | ៨០ | ១០០ |
| សរុប(តោន) | ១.៦១០ | ៣.០០០ | ២.២០០ | ២.៥០០ | ៤.៦០០ | ៥.៩៣៨ | ៦.៤០០ | ៦.៧០០ | ៨.៥៥០ | ៧.៤០០ | ៨.២០០ | ៩.៥១០ | ៩.៦០០ | ១១.៧០៩ | ១៤.១០០ |
| តំលៃ(US$លាន) | ១.០ | ១.៨ | ១.៣ | ១.៥ | ២.៨ | ៣.៣ | ៣.៨ | ៤.៨ | ៦.០ | ១១.៤ | ១២.១ | ១៤.៦ | ១៣.៨ | ១៣.៦ | ១៧.២ |
| ផលិតកម្មជា%នៃផលិតផលជលផល | nd | nd | nd | nd | nd | nd | ០.២ | ០.៣ | ០.៣ | ០.៦ | ០.៥ | ០.៥ | ០.៤ | ០.៥ | ០.៦ |
| ចំនួននៃការនាំចេញ (US$) | | | | | | | | | | | | | | | |
| បុគ្គលិកធ្វើការងារ | ១.២៩៣ | ៣.០១៥ | ២.៦៣៣ | ២.៨០៧ | ២.៨៨២ | ៣.១៥៦ | ៣.៩៧៥ | ៤.៦១៣ | ៨.៩៤៤ | ៦.៦៦៧ | ១០.១៩៩ | ១១.២០៣ | ៩.៦០០ | ១០.៦២៨ | ១២.០២៤ |

**ប្រភពមកពី :** *តិន្នន័យឆ្នាំ១៩៩៩ របស់នាយកដ្ឋានជលផល* Nandeesha et al. (1997) So Nam et al. (1996) *ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឆ្នាំ១៩៩៩*

ការចិញ្ចឹមដោយបែរ និងស៊ង ត្រូវបានគេរាយការណ៍ថាមានប្រភពដើមពីប្រទេសកម្ពុជា ដែលជាប្រព័ន្ធផលិតកម្មវារីវប្បកម្មខាងក្នុងដ៏សំខាន់ និងប្រវត្តិសាស្ត្ររបស់ខ្លួនដែលវិលត្រលប់ទៅសតវត្សទី១០ ។ ដោយសារតែការហូរត្រលប់នៃទឹកទន្លេមេគង្គ និងអាងក្លាំងការពារធម្មជាតិបឹងទន្លេសាប ការចាប់ត្រីខាងក្នុង ជាទូទៅគឺនៅរដូវដែលមានត្រីច្រើនបំផុតនៅក្នុងប្រទេសកម្ពុជា ជាពិសេសក្នុងករណី សត្វក្នុងទឹកធំៗដែលស៊ីសាច់ជាអាហារ (ពូជ Pengasuis and Channa ) ដែលត្រូវបាន ចាប់ដោយប្រជាជនភាគច្រើនដែលស្ទាត់ជំនាញ ។ អ្នកនេសាទនៅបឹង ទន្លេសាបជាដំបូង បានស្តុកត្រីដែលចាប់បានយ៉ាងច្រើននៅក្នុងទ្រុងឫស្សី ឬទ្រុងបណ្តែតទឹក ហើយរក្សាអោយត្រីនៅ រស់ដោយផ្តល់ចំណីខ្លះៗ ហើយបន្ទាប់មកចាប់ផ្តើមចិញ្ចឹមបំបែកទៅក្នុងទ្រុងជាក្រុមតូចៗរបស់ពួកគេ ដើម្បីនឹងចិញ្ចឹម អោយធំ និងលក់នៅរដូវហាមឃាត់ ។ ការចាប់ត្រីជំទង់ ជាពិសេសចំពោះការចិញ្ចឹមដោយបែរ និងស៊ង និងការ អោយចំណីទៀងទាត់ពេញមួយរដូវចំបាត់ ទំនងជាការបញ្ចប់នៃដំណើរការវិវត្តរយៈពេលវែងមួយ ។ ដូច្នេះការចិញ្ចឹម ដោយបែ និងស៊ងត្រូវបានអភិវឌ្ឍន៍ និងអនុវត្តន៍ដោយសហគមន៍នេសាទ ដែលមានអន្តរទំនាក់ទំនងយ៉ាងជិតស្និទ្ធ ជាមួយសកម្មភាពនៃការនេសាទ ពីព្រោះបញ្ហានេះនៅតែជាករណី ជាពិសេស នៅក្នុងបឹងទន្លេសាប ។

ការចិញ្ចឹមត្រីតាមស្រះគឺមានប្រភពថ្មីៗនេះ ។ នៅក្នុងកំឡុងឆ្នាំ ១៩៦០ ការចិញ្ចឹមតាមស្រះនៃត្រីកាបចិន (Chinese carps) និងទីឡាប់យ៉ា គឺត្រូវបានគេធ្វើឡើងនៅជុំវិញរាជធានីភ្នំពេញ និងនៅតាមស្រះសួនច្បារ និងដំណាំមួយចំនួន ។ ទោះបីជាយ៉ាងណាក៏ដោយ វាប្រហែលជាដំណើរការមិនល្អទេ ដោយការពិតដែលថា ត្រីដែលចាប់បានពីការនេសាទ គឺវាគ្រប់គ្រាន់និងបំពេញសេចក្តីត្រូវការ និងដោយសារតែភាពចលាចលដែលកើតមានជិតពីរទសវត្សមកហើយ ។

ជាមួយសកម្មភាពនៃការនេសាទ ពីព្រោះបញ្ហានេះនៅតែជាករណី ជាពិសេស នៅក្នុងបឹងទន្លេសាប ។ ការចិញ្ចឹមត្រីតាមស្រះគឺមានប្រភពថ្មីៗនេះ ។ នៅក្នុងកំឡុងឆ្នាំ ១៩៦០ ការចិញ្ចឹមតាមស្រះនៃត្រីកាបចិន (Chinese carps) និងទីឡាប់យ៉ា គឺត្រូវបានគេធ្វើឡើងនៅជុំវិញរាជធានីភ្នំពេញ និងនៅតាមស្រះសួនច្បារ និងដំណាំ មួយចំនួន ។ ទោះបីជាយ៉ាងណាក៏ដោយ វាប្រហែលជាដំណើរការមិនល្អទេ ដោយការពិតដែលថា ត្រីដែលចាប់បានពី ការនេសាទ គឺវាគ្រប់គ្រាន់និងបំពេញសេចក្តីត្រូវការ និងដោយសារតែភាពចលាចលដែលកើតមានជិតពីរទសវត្ស មកហើយ ។

## ការចិញ្ចឹមដោយបែរ និងស៊ង

ប្រព័ន្ធចិញ្ចឹមដោយបែរ និងស៊ង ទំនងជាមានប្រភពនៅបឹងទន្លេសាប បច្ចុប្បន្ន ៧៧% នៃបែរ ស្ថិតនៅក្នុងបឹងទន្លេសាប ទន្លេមេគង្គ ទន្លេបាសាក់ គឺមានតែ ២៣% ប៉ុណ្ណោះដែលគេធ្វើនៅក្នុងបឹង (ចូរមើលតារាងទី៣.២០) ។ ប្រព័ន្ធចិញ្ចឹមដោយបែរបានរាយការណ៍អោយដឹងថា ត្រូវបានគេអនុវត្តតាំងពីមួយសតវត្សមកហើយដោយអនិកជនចិន ហើយក្រោយមកទៀតបានក្លាយជាមានប្រជាប្រិយភាពបំផុតក្នុងចំណោមអនិកជនវៀតណាម ។ ការពង្រីកផលិតកម្មចិញ្ចឹមដោយបែរនៅទឹកសាបដោយចំពូក និងប្រព័ន្ធ នៅប្រទេសកម្ពុជា បានបង្ហាញនៅក្នុងតារាងលេខ ៣.១៩ ។ ការចិញ្ចឹមដោយបែរគឺនៅតែលើសលប់គេសំរាប់វារីវប្បកម្មកម្ពុជា ចាប់ពី ៩០%-៨០% នៅឆ្នាំ ១៩៨៤-១៩៩១ ទៅ ៨០%-៧០% នៃផលិតកម្មវារីវប្បកម្មកំឡុងពេល ១៩៩២-១៩៩៨ ដែលបានមកពីប្រព័ន្ធទាំងនេះ ក្នុងខណៈដែលផ្នែកនៅសល់គឺបានមកពីការចិញ្ចឹមតាមស្រះ (Tana, 1995; Savanary, 1997, DOF,1999) ។ ប្រភេទចិញ្ចឹម

ដោយបែរ និងស៊ង ដ៏សំខាន់ មានដូចជា Tana, Pangasius hypophthalmus (73%) បន្ទាប់មក Channa micropeltes (21%)។ ប្រភេទផ្សេងៗទៀតរួមមាន Puntius sp., Clarias batrachus, Oxyeleotris marmorata, Cirrhinus sp., Puntius altus and Leptobarbus hoevennii ដែលអ្នកនេសាទប្រើដើម្បីក្រុងទុករយៈពេលពីរទៅបីខែ ដើម្បីចិញ្ចឹមអោយធំក្នុងកំឡុងពេលរដូវចាប់ត្រីដ៏ខ្លាំងក្លាហើយបន្ទាប់មកទើងលក់នៅពេលដែលត្រីអត់ស្ទើរសំបូរ។

ការចិញ្ចឹមត្រីដោយបែរ គឺជាបច្ចេកទេសមួយដែលបានអនុវត្តនៅតំបន់មួយចំនួននៅក្នុងបឹងទន្លេសាប (ព័ទ្ធជុំវិញដោយ ខេត្តសៀមរាប ខេត្តបាត់ដំបង ខេត្តពោធិសាត់ ខេត្តកំពង់ធំ និងខេត្តកំពង់ឆ្នាំង) និងនៅតាមទន្លេ ស្ទឹង បឹងជុំវិញទីក្រុង ។ ត្រីតូចៗ (ពូជត្រីអណ្តែង Pangaius) ត្រូវបានគេចិញ្ចឹមទុកនៅក្នុងបែរឬស្សីនៅទឹករាក់ (ជំរៅ១-៣ម) និងជាធម្មតា ត្រូវបាគេលក់នៅពេលវាធំជំទង់ ឬក៏ផ្លាស់ប្តូរទៅក្នុងទ្រុងបណ្តែតទឹកនៅ ពេលដែលទឹកចាប់ផ្តើមឡើង។ ទំហំបែរចាប់ពី ៩០០-៥,០០០ម² (FAO, 1993) វាតូចជាងបន្តិចនៅទន្លេ និងធំជាងបន្តិចនៅបឹង ។

**តារាងលេខ ៣.២០ : ចំនួនទ្រុងបែរត្រី និងស្រះត្រី នៅតាមខេត្ត នៃប្រទេសកម្ពុជា ឆ្នាំ១៩៩៩**

| | ស្រះ | | | | បែរ/ទ្រុង | | | |
|---|---|---|---|---|---|---|---|---|
| | មាន | | ប្រើប្រាស់ | | មាន | | ប្រើប្រាស់ | |
| ខេត្ត | ចំនួន | ម² | ចំនួន | ម² | ចំនួន | ម² | ចំនួន | ម² |
| ភ្នំពេញ | ១១២ | ៥១៦០០០ | ១១២ | ៥១៦០០០ | ៣០៨ | ១៤១៩៦ | ៣០៨ | ១៤១៩៦ |
| កណ្តាល | ៧៥៨ | ៤៨៣១០០ | ៥៩០ | ៤០៩៤៦០ | ១០៥០ | ៨៥៩៥ | ៩៦០ | ៧៦២០ |
| ព្រៃវែង | ១៤៥០ | ១៣៥០០០០ | ១៤៥០ | ១៣៥០០០០ | ៩៤ | ៣៣០០ | ៩៤ | ៣៣០០ |
| តាកែវ | ២៨៧៩០ | ៤៦០៦៤០០ | ៧៨៧ | ១៥៧៤០០ | ២០ | ២៤០ | ២០ | ២៤០ |
| ស្វាយរៀង | ២១០០ | ៤២០០០ | ២១០០ | ៤២០០ | | | | |
| កំពង់ស្ពឺ | ៣៩៨៦ | ១៧៤១៥០០ | ២១០ | ២២២០០ | | | | |
| កំពង់ចាម | ៧៨៧ | ២៩៣០០ | ២៤០ | ៩៧៤០ | ៦៧៥ | ៩៤០០ | ៥៨៥ | ៨៣៥២ |
| ក្រចេះ | ១០៣ | ២០០០០ | ២៥ | ៥០០០ | ១២០ | ១២០០ | ២០០ | ២០០០ |
| ស្ទឹងត្រែង | ១៧ | ២១០០០ | ៥ | ៧០០០ | ៣០ | ៣១៥ | ៣០ | ៣១៥ |
| កំពង់ធំ | ៩០០ | ៩០០០០ | ៦០០ | ៦០០០០ | ៤៥០ | ១៥០០០ | ៣៨០ | ១២៧០០ |
| កំពង់ឆ្នាំង | ៥១ | ៤៨៥០ | ២២ | ២០៩០ | ៤១០ | ៦៣០០ | ៥២០ | ៤៦៨០ |
| ពោធិសាត់ | ៤១៩ | ៧៤០៤៣៨ | ២១៩ | ៤១០០០០ | ៥៣ | ៤៩០០ | ៥៣ | ៤៩០០ |
| បាត់ដំបង | ១៧០ | ៥៤១២៩ | ១៧០ | ៥៤១២៩ | ៤១ | ៥៧៨៩៧ | ៤១ | ៥៧៨៩៧ |
| ប.មានជ័យ | ៦០០ | ៥៨២៩២ | ៦០០ | ៥៨២៩២ | | | | |
| សៀមរាប | ៥៩៥ | ១០៣៨១០ | ៤៨៩ | ៨៨៣២០ | ៣២៥ | ២៥៥៩០ | ៣២៥ | ២៥៥៩០ |
| សរុប | ៤០៨៣៨ | ៩៨៦០៨១៩ | ៧៦១៩ | ៣១៥៣៨៣១ | ៣៥៧៦ | ១៥៧៦៥៣ | ៣៥៦១ | ១៤២៥១០ |

ប្រភពមកពី : នាយកដ្ឋានជលផល ឆ្នាំ២០០០

**ការចិញ្ចឹមត្រីតាមស្រះ**

ការចិញ្ចឹមត្រីតាមស្រះ គឺជាបច្ចេកទេសដែលមានការអភិវឌ្ឍន៍តិចតួចណាស់នៅក្នុងប្រទេសកម្ពុជា ការចូលរួមចំណែករបស់វាទៅនឹងចំនួនសរុប គឺប្រហែលតិចជាង ១០០០ តោន ក្នុងមួយឆ្នាំ ឬ ១០% នៃផលិតកម្មវារីវប្បកម្ម (១៩៩៨៤-១៩៩២) (DOF, 1993, FAO, 1993 ) និង ១៥-២០% នៃចំណុះត្រីដែលបានចិញ្ចឹមសរុបនៅឆ្នាំ ១៩៩៣-១៩៩៨ (DOF, 1999) ។ មានប្រព័ន្ធចិញ្ចឹមត្រីពីរប្រភេទនៅកម្ពុជា **ការចិញ្ចឹមត្រីបែបប្រពលវប្បកម្ម** ពិសេសត្រីអណ្តែង Pangaius ដែលចូលរួមចំណែកតិចជាង ១០% នៃផលិតកម្មវារីវប្បកម្មសរុប ។ ការចិញ្ចឹមដូចនេះត្រូវបានគេរកឃើញនៅជុំវិញភ្នំពេញ និងខេត្តកណ្តាល ។ មានប្រជាកសិករជាច្រើនដែលបានអនុវត្តនូវសកម្មភាពទាំងនេះនៅក្នុងស្រះតូចៗចាប់ពី ៣០០-១,៥០០ ម$^2$ កូនត្រីទាំងឡាយដែលប្រមូលមកពីបឹងធម្មជាតិត្រូវបានគេដាក់ទៅក្នុងស្រះប្រមាណ ៤-១០ ក្បាល ក្នុងមួយម៉ែត្រការេ ដែលនឹងធំធាត់រហូតដល់ជាង ១ គីឡូក្រាម ក្នុងរយៈពេលមួយឆ្នាំ ។ គេចិញ្ចឹមត្រីដោយអោយចំណីជា **ធាយកន្ទក់** ស្ទើរតែពេញមួយឆ្នាំៗ ថ្វីបើកំឡុងពេលរដូវនេសាទ គេចិញ្ចឹមដោយ **ចំណីត្រី** ក៏ដោយ គឺអាស្រ័យទៅលើយុទ្ធសាស្ត្រចាត់ចែងដែលគេអនុវត្ត ផលិតកម្មនេះគឺមានកំរិតខ្ពស់ ៣០-១០០ តោន ក្នុងមួយហិកតា ក្នុងមួយឆ្នាំ (Nandeesha, 1994; Nandeesha et al., 1997 ) ។

ប្រភេទមួយផ្សេងទៀតគឺជាស្រះ / ស្រែ / ត្រី ដែលមានទិន្នផលទាប និងបច្ចេកទេសចិញ្ចឹមបញ្ចូលគ្នានៃបន្លែ សត្វ និងត្រី ដែលគេអោយឈ្មោះហៅថា **ប្រព័ន្ធពាក់កណ្តាលប្រពលវប្បកម្ម ឬប្រព័ន្ធយកចាំផល** នៃត្រីទីឡាប់យ៉ា (O. niloticus), silverbarb (P.gonionotus) , pangasius catfish (P. hypophthalmus), កាបស (H. nolitrix) កាបសាមញ្ញ (C. carpio) កាបស្មៅ (C. idallus) កាបក្បាលធំ (Aristichthys nobilis) catla (Catla catla), rohu (L. rohita), mrigal (C. mrigala) small scale mud carp (C. micropeltes), giant barb, (Catlocarpio siamensis), អណ្តែងលោត (Clarias macrocephalus and batrachus) និងពពួកកំរផ្សេងៗទៀត ។ ប្រព័ន្ធវារីវប្បកម្មទ្រង់ទ្រាយតូច ទាំងនេះគឺត្រូវបានផ្សព្វផ្សាយ ដោយទីភ្នាក់ងារអង្គការ ជាតិផ្សេងៗ មានជាអាទិ៍ : នាយកដ្ឋានជលផល មជ្ឈមណ្ឌល / ស្ថានីយ៍អភិវឌ្ឍន៍ និងស្រាវជ្រាវវារីវប្បកម្ម មន្ទីរ ជលផលខេត្ត និងអង្គការអន្តរជាតិ អង្គការមិនមែន រដ្ឋាភិបាលនានាដែលមានគោលដៅ និងនយោបាយដូចគ្នា ដើម្បីធ្វើអោយប្រសើរឡើងនូវសន្តិសុខស្បៀង និងជីវភាពរស់នៅព្រមទាំងកាត់បន្ថយភាពក្រីក្រ (ចូរមើល តារាងលេខ ៣.២១) ។ វាបានចូលរួមចំណែកប្រហែល ១០% នៃផលិតកម្មវារីវប្បកម្ម សរុប នៅឆ្នាំ១៩៨៤-១៩៩២ និងប្រហែល ១៥-២០% នៅឆ្នាំ ១៩៩៣-១៩៩៨ ។ ជាមួយនិងដង់ស៊ីតេផ្ទុកត្រីចាប់ពី ២-៦ ក្បាល ក្នុងមួយម៉ែត្រ ការេ ផលដែលទទួលបានពី ២-៥ តោន ក្នុងមួយហិកតា ក្នុងរយៈពេល ០៨ខែ ។

**តារាងលេខ ៣.២១ : គំរោងការ/សកម្មភាពស្រាវជ្រាវវារីវប្បកម្មទឹកសាបខ្នាតតូច**

| ការពិពណ៌នា | កន្លែងគោលដៅ | នៅកសិដ្ឋាន ស្ថានីយ៍ | រយៈពេល | អ្នកផ្តល់ជំនួយ | ថវិកា (US$) |
|---|---|---|---|---|---|
| ១. គំរោង AIT-AARM<br>១-១-<br>បច្ចេកវិជ្ជាវារីវប្បកម្ម | ស្វាយរៀង / តាកែវ / កំពង់ស្ពឺ | នៅកសិដ្ឋាន | ១៩៩៤-២០០០<br>និងដំណាក់កាលទី៣<br>២០០១-២០០៣ | SIDA/DANIDA<br>ដំណាក់កាលទី 3<br>(2001-2003) | 900,000 |

| | | | | | |
|---|---|---|---|---|---|
| ទ្រង់ទ្រាយតូច ( ការបំប៉ន និងចិញ្ចឹម ពូជត្រីកំរ)<br>១-២-<br>ការចិញ្ចឹមត្រីក្នុងស្រែ<br>១-៣-<br>ការនេសាទតាមស្រែ<br>( វាលស្រែ ស្រះ និងទីផ្សារ ត្រីធម្មជាតិ)<br>១-៤-<br>ការគ្រប់គ្រងសហគមនេសាទ ( បំលាស់ទីនៃត្រី ការអភិរក្សត្រី អាង) | ស្វាយរៀង<br>ស្វាយរៀង /<br>តាកែវ / កំពង់ស្ពឺ<br>ស្វាយរៀង /<br>តាកែវ / កំពង់ស្ពឺ | នៅកសិដ្ឋាន<br>នៅកសិដ្ឋាន<br>នៅកសិដ្ឋាន | ១៩៩៦-១៩៩៨<br>១៩៩៦-២០០០<br>១៩៩៨-២០០០•<br>ដំណាក់កាលទី៣<br>១៩៩៨-២០០០•<br>ដំណាក់កាលទី៣ | | |
| **<u>២_គំរោង</u>**<br><u>MRC/READ</u><br>២-១-<br>ការស្រាវជ្រាវសេដ្ឋកិច្ច-សង្គម<br>២-២-យុទ្ធសាស្ត្រ និងវិធីសាស្ត្រ ពង្រីកបន្ថែម | ព្រៃវែង / កណ្ដាល<br>តាកែវ<br>ព្រៃវែង / កណ្ដាល<br>តាកែវ | នៅកសិដ្ឋាន<br>នៅកសិដ្ឋាន | ១៩៩៧-១៩៩៩<br>១៩៩៨-២០០០ | DANIDA | 1,947,350<br>( កម្ពុជា និងវៀតណាម) |
| **<u>៣_គំរោង</u>**<br><u>SAO/SCALE</u><br>៣-១-<br>បច្ចេកវិជ្ជាវារីវប្បកម្មទ្រង់ទ្រាយតូច( ការបំប៉ន និងចិញ្ចឹម ពូជត្រីកំរ)<br>៣-២-យុទ្ធសាស្ត្របន្ថែម វារីវប្បកម្មទ្រង់ទ្រាយតូច<br>៣-៣- ការបំប៉ន និងចិញ្ចឹម ពូជត្រីកំរ<br>៣-៤-ការបង្កាត់ និងការបំប៉នត្រី | កណ្ដាល<br>កណ្ដាល<br>កណ្ដាល<br>កណ្ដាល | នៅកសិដ្ឋាន<br>នៅកសិដ្ឋាន /<br>ស្ថានីយ៍<br>នៅកសិដ្ឋាន /<br>ស្ថានីយ<br>នៅស្ថានីយ៍ | ១៩៩៤-២០០១<br>១៩៩៤-២០០១<br>១៩៩៤-២០០១<br>២០០០-២០០២ | EU/DFID/TFUK<br>New Zealand | |
| ៤_<br>**<u>ស្ថានីយ៍ស្រាវជ្រាវការនេសាទ,</u>**<br>**<u>ខាយកដ្ឋានជលផល</u>** | ភ្នំពេញ | នៅស្ថានីយ៍ | ១៩៨២ រហូតដល់ | Govt. | |

| | | | | | |
|---|---|---|---|---|---|
| ៤-១-ការបង្កាត់ ការបំប៉ន និងការចិញ្ចឹមពូជត្រីកំរ<br>៤-២- ការបង្កាត់ ការបំប៉ន និងការចិញ្ចឹមត្រី | ភ្នំពេញ | នៅស្ថានីយ៍ / កសិដ្ឋាន | ២០០១-២០០៥ | Govt.+DANIDA | |
| **៥. មជ្ឈមណ្ឌលស្រាវជ្រាវ ពូជ ត្រី នៅបាទី**<br>៥-១- ការបង្កាត់ ការបំប៉ន និងការចិញ្ចឹមពូជត្រីកំរ<br><br>៥-២- យុទ្ធសាស្ត្រពង្រីកបន្ថែម<br><br>៥-៣-ការបង្កាត់ និងកាបំប៉នពូជ Pangasius hypophthalmus<br>៥-៤- ការបង្កាត់ ការបំប៉ន និងការចិញ្ចឹមពូជត្រី | ព្រៃវែង<br><br>ព្រៃវែង ស្វាយរៀង កំពង់ស្ពឺ សៀមរាប<br><br>ព្រៃវែង<br><br>ព្រៃវែង | នៅស្ថានីយ៍<br><br>នៅកសិដ្ឋាន / ស្ថានីយ៍<br><br>នៅស្ថានីយ៍<br><br>នៅស្ថានីយ៍ / កសិដ្ឋាន | ១៩៩២-២០០០<br><br>១៩៩៤-២០០០<br><br>១៩៩៦-២០០០<br><br>២០០១-២០០៥ | Govt.+ Padek/Oxfam<br><br>Padek/Oxfam Belgium/Novib<br><br>Padek/Oxfam<br><br>MRC/DANIDA | |
| **៦.គំរោង Padek**<br>៦-១- ការបង្កាត់ ការបំប៉ន និងការចិញ្ចឹមពូជត្រីកំរ<br><br>៦-២- យុទ្ធសាស្ត្រពង្រីកបន្ថែម | ព្រៃវែង ស្វាយរៀង កំពង់ស្ពឺ សៀមរាប<br><br>ព្រៃវែង ស្វាយរៀង កំពង់ស្ពឺ សៀមរាប | នៅកសិដ្ឋាន / ស្ថានីយ<br><br>នៅកសិដ្ឋាន / ស្ថានីយ | ១៩៩២-២០០០<br><br>១៩៩៣-២០០០ | Oxfam Belgium/Novib | |
| **៧.សមាសភាគនេសាទ. APIP**<br>៧-១-ការបង្កាត់ និងភ្ញាស់ពូជត្រី | ភ្នំពេញ | នៅស្ថានីយ៍ | ១៩៩៩-២០០៤ | លុយកំចីរបស់ ធនាគារពិភពលោក | ១.០០០.០០០ |
| **៨.DoF/MRC-AIMFS** | ភ្នំពេញ / ព្រៃវែង | នៅស្ថានីយ៍ / | ២០០១-២០០៥ | DANIDA | ២.៦៣០. |

| | | | | | |
|---|---|---|---|---|---|
| ៨-១-បច្ចេកទេសបង្កាត់<br>បំប៉ន និង<br>ចិញ្ចឹមពូជត្រីទន្លេមេគង្គ ៥-៦<br><br>សំភារៈ<br>និងប្រព័ន្ធពង្រីកបន្ថែម | មជ្ឈមណ្ឌលស្រាវជ្រាវវារីវប្បកម្មជាតិពីរ ( ប្រាំង ចំរេះ និង បាទី )<br>និងត្រូវបញ្ចាក់ | កសិដ្ឋាន<br>នៅស្ថានីយ៍<br><br><br><br>នៅកសិដ្ឋាន | ២០០១-២០០៣<br><br><br>២០០៤-២០០៥ | | ០០០<br>( កម្ពុជា<br>ឡាវ<br>ថៃ និង<br>វៀតណាម<br>) |
| ៩-<u>FAO</u><br>វារីវប្បកម្មទ្រង់ ទ្រាយតូច | សៀមរាប<br>បាត់ដំបង<br>តាកែវ<br>និងកំពត | | | | |
| ១០-<u>ADRA</u><br>វារីវប្បកម្មទ្រង់ ទ្រាយតូច | កំពង់ធំ | | | | រដ្ឋាភិបាល<br>ប្រទេស<br>ញូហ្សេឡែន |
| ១១-<br>**<u>អង្គការដែលគ្មានអ្នកជំនាញវារីវប្បកម្ម</u>**<br>APHEDA, CRS, CCFC, CWS, WFP, CONCERN WORLDWIDE, CCC, CIDSE, GRET, IWDA, LWS, MCC, OXFAM, GB,VSC, JICA, GTZ, QUAKE, EU/PRASAC | ការអភិវឌ្ឍន៍ជនបទ រួមមានវារីវប្បកម្មទ្រង់ទ្រាយតូច | | | | |

ប្រភពមកពី : SO NAM (2000b)

### ការផលិតពូជត្រី

សូណាម ( ២០០០ ) បានរាយការណ៍ថា ការប្រមូលទិន្នន័យតាមផ្នែកត្រូវបានគេអនុវត្តចាប់ពីថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០០ រហូតដល់ថ្ងៃទី១៥ ខែមេសា ២០០០ ទូទាំងប្រទេសកម្ពុជា ។ ទិដ្ឋភាពទូទៅគឺឈរលើមូលដ្ឋាន នៃការធ្វើទស្សនកិច្ចទៅកាន់ស្ថានីយ៍ភ្ញាស់ចំនួន៣៥ ដែលរួមមានស្ថានីយ៍ភ្ញាស់ របស់រដ្ឋាភិបាល ចំនួន១១កន្លែង ស្ថានីយ៍ភ្ញាស់ឯកជនចំនួន០៧ និងស្ថានីយ៍ភ្ញាស់របស់កសិករដែលមានទ្រង់ទ្រាយតូច ។

បច្ចេកទេសភ្ញាស់ដ៏ធំជាងគេទូទាំងប្រទេសគឺជាប្រព័ន្ធរបស់ចិន ដែលធ្វើសារាចរដោយអាងត្រីពង និងអាងភ្ញាស់ពង ដោយមានការផ្គត់ផ្គង់ទឹកពីអាងរាងចតុកោណកែងដ៏ធំ ដែលគេប្រើប្រាស់នៅគ្រប់ស្ថានីយ៍ភ្ញាស់ទាំងអស់ ។ ជា

ធម្មតាអាងត្រីពងមានទំហំធំជាងអាងភ្ញាស់ ដើម្បីអោយទឹកហូរចូលច្រើន ហើយអោយពងជាលក្ខណៈធម្មជាតិ បន្ទាប់ពីការ ចាក់ជាតិអរម៉ូន EXOGENOUS ។

យ៉ាងហោចណាស់មានពូជត្រីចំនួន០៦ប្រភេទ ដែលមានឈ្មោះថា កាបស កាបសាមញ្ញ ត្រីទីឡាព្យា Mrigal, Silver barb, Clarias Hybrid catfish (C. macrocephalus x C. gareipines) ដោយមានការ ប្រើប្រាស់ Exogenous hormones (HGG and LHRH analogues, Pituitary gland and Ovaprim) ដើម្បី ចាក់ថ្នាំដែលជុំរុញអោយឆាប់មានពង ។

ការភ្ញាស់ភាគច្រើនបំប៉នរហូតបានកើតជាកូនត្រី ប៉ុន្តែកូនត្រីដែលទើបនឹងញាស់ភាគច្រើន ត្រូវបានគេលក់ទៅអោយ ប្រតិបត្តិការដែលមានជំនាញខាងបំប៉ន និងចិញ្ចឹម ។

ត្រីទីឡាព្យា គឺជាពូជមួយដ៏សំខាន់បំផុតដែលអាចបង្កើតកូនបាន (៣៦% នៃផលិតកម្មភ្ញាស់ពូជត្រីសរុប) (ចូរមើល តារាង លេខ៣.២២) នៅក្នុងប្រទេសកម្ពុជា ដោយសារតែត្រីត្រូវបានគេបង្កាត់កូននៅក្នុង ស្រះធម្មជាតិពេញមួយឆ្នាំ វាគឺជាពូជដែលពេញនិយម ហើយល្បីល្បាញចំពោះសំរាប់ប្រជាជន ដោយវាមានការធំធាត់លឿន និងហាក់គួរជាទីពេញ ចិត្តរបស់អតិថិជន ហើយបន្ទាប់មកគឺត្រីកាបសាមញ្ញ (២៨% ) និងត្រីកាបស (១៧% ) និង (៩% ) ផ្សេងទៀត គឺជាត្រីប្រភេទ Clarias hybrid catfish ដែលត្រូវបានផលិតដោយស្ថានីយ៍ភ្ញាស់ឯកជនទាំងអស់ ។ ចំនួនកូនត្រីសរុបដែលគេបានបង្កាត់នៅក្នុងទីក្រុងភ្នំពេញគឺមានប្រហែល ២,៦ លានក្បាល នៅក្នុងស្ថានីយ៍ភ្ញាស់បី កន្លែង បន្ទាប់មកគឺខេត្តព្រៃវែង (១,២ លានក្បាល ) និងខេត្តកណ្តាល (១,១ លានក្បាល) (ចូរមើល តារាងលេខ៣.២៣) ។

**តារាងលេខ ៣.២៣ : ភាគរយនៃពូជត្រីដែលគេបង្កាត់នៅប្រទេសកម្ពុជា ឆ្នាំ ១៩៩៩**

| ការពិពណ៌នា | ចំនួនភាគរយ |
|---|---|
| ទីឡាព្យា | ៣៦,៣៣ |
| កាបស | ៥.៥៦ |
| Silver barb | ១៧.១២ |
| កាបសាមញ្ញ | ២៧.៧៤ |
| Mrigal | ៤.១២ |
| Hybrid | ៨.១២ |
| ផ្សេងទៀត | ១ |
| **សរុប** | ១00.00 |

តារាង ៣.២៣: របាយនៃស្ថានីយ៍ភ្ញាស់កូនត្រីតាមបណ្តាខេត្ត កម្ពុជា ១៩៩៩

| ខេត្ត | ចំនួនកូនត្រីដែលផលិតបានប្រចាំឆ្នាំ (ក្បាល) | ចំនួនស្ថានីយ៍ | ឈ្មោះស្ថានីយ៍ |
|---|---|---|---|
| បន្ទាយមានជ័យ | ២៥០.០០០ | ១ | -វត្តស្វាយ |
| បាត់ដំបង | ២០០.០០០ | ១ | -បាត់ដំបង |
| កណ្តាល | ១.០៦៧.៧៨៤ | ៣ | -ទួលក្រសាំង ពៅវត្តា គូពិសិដ្ឋ |
| កំពង់ស្ពឺ | ៥៤.៩៧០ | ២ | -ខាត់ សុខនី ឡៅធន |
| កំពង់ធំ | ១៣.៥០១ | ២ | -ឃុនវុទ្ធី សូថេន |
| កំពត | ៣៣.៩៥២ | ២ | -កំពត (ឈូក) ម៉ាងញូន |
| ក្រុងភ្នំពេញ | ២.៦៤៣.៣៩០ | ៣ | -ចាក់អង្រែ ពុងពឹង ច្រាំងចំរេះ |
| ព្រៃវែង | ១.២៦៦.៧៥០ | ៨ | -ហាទី សុខសារួន សមពិច មុតថេន ពុតវ៉ែន ឈ សម្បត្តិ ហេងថន អៀនសាក |
| ពោធិសាត់ | ៧៣.០០០ | ១ | -ពោធិសាត់ |
| សៀមរាប | ១១៣.៣៧០ | ១ | -ទីកវិល |
| ស្វាយរៀង | ២១៧.៣៧៥ | ២ | -ប្រាសូត សមវ៉ាសនា |
| តាកែវ | ៦៩០.៣៤៦ | ៣ | -កៀង រ៉ែនឆុន ខៀវសម |
| សរុប | ៧.០៤២.៦៣៨ | ២៩ | |

ប្រភព: So Nam et al. 2000

កូនត្រីពូជត្រូវបានផលិតប្រចាំឆ្នាំចំនួន ៧.១ លានកូន (តារាង ៣.២៣) ។ លទ្ធផលនេះទាបជាងរបាយការណ៍របស់នាយកដ្ឋានជលផល ដែលមាន ៩.២ លាន កូន នៅឆ្នាំ ១៩៩៩ ។ យើងពុំបានដឹងពីមូលហេតុខុសគ្នានេះទេ ។ យើងគិតថាប្រហែលនាយកដ្ឋានប៉ាន់ប្រមាណលើស ឬ រាប់ចំនួនកូនត្រីពីស្ថានីយ៍មួយចំនួនទុបពីរដង មុនពេលដែលកូនត្រីត្រូវបានដឹកជញ្ជូនពីខេត្តមួយទៅខេត្តមួយទៀត ។ម្យ៉ាងទៀតប្រហែលការសិក្សានេះ ប៉ាន់ប្រមាណទាបជាង ដោយសារយើងពុំបានទៅដល់ស្រះកសិករដែលមានកូនត្រីទីឡាព្យាញាស់តាមធម្មជាតិ (ដោយខ្លួនឯង) នៅតាមស្រះកសិករ ។

## ៤. សេចក្តីសន្និដ្ឋាន

របាយការណ៍នេះ មានគោលបំណងធ្វើការពិពណ៌នា និងវិភាគស្ថានភាពក្រីក្ររបស់ប្រជាជន ការអភិវឌ្ឍន៍ធនធានមនុស្ស និងស្ថានភាពធនធានវារីជាតិនៅក្នុងប្រទេសកម្ពុជា ដោយផ្តោតយកចិត្តទុកដាក់អំពីភាពខុសគ្នា នៃសេដ្ឋកិច្ចនៅតាមជនបទ ទីក្រុង បណ្តាខេត្ត រវាងបុរស និងស្ត្រី និងចង្អុលបង្ហាញទីកន្លែងដែលមានប្រជាជនក្រីក្រ និងការធ្វើអន្តរាគមន៍ដែលអាចជួយសំរាលទុក្ខលំបាកដល់ប្រជាជនក្រីក្រទាំងនោះ ។

<u>អ្នកណាជាអ្នកក្រីក្រ ហើយនៅទីណា?</u>

ប្រទេសកម្ពុជាត្រូវបានចាត់ចូលក្នុងចំណោម ២០% នៃបណ្តាប្រទេសដែលមានការអភិវឌ្ឍន៍ធនធានមនុស្សទាបបំផុត ។ កម្ពុជាក៏ស្ថិតក្នុងចំណោមបណ្តា ២០ប្រទេសក្រីក្របំផុតនៅលើពិភពលោក ។ ប៉ុន្តែដោយសារមានចំនុចលក្ខណៈជាច្រើនដែលពាក់ពន្ធ័នឹងការអភិវឌ្ឍន៍ធនធានមនុស្ស ដូចជា ឧក្ខរភាព ការចូលរៀននៅតាមសាលា អាយុភាពជីវជាតិអាហារ និងហ បញ្ហាភាពក្រីក្រដែលចំនុចលក្ខណៈទាំងនេះមានទំនាក់ទំនងយ៉ាងសំខាន់ជាមួយនឹង ផលិតផលក្នុងស្រុករបស់ប្រជាជនម្នាក់ៗនោះ ការរីកចំរើនសេដ្ឋកិច្ចនឹងធ្វើឱ្យស្ថានភាពអភិវឌ្ឍន៍ធនធានមនុស្សកាន់តែប្រសើរឡើងនៅកម្ពុជា ។ នេសាទទឹកសាប កម្ពុជាជាប្រភពដ៏ធំបំផុតផ្គត់ផ្គង់ត្រីសាច់ដល់ប្រជាជន ។ ដោយហេតុនេះ ការគ្រប់គ្រងនេសាទទឹកសាបកម្ពុជា ប្រកបដោយ និរន្តរភាពមានសារៈសំខាន់ណាស់ចំពោះសុវត្ថិភាពស្បៀងអាហារ និងជីវភាពរស់នៅប្រកបដោយនិរន្តរភាពរបស់ប្រជាជន នៅតាមតំបន់ជនបទ ។

ប្រជាជនក្រីក្រកម្ពុជា ដែល៩០% នៃប្រជាជនទាំងនេះមានរបរជាអ្នកនេសាទ និងធ្វើកសិកម្មជាប្រភពប្រាក់ចំណូលសំខាន់អាស្រ័យលើការនេសាទទ្រង់ទ្រាយតូច ព្រៃឈើ និងផលផល ។ ផលផលមានតួនាទីយ៉ាងសំខាន់ក្នុងការផ្គត់ផ្គង់សុវត្ថិភាពស្បៀងអាហារ និងនិរន្តរភាពនៃជីវភាពរស់នៅ និងជាប្រភពប្រាក់ចំណូលគ្រួសារ ។ គ្រួសារអ្នកក្រីក្រហាក់ដូចជាមានសមាជិកគ្រួសារច្រើន មានវ័យក្មេង មេគ្រួសារជាបុរស ហាក់ដូចជាអនក្ខរភាពទៅរៀនសាលារៀនបានពីរបីឆ្នាំ និងមានកូនច្រើនជាងគ្រួសារអ្នកមាន ។ ត្រីជាប្រភេទអាហារដ៏សំខាន់ដែលអាចទិញ ឬនេសាទបាន ។ អត្រាភាគរយទទួលបានពីការនេសាទ ឬទិញ អាស្រ័យនឹងលទ្ធភាពចូលនេសាទរបស់គ្រួសារទាំងនោះ ។ ក្រុមអ្នកប្រើប្រាស់ធនធានតិច គឺជាអ្នកនេសាទជាលក្ខណៈគ្រួសារ និងអ្នកដែលរស់នៅតំបន់ឆ្ងាយពីដែននេសាទ ធ្វើវារីវប្បកម្មទ្រង់ទ្រាយតូច ឬដើររើសធនធានក្នុងទឹកដែលជាផ្នែកតូបផ្សំនៃជីវភាពរស់នៅ ។

- អ្នកនេសាទទ្រង់ទ្រាយតូច ឬនេសាទគ្រួសារ ធ្វើការនេសាទជាទូទៅនៅតាមតាមទន្លេតូចៗ និងបឹង (៣៩%) នៅតាមទំនាបព្រៃលិចទឹក (១៧%) នៅបឹងទន្លេសាប (១៥%) (តារាង ៣.១៦ និង១៧) នៅតាមបណ្តាខេត្តជុំវិញបឹងទន្លេសាប (១៥%) (ខេត្តកំពង់ធំ សៀមរាប បន្ទាយមានជ័យ បាត់ដំបង ពោធិសាត់ កំពង់ឆ្នាំង និងផ្នែកនៃខេត្តកណ្តាលដែលស្ថិតនៅខាងជើងទីក្រុងភ្នំពេញ) និងតំបន់ទន្លេមេគង្គ/ទន្លេបាសាក់ (ផ្នែកនៃខេត្តកណ្តាលដែលស្ថិតនៅខាងត្បូងទីក្រុងភ្នំពេញ កំពង់ចាម ស្វាយរៀង ព្រៃវែង និងតាកែវ) ដែលមានអ្នកនេសាទទ្រង់ទ្រាយតូចប្រមាណ ៣៩% ។ នៅតំបន់ប្រព័ន្ធអេកូទី៣ ដែលស្ថិតនៅផ្នែកខាងលើនៃទន្លេមេគង្គកម្ពុជា និងតំបន់ទឹកហូរធ្លាក់ខ្លាំង (Rapids) (ក្រចេះ និងស្ទឹងត្រែង) ត្រូវបានចាត់ទុកជាតំបន់នេសាទពុំសូវមានសារសំខាន់ ប៉ុន្តែបានផ្តល់សារសំខាន់ផ្នែកអេកូឡូស៊ីសំរាប់ជាពិសេសប្រភេទត្រីដែលធ្វើចរាចរភាគច្រើន និងផ្តល់ឱកាសសំរាប់នេសាទជាលក្ខណៈគ្រួសារដល់ប្រជាជនដែលរស់នៅក្បែរ ។
- ការធ្វើវារីវប្បកម្មទ្រង់ទ្រាយតូច ឬការដើររើសធនធានជលផលមានសារៈសំខាន់ណាស់ចំពោះប្រជាជនដែលរស់នៅក្នុងខេត្តស្ថិតនៅឆ្ងាយពីបឹងទន្លេសាប ទន្លេមេគង្គ និងទន្លេបាសាក់ ដូចជា ខេត្តកំពង់ស្ពឺ រតនៈគិរី មណ្ឌលគិរី ព្រះវិហារ និងឧត្តមានជ័យ ដែលពុំសូវមានធនធានជលផល ។

គេពិនិត្យឃើញមានភាពខុសគ្នាយ៉ាងខ្លាំងលើផ្នែកធនធានមនុស្ស និងស្ថានភាពសង្គមរវាងបណ្តាខេត្ត ។ មានចំនុចលក្ខណៈជាច្រើនដែលមានឥទ្ធិពលកំណត់គុណភាពខុសៗគ្នារបស់សហគមនៅកម្ពុជា ដូចជា កង្វះជីវជាតិអាហារ

របស់កុមារ បញ្ហាសុខភាព និងសេវាកម្មជាមូលដ្ឋានមួយចំនួន (ដូចជា ទឹកបរិភោគ ការអនាម័យ ចរន្តអគ្គិសនី) សេវាកម្មសុខភាព ការកសាងលំនៅដ្ឋាន ការកំសាន្ត និងពត៌មាន ។ ការសិក្សាអំពីការអភិវឌ្ឍន៍ធនធានមនុស្សនៅកម្ពុជា (CHDI) បានប្រមូលទិន្នន័យសេដ្ឋកិច្ច និងសង្គម ហើយបានវាយតំលៃខេត្តកំពង់ស្ពឺជាខេត្តដែលពុំសូវមានប្រយោជន៍ ចំណែក ខេត្តរតនៈគិរី មណ្ឌលគិរី កំពង់ចាម សៀមរាប និងព្រៃវែងមានការអភិវឌ្ឍន៍ធនធានមនុស្សទាបបំផុត ។

## <u>តើមានបញ្ហាចំបងជាគន្លឹះអ្វីខ្លះ?</u>

បញ្ហាជាចំបងដែលអ្នកប្រើប្រាស់ធនធានបន្តិចបន្តួចនៅកម្ពុជាជួបប្រទះ គឺជុំវិញបញ្ហាសិទ្ធិនៃការចូលធ្វើនេសាទ និងការទំនាក់ទំនងរវាងអ្នកក្រីក្រ និងភ្នាក់ដែលជួយដល់អ្នកក្រីក្រ ។ មន្ត្រីជលផល និងបណ្តាអ្នកដែលជួយកសិករក្រីក្រ អ្នកគ្មានកម្មសិទ្ធិដីធ្លី និងអ្នកនេសាទជាលក្ខណៈគ្រួសារ នៅមានការយល់ដឹងនៅមានកំរិតនៅឡើយ ។ ការនេះមានសារៈសំខាន់ណាស់ព្រោះវាអាចជះឥទ្ធិពលលើគោលនយោបាយរបស់រដ្ឋាភិបាល វិធិសាស្ត្រដ៏ត្រឹមត្រូវក្នុង ការផ្សព្វផ្សាយការយល់ដឹងដល់អ្នកទាំងនេះ ប៉ះពាល់ដល់សិទ្ធិស្របច្បាប់របស់អ្នកនេសាទទ្រង់ទ្រាយតូច ក្នុងការចូល នេសាទ និងជាឧបសគ្គដែលអ្នកក្រីក្រទាំងនេះពុំអាចចេញរួច ពីភាពក្រីក្រតាមរយៈនៃការបង្កើន សមត្ថភាពនេសាទ ។

## <u>តើយើងមានគោលបំណងធ្វើឱ្យមានការប្រែប្រួលដូចម្តេចខ្លះ?</u>

មានគោលបំណងជាច្រើនក្នុងការធ្វើឱ្យមានការប្រែប្រួល ក្នុងនោះរួមមានៈ ជំរុញដំណើរការបង្កើតឡើងនូវគោលនយោបាយជួយអ្នកក្រីក្រ កសាងសមត្ថភាព និងគោលដៅរបស់រដ្ឋាភិបាល និងរបស់ស្ថាប័នក្រៅរដ្ឋាភិបាលសំរបសំរួល ស្ថាប័ននៅតាមបណ្តាមូលដ្ឋាន និងនៅទូទាំងប្រទេស ជំរុញការផ្តួចផ្តើមទំនាក់ទំនងជាមួយ បណ្តាស្ថាប័នដែលមាន ទំនាក់ទំនងក្នុងតំបន់ក្នុងការគ្រប់គ្រងធនធានជលផលសំដៅកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍន៍ជនបទ ។ ជាពិសេស ជំរុញការយល់ដឹងអំពីស្ថានភាពក្រីក្រ ការប្រើប្រាស់ធនធានវារីជាតិ និងការកសាងសមត្ថភាពមន្ត្រីរាជការ សំដៅជំរុញការ ចូលរួម និងវិភាគអំពីនិរន្តរភាពនៃជីវភាពរស់នៅ ដើម្បីរកឱ្យឃើញនូវចំនុចខ្លាំង ចំនុចខ្សោយគោលបំណងរបស់ប្រជាជន ក្រីក្រនៅតាមជនបទ និងការជះឥទ្ធិពលនៃគោលនយោបាយ និងស្ថាប័នលើប្រជាជនក្រីក្រ ។

- <u>បញ្ហាដែលពាក់ព័ន្ធនឹងការនេសាទៈ</u> ក្នុងនោះរួមមាន ការកំណត់ព្រំប្រទល់ដែលនេសាទក្នុងច្បាប់ជលផល ពិនិត្យព្រំប្រទល់ឡូត៍នេសាទឡើងវិញ ពិនិត្យនិយមន័យ និងកំណត់ដែន នេសាទសំរាប់ការនេសាទជាលក្ខណៈគ្រួសារ ឬទ្រង់ទ្រាយតូច បង្កើតឡើងវិញនូវច្បាប់នៃការនេសាទជាលក្ខណៈគ្រួសារ ដំណើរការដេញថ្លៃឡូត៍នេសាទ រយៈពេលអាណត្តិនៃការធ្វើអាជីវកម្មនេសាទបញ្ហានៃការស្រាវជ្រាវឡូត៍នេសាទ ការគ្រប់គ្រងធនធានជលផល តាមរូបភាពសហគមនេសាទ ការផ្ទេរការទទួលខុសត្រូវក្នុងការចំណាយថវិការជូនអាជ្ញាធរ ឬស្ថាប័ននៅតាមបណ្តាខេត្តក្រោម ឱវាទនាយកដ្ឋាន និង ក្រសួង និង អនុវត្តយុទ្ធវិធីចំណាយថវិការអោយសមស្របនឹងធនធានមនុស្សក្នុងស្ថាប័នរបស់ខ្លួន ។

  ច្បាប់ជលផលបានកំណត់សិទ្ធិនៃ ការនេសាទជាលក្ខណៈគ្រួសារខុសពីការនេសាទជាលក្ខណៈឧស្សាហកម្ម ។ និយម ន័យនៃការនេសាទជាលក្ខណៈគ្រួសារត្រូវកំណត់ដោយផ្អែកលើមូលដ្ឋាន នៃសមត្ថភាពនេសាទ និងទំហំឧបករណ៍នេសាទ។ ប៉ុន្តែសមត្ថភាពនេសាទ ឬកំលាំងនេសាទដែល បានកំណត់

អនុញ្ញាតិឱ្យ មិនសម ស្របនឹងស្ថានភាព នេសាទបច្ចុប្បន្ន ដែលអាចផ្គត់ផ្គង់ជីវភាពរស់នៅបានពី ផលត្រី ដែលនេសាទបាន ។ ច្បាប់ ជលផលក៏បានកំណត់និយមន័យការនេសាទជា លក្ខណៈគ្រួសារមិនលក់ ផលនេសាទ ដែលជាហេតុធ្វើឱ្យប្រជា នេសាទជាលក្ខណៈគ្រួសារពុំអាចមានលទ្ធភាពរំដោះ ខ្លួនចេញពីភាព ក្រីក្របានដោយបង្កើនសមត្ថភាពនេសាទ ។

***********

## 6. Reference


Ahmed M and Tana T.S. (1996). Management of Freshwater Capture Fisheries of Cambodia-issue and Approaches, In Naga Vol. 19, No. I, 1999.

Ahmed M., Hap Navy, Lv Vuthy and Marites Tiongco. 1998. Socio-economic Assessment of Freshwater capture Fisheries of Cambodia, Report on a household Survey. 185 pages.
MRC/DOF/DANIDA.

AIT-AAΓ.M (1998). Kampong Speu Database, Phnom Penh.

APIP-Fisheries Component (1999). Fisheries Law Revision on Conservation, Management and Development Fisheries Law, Department of Fisheries, English version. August 1999 and Khmer vei'siofl dated May 2000)

Assembly

Azimi et al. (2000). Environment in Transition Cambodia, Lao. Thai [and and Vi etnaevt. Asia Developmeni Bank.

Canibodia Daily (newspaper), 13th June 2000, Protester give birth near National

Cambodia Daily (newspaper),25th May 2000, Expert calls for fishing reforiri, Pnh.

Cambodia Daily Newspaper (2000).

Chea Vanaren (1999). Fisheries Activities in Stung Treng province, Cambod a. Department ot Fisheris, Phnom Penh.

(Csavas I., Doulman P., Peter T., Padro J., and Dehas L. 1994. Cambodia Rehabilitation an:! Development Needs for the Fisheries Sector. FAG fisheries Circular No- 873, FAG. Rome.

USES (1996). Cambodia's Socio-econornic Survey. Phnom Penh.

CSES (1997). Cambodia's Soeio-economic Survey (1997). Phnom Penh.

Deap L. 1999. Bagnet (Dai) fishery in Tonic Sap, DoF, Phnom Penh.

Deap L. 1998. Catch Statistic of Cambodian Fresliwat.er Fisheries. DoF/MRC/DANIDA-Capture F;shevies Management project.

Degen. P and Thuok (1998). Inland fisheries management in Cambodia: Is the fishing Wt. system the basis for improved management or should it be abolished? Draft paper submitted to the JEh conference of the international association for the study of common property, Vancourver Canada, 10-14 iune 1998, Mekong River Commission/ DoF/DANIDA project, Management of the Freshwater Capture Fisheries of Cambodia.

Degent et al. 2000. Taker for granted conflicts over Cambodia's Freshwater fish resources, paper written for the 8(IL IASCP Conference, Bloomington, Indiana 31th May to 4th June 2000.

Degent P. and Nao Thuok, 1998. Inland Fisheries management in Cambodia: Is the fasnirtg lots system the basis for improved management or should be abolished?

DoF (2000). The Department of Fisheries Data Collection and Statistics 1980-1999. Phnom Penh Cambodia.

EWG 2000. Review of fisheries conflict in Stung Treng, Environment Working group, NGG fomm, January 2000.

FAO. 1993. Cambodia fisheries program mission: rehabilitation and development needs.

Technical cooperation program. FAG, Rome.
GCP/CMB/002/BEL 2000. Participatory Management of National Resources in the Tonic Sap region, Food and Agriculture Organization of United Nations, Siem Reap
General Population Census of Cambodia (1998). Phnom Penh.
Gregory R 1997. Rice Field fisheries Handbook, Cambodia IRRJ Australia Project, Cambodia.
Gregory R and Gunman H. 1999. A Diverse Monoculture, Aquatic Animal Production from Rice Fields in South East Asia, Cat and Culture Mekong Fisheries Network Newsletter, Vol. No I September 1999.
Gregory R. and Guttman H., 1999. A diverse monoculture, aquatic animal production from rice fields in South East Asia, Catch and Culture Mekong Fisheries Network Newsletter, Vol. 5, No, I, September 1999.
Gum W (1998). Natural Resources Management in the Tonlc Sap Biosphere Reserve *in* Battanbang Province, Consultant report of European Commission support program to the Environment sector in Cambodia, August 1998.
Gum W. 2000. Draft consultation repoit on Inland aquatic resources and Livelihoods in Cambodia. Oxfam GB, Phnorn Penh, Cambodia.
Gum W., 19997. Consultantcy report on Fisheries development in Northwestern Cambodia, May 996 to February [999, CARERE/UNDPRGC
Guttman H. 1999. Rice Field Fisheries- A resource for Cambodia, Naga, The ICLARM quarterly, Vol. 22, No.2, April-June 1999.
Helmers K and Kenefick E (1999). Survey of household livelihoods and nutrition in Cambodia Communes affect by civil conflict since 1989: The UN World Food Program Protracted Emergency Target (PET) survey. WFP September 1999.
Hy H. 1995. Fish Production and Consumption in Siem Reap province. Participatory Natural Resources in the Tonic Sap Region, Siem Reap, Cambodia.
Jensen J (2000). Mekong Countries take the lead in fisheries management. Mekong Fish Catch and Culture, Fisheiies Nct~vork Newsletter, Vol. 6, No. I, SDeptemher 2000.
JICA. 1997. The Agricultural Development Study of the Mekong Flooded Arca in Cambodia Draft Final Report. Sanyu Consultants Inc.
Kato E 1999. Where has all the land gone? Land rights and access in Cambodia. Volume 2, case studies, Oxfam.
Lagler K.F. 1976. Fisheries and Integrated Mckong River Basin Development, Terminal report of the Mekong Basinwide fisheries studies, University of Michingen.Ann Arbor, Appendix I.

MAFF. 1998. Agricultural Development Plan (1999-2010), Long, Medittm and Short lerm, Phnom Penh, Cambodia.
MEF- Ministry of Economic and Finance. 1999. Cambodia Economics and Finance, Phnom Penh, Cambodia.
Mekong Secretariat 1992 (Committee for Coordination of Investigation of the Lower Mekong Basin). Fishenes n the Lower Mekong basin (Review of Fisheries Sector in the Lower Mekong Basin. Bangkok. 92 p. plus annex.
Ministry of Commerce (1998).
Ministry of Planning. 1995. Cambodian Economic Development Plan, Phnom Penh, Cambodia.
MoE (1996). National Environment Action Plan, Management of Tonlc Sap Ecosystem, Draft WorkHg Paper No.3, Ministry Cf Environment, July 1996.
MoP- Ministry of Planning 1998a. An updated Poverty Profile for Cambodia 1997" Kingdom of Cambodia. Phnoni Penh.
MOP/UNDP/SIDA/World Bank, 1998. Ministry of Planning A poverty profile of Cambodia-1997.
MOP/UNDP/SIDA/World Bank, 1999. Ministry of Planning Cambodia Poverty Assessment (1999).
Murshid *K.A.S.* (1998). Food security in an Asian Transitional Economy: The Cambodia Experience, Cambodia Development Research Institute, Working paper No. 6. Phnom Penh.
Mysliwiec EL. (1987). Kampuchea: the state of agriculture and outlook for future Cornell

University, USA. 124 p. Master Thesis
Nandeesha MC, Sereyvuth S. 1997. Pond culture of Pangasids in Cambodia: A potential native species to create economic security for the farmers.
Ngor P.B. 1999. Cattish Liv collection in the Mekong River, Kandal Phnom Penh. DoF, Phnoni Penh.
NIS/M0F/UNDP/SIDA/Wrold Bank, 1995. Cambodia Socio-econoinic Survey 1993-94. Phnom Penh.
NLS/MOP/UNDP/STDA/Wrold Bank, 1996. Consumer Price Index. Phnom Penh.
NIS/MOP/UNDP/ STDA/Wrold Bank, 1997. Consumer Pricc Index. Phnom Penh.
NIS/IMOP/UNI)P/STDA/Wrold Bank, 1998. Cambodia Socio-cconomic Suney 1997. Phnom Penh.
N1S/M0P/UNDP/SIDA/World Bank, 2000. Cambodia Socio-economic Survey 999. Phnon Penh.
Nunia Shams and Ahmed M. 1996. Common and Private property linkages to sustain livelihood ri low-land forest-fisheries-farming systems of Northwest Cambodia. Paper presented at Voices of the common 6th annual conference of international association for the study of common property, Clark Compus University of California at Berkeley June 5-6 1996.
Ovesen J, I-B Trankell and J. Ojendal 1996. When every household is an island: Social organization and power stnrctures in rural Cambodia.
OXFAM GB (2000). All our livelihoods arc Dead. Landless and Aquatic Resources in Rattambang Province, Cambodia,
Plriak 2000. Draft report workshop on the Downstream Impacts of the Yali Fa:ls Dam in the Sesan River basin in Ratanakiri province. JVC.
Phounsovauth et al., 1999. Are state-user relation conductive to fisheries co-management in the lower N4ekcng Basin? MRC/FIU Technical symposium, Phnom Penh, 13-14 December 1999.
Prescott N. and I'radlran Ni., 1997. A poverty profile of Cambodia. World Bank Discussion Paper No. 373, Washington, USA.
Provincial Fisheries Office (2000). A study of the downstream impacts of the Yali Falls Dam in the Sesan river basin in Ratanakiri province, Northeast Cambodia, Office of Fisheries, Ratanakiri province in cooperation with the non- Timber Forest Producls (NTFP) project, Ratanakiri province.
Rainhoth (1996). Fish of the Cambodian Mekong. FAO species identification filed guide for fisheries pumoses. MRC/DANIDA/FAC, Rome, 1996.
RCG (1995). Royal Government of Cambodia, First Socio-econornic Deve!ɔpment Plan., Phnom Penh.
RCG 2000. Daft Governance Action Plan in Good Governance, Paper presented by tile Royal Government of Cambodia at the 4 th Consultative Group Meeting in Paris 25-26 May 2000.
Seilert H. and Lamberts D. (2000). The fisheries sector in Cambodia. A discussion paper. Food and Agriculture Organization (FAO), Cambodia.
Shamr N. arid M. Ahmed (1996). Common and Private Property Linkages for Sustainable Livelihoods in Low Land Forest-Fisheries-Farming System of Cambodia. Paper presented at Voices of the Common 6" Annual Conference of International Association for the Study of Common Property, University of California June 5-8 1996 USA.
Sithirith 2000. Fishing Conflict in Battambang, NCO P0mm, March 20(30.
So Nam (2000). Research and Development Activities/projects. Cambodia's Department of Fisheries. Phnom Penh, October 2000.
So Nam and Nao Tlruok 1999. Aquaculture Sector Review (1924-1999) and Aouaculture Development Plan (2000-2020). Phnom Penh, Cambodia.
So Nam. Hay Viseth, Song Mov, Hap Navy and Ka-Ming Au (2000). Overview of Cambodia's Fish Seed Production. Paper presented at National Workshop on Cambodia's Fish Seed Production- Current Status and Logflame Analysis. Phnom Penh, April. 2000.
Sovannary K. 1997. Technological Assessment of Feed Use in Cambodia Cage/Pen and Pen Culture. M.Sc. Thesis at ALT, Thailand. 60 pages

Sovannarv K. 1997. Technological Assessment of Peed Use in Cambodia Cage/Pet-i arid Pen Culture. M.Sc. Thesis at ALT, Thailand, 60 pages
Swift, P. 1999. Long-tern case study of the fishery setting in Phlong Village, Kompong Khhang province, Lnitial information gathering and outlines of future work program, report on filed ~vork conducted from 7 to 16 June 1999.
Tan K. (1971). Recuil Comment du Code des Itches en vigur au les Janvier 1971 (compiled theme of fisheries law and regulations)
Tana (1996). Status of Eiodiversity of the Great Lake (Boeung Tonlc Sap), an approach (hr better conservation and future sustainable development. Tnle Sap Technical Workshop, MoE, Phnoni Penh, 1996.
Tana T. 1995. Environmental Assessment and Management of Cambodian Aquaculmr~e Development. Paper presented at the workshop on a Regional Study Workshop on Environmental Assessment and Management of Aquaeu!ture Development. F.AC/NACA, 1995.
Tana T. 1995. Environmental Assessment and Management of Cambodian Aquaculture Development. Paper presented at the workshop on a Regional Study Workshop on Environmental Assessment and Management of Aquaculture Development. FAOThACA, 1995.
Tana T.S (1990). Complied Theme of Fisheries Law, Translated by Touch Seng lana, Department of Fisheries Phnom Penh.
Tana T.S 1993, Fish Supply and Demand in Rural Svay Ricng Province, Cambodia. Asian Institute of technology, Bangkok, Thailand.
Thuok and Song (1999). Report on fl:ed survey work for fishing lots # 6, Kompong Khleang commune, Sot Nikum District, Siem Reap province, Cambodia, Department of Fisheries, supported by project GCP/CME/002/EEL: Participatory Management of National Resources in the Tonic Sap region, Food and Agriculture Organization of United Nations, 51cm Reap, May 1999.
Thuok and Van Zalinge (2000). Challenging in Managing Cambodia's Inland Fisheries. How can we meet? DOF/MRCFCFMC Phnom Penh, September 2000.
Thuok N. and Sina, L. 1997. Reviw of the fisheries and aquaculture sector in Cambodia. CMB/95/003: Natural resource base development for the Tonic Sap Area.
Thuok, Thav Sotnony and Srun Lim Song (2000). Fisheries Environment Study in the Mekong Delta (Cambodia). Project of Flood Control for Development of the Mekong Delta, Phnoni Pem,h, May 2000.
UNDP- Cambodia Human Development Report 1997.
UNDP- Cambodia Human Development Report 1998.
UNDP- Cambodia Human Development Report 999.
UNDP- Cambodia Human Development Report 2000.
UNICEF (1994) Nutritional status and food practices in rural areas: Food and Nutrition survey *in* 12 villages oi 4 provinces In L993-94, Phnom Penh, 1994
UNICEE/WFP Cambodia: Kenfick E., 1998. Baseline Survey of CASD Project and WIT Target Areas. WFP/UNLCEF, Phnom Penh.
Van, Acker, F. 1999. Land Tenure: flitting a stone with an egg? Cambodia Development Review, Vol.3, rssue 3, Cambodia Development Resources Lnstitute, September 1999.
WFP 1998. Socmo-economic Assessment of Freshwater Capture Fisheries of Cambodia . Report on a household Survey Mekong River Commission, Phnom Penh; World Food Progr~amme Protracted Emergency Target Zones in Cambodia (UN WFP, 1998).
WFP Cambodia: Rent Helmers and Erix Kencflck, 1999. Survey of Household
Williams S. 1999. Where has all land gone? Land Right and Access in Cambodia, Volume I, Review of land issues and property law, Cxfam GB. Phnomn Penh.
World Bank, 1997, Cambodia: Progress in Recovery and Reform, East Asia and Pacific Region. Washington D.C., June.
World Bank. 1992. Cambodia Agenda For Rehabilitation And Reconstruction. Washington D.C. 219 p. plus appendices.
World Health Organization (1985). Energy and Protein Requirement, Technical Report Series No. 724, Geneva.

Zalinge and Thuok (1999). Summary of project findings: Present status of Cambodia Freshwater capture fisheries and management implications. DoFk'ARC- FCFMC, Phnom Penh.

Zalinge N. and Nao Thuok, 2000. Present status of Cambodia's freshwater capture fisheries and management. DoF, Phnom Penh.

Zalinge N. and Nao Thuok. 1999. The present status of Cambodia's fisheries and management implications. In project for management of the freshwater capture fisheries of Cambodia.

Zalinge, NP. F 1997. Fisheries Research needs in the Lower Mekong Basin from a perspective. Contribution to nationa] Fisheries workshop, Vientianc, Lao PI)R, 19-21 March 1997.

Zalinge, Thruok, and Tana T.S. Draft 1998, where there is water, there is fish? Fisheries Issues in the Lower Mekong Basin from a Cambodia perspective, Contribution to Mekong Panel at the 7* conference of the intem~national association for the study of common property, Vaneourver Canada, 10-14 June 1998, Mekong River CommissionjDoF/DANIDA project. Management of the Freshwater Capture Fisheries of Cambodia.